អេ អឹម ខេ

AMK

អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី (អេ អឹម ខេ)



# សេវាហិរញ្ញវត្ថុ
# នៅជិតលោកអ្នកបំផុត

២០១១

របាយការណ៍ប្រចាំឆ្នាំ

# មាតិកា


ជីវប្រវត្តិ ........ ៤
របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល ........ ៦
របាយការណ៍អគ្គនាយក ........ ៧
សមិទ្ធផលសំខាន់ៗ ........ ៨
បណ្តាញប្រតិបត្តិការ ........ ១០
កម្មសិទ្ធិ និងអភិបាលកិច្ច ........ ១១
រចនាសម្ព័ន្ធគ្រប់គ្រង ........ ១២
ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រឹក្សាយោបល់ ........ ១៣
គណៈគ្រប់គ្រង ........ ១៥
អតិថិជន អេ អឹម ខេ ........ ១៦
ដំណើការគ្រប់គ្រងការងារសង្គម ........ ១៨
របកគំហើញសំខាន់ៗក្នុងការអនុវត្តន៍ការងារសង្គម ........ ២១
ផលិតផល និងនីតិវិធីការងារ ........ ២៣
សេវាផ្ទេរប្រាក់ ........ ២៩
ការឆ្លើយតបសង្គ្រោះបន្ទាន់ទឹកជំនន់ ........ ៣០
បរិកាសប្រកួតប្រជែងនៅប្រទេសកម្ពុជា ........ ៣១
ការគ្រប់គ្រងហានិភ័យ ........ ៣២
រង្វាន់ និងការទទួលស្គាល់ ........ ៣៣
របាយការណ៍ក្រុមប្រឹក្សាភិបាល ........ ៣៤
របាយការណ៍សវនករឯករាជ ........ ៣៦
តារាងតុល្យការ ........ ៣៧
របាយការណ៍លទ្ធផល ........ ៣៨
របាយការណ៍បម្រែបម្រួលមូលនិធិម្ចាស់ហ៊ុន ........ ៣៩
របាយការណ៍ចលនាសាច់ប្រាក់ ........ ៤០
កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ........ ៤១
ទីតាំងប្រតិបត្តិការរបស់គ្រឹះស្ថាន អេ អឹម ខេ ........ ៦៥



អេ អឹម ខេ និងសកលវិទ្យាល័យធនធានមនុស្សចុះអនុស្សារណៈយោគយល់សហប្រតិបត្តិការគ្នា: កញ្ញា ឆ្នាំ២០១១

## ទស្សនវិស័យ

ទស្សនវិស័យរយៈពេលវែងរបស់ អេ អឹម ខេ គឺដើម្បីសង្គមកម្ពុជាដែលប្រជាពលរដ្ឋទាំងឡាយមានឱកាសគ្រប់គ្រាន់ និងស្មើភាពគ្នា ក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គម ដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគេ ហើយអាចជួយជាវិភាគទានយ៉ាងមានប្រយោជន៍ចំពោះការអភិវឌ្ឍន៍ប្រទេសជាតិ។

## បេសកកម្ម

បេសកកម្មរបស់ អេ អឹម ខេ គឺ ជួយដល់ប្រជាពលរដ្ឋក្រីក្រភាគច្រើន ក្នុងគោលបំណងជួយធ្វើឲ្យប្រសើរឡើង នូវជីវភាពរស់នៅរបស់ពួកគេ តាមរយៈការផ្តល់សេវាមីក្រូហិរញ្ញវត្ថុសមស្រប និងបិតថេរ។

ការចាប់កំណើតរបស់អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូអិលធីឌី វិវត្តន៍មកពីការធ្វើអន្តរាគមន៍ឥណទានខ្នាតតូចរបស់អង្គការ Concern Worldwide នៅក្នុងទសវត្សរ៍ឆ្នាំ៩០។ ដោយសារប្រតិបត្តិការមានការរីកចម្រើនអង្គការ Concern បានបង្កើតក្រុមហ៊ុនមីក្រូហិរញ្ញវត្ថុដាច់ដោយឡែក ដែលបានប្រែក្លាយទៅជា អេ អឹម ខេ។ នៅត្រឹមឆ្នាំ២០០៣ អេ អឹម ខេ បានធ្វើប្រតិបត្តិការដោយឯករាជ្យពីអង្គការ Concern ហើយទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជានៅឆ្នាំ២០០៤។

នៅត្រឹមឆ្នាំ២០០៥ អេ អឹម ខេ ទទួលបានប្រាក់ចំណេញពីប្រតិបត្តិការដំបូងរបស់ខ្លួន និងទទួលបានប្រាក់កម្ចីពីប្រភពខាងក្រៅលើកដំបូង ព្រមទាំងបានបង្កើតយន្តការគ្រប់គ្រងការងារសង្គមផងដែរ។ នៅឆ្នាំជាបន្តបន្ទាប់ អេ អឹម ខេ បានរីកចម្រើនយ៉ាងឆាប់រហ័ស ចំពោះសេវាប្រាក់កម្ចីដ៏សំខាន់ និងបានពង្រីកបណ្តាញសាខាប្រតិបត្តិការនៅគ្រប់ខេត្ត។ ឆ្នាំ២០១១ អេ អឹម ខេ បាននាំមុខគេគ្រប់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ បានក្លាយទៅជាអ្នកផ្តល់សេវាប្រាក់កម្ចីធំជាងគេបំផុតនៅក្នុងប្រទេសកម្ពុជាដោយគិតពីចំនួនអតិថិជន។

នៅឆ្នាំ២០១០ អេ អឹម ខេ បានផ្តើមធ្វើកំណែទម្រង់ជាយុទ្ធសាស្ត្រ ដោយធ្វើការផ្លាស់ប្តូរពីឥណទានជនបទតែមួយមុខ ឲ្យទៅជាអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដ៏សម្បូរបែប។ យុទ្ធសាស្ត្រនេះឆ្លើយទៅនឹងតម្រូវការ ក្នុងការផ្តល់សេវាមីក្រូហិរញ្ញវត្ថុជាច្រើនប្រភេទទៅដល់ប្រជាពលរដ្ឋក្រីក្រ ក្នុងគោលបំណងធ្វើឲ្យជីវភាពរបស់ពួកគេបានប្រសើរឡើង។

ការទទួលបានអាជ្ញាប័ណ្ណប្រាក់សន្សំក្នុង២០១០ បានដើរតួនាទីយ៉ាងសំខាន់ចំពោះដំណើរការនេះ។ អាជ្ញាប័ណ្ណនេះបានអនុញ្ញាតិឲ្យ អេ អឹម ខេ ផ្តល់សេវាប្រាក់សន្សំ និងផ្ទេរប្រាក់ថ្មីៗជាច្រើនទៀត។ សេវាប្រាក់សន្សំបានដាក់ឲ្យដំណើរការនៅគ្រប់សាខាទូទាំងប្រទេសត្រឹមពាក់កណ្តាលឆ្នាំ២០១១ ជាមួយនឹងសេវាផ្ទេរប្រាក់ក្នុងស្រុក ដែលបានដំណើរការនៅក្នុងខែកក្កដា ឆ្នាំ២០១១។ អេ អឹម ខេ បានចាប់ផ្តើមសាកល្បងសេវាសន្សំងាយស្រួលតាមរយៈភ្នាក់ងារនៅខែធ្នូ ឆ្នាំ២០១១។

តាមជីវប្រវត្តិរបស់ខ្លួន ការប្តេជ្ញាចិត្តរបស់ អេ អឹម ខេ ចំពោះការងារសង្គមគឺការងារដ៏សំខាន់បំផុត។ អេ អឹម ខេ បានបង្កើតផែនការគ្រប់គ្រងការងារសង្គមយ៉ាងទូលំទូលាយ ដើម្បីធានាថាអង្គភាពនៅតែផ្តោតលើបេសកកម្មរបស់ខ្លួនក្នុងការជួយប្រជាពលរដ្ឋក្រីក្រភាគច្រើន។ នាពេលបច្ចុប្បន្ននេះ បុគ្គលិក អេ អឹម ខេ ចំនួន៩៧៣នាក់ បម្រើអតិថិជនជាង២៨ម៉ឺននាក់ ក្នុងភូមិចំនួន៩.១៥២ នៅទូទាំងប្រទេសកម្ពុជា។ ការបញ្ជ្រាបចូលនេះមានចំនួន៦៥% នៃចំនួនភូមិសរុប និងប្រហែល១០% នៃក្រុមគ្រួសារទាំងអស់នៅក្នុងប្រទេស។

## គោលការណ៍ណែនាំ

- អេ អឹម ខេ ផ្តល់សេវាមីក្រូហិរញ្ញវត្ថុដល់ប្រជាជនក្រីក្រនៅក្នុងប្រទេសកម្ពុជា ដែលមានវិន័យហិរញ្ញវត្ថុរឹងមាំនៅគ្រប់កម្រិត។
- អេ អឹម ខេ ប្តេជ្ញាបើកទូលាយឲ្យមានតម្លាភាពនូវគ្រប់ផ្នែកទាំងអស់នៃការគ្រប់គ្រង និងប្រតិបត្តិការ។
- អេ អឹម ខេ ប្តេជ្ញាធ្វើការអភិវឌ្ឍន៍ ដំណើរការ/សេវាកម្ម និងប្រកាន់ខ្ជាប់នូវអត្តចរិត និងស្តង់ដា ដើម្បីធានាឲ្យបាននូវការបម្រើសង្គមប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយរួមទាំងការការពារអតិថិជន។
- អេ អឹម ខេ គឺជាគ្រឹះស្ថានរៀនសូត្រ ដែលការផ្លាស់ប្តូរ និងការចែករំលែកនូវព័ត៌មានដ៏សមស្រប ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍បុគ្គលិក ការបណ្តុះបណ្តាល ព្រមទាំងចូលរួមចំណែកក្នុងការកែលម្អគោលនយោបាយ និងប្រព័ន្ធ។

## ក្រមអនុវត្តន៍របស់ អេ អឹម ខេ នៅក្នុងកិច្ចការពារអតិថិជន

១. **ការរួមបញ្ចូល:** យើងនឹងផ្តល់ផលិតផល និងសេវាកម្មរបស់ អេ អឹម ខេ ដល់ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋដែលគេមិនសូវយកចិត្តទុកដាក់ឲ្យបានច្រើនបំផុត។

២. **ការជៀសវាងពីបំណុលវណ្តក:** យើងនឹងផ្តល់កម្ចីដល់អតិថិជនទៅតាមលទ្ធភាពនៃការបង់សងត្រឡប់របស់អតិថិជន និងស្វែងរកមធ្យោបាយដើម្បីជៀសវាងបំណុលវណ្តកតាមដែលអាចធ្វើទៅបាន។

៣. **ការកំណត់តម្លៃដែលមានតម្លាភាព:** យើងនឹងផ្តល់នូវព័ត៌មានទៅឲ្យអតិថិជនពីគោលការណ៍តម្លៃ និងកាតព្វកិច្ច ព្រមទាំងធានាឲ្យមានតម្លាភាពក្នុងការកំណត់តម្លៃផលិតផល និងប្រតិបត្តិការ។

៤. **ក្រមសីលធម៌បុគ្គលិក:** យើងនឹងធានាឲ្យមាននូវឥរិយាបថប្រកបដោយក្រមសីលធម៌ខ្ពស់ និងការគោរពចំពោះអតិថិជន ពីសំណាក់បុគ្គលិកគ្រប់ជាន់ថ្នាក់។

៥. **សេរីភាពនៃការជ្រើសរើស:** (ផលិតផល និងសេវាកម្ម) យើងនឹងសម្របសម្រួលព្រមទាំងលើកកម្ពស់សេរីភាពក្នុងការជ្រើសរើសចំពោះអតិថិជនទាំងអស់។

៦. **ការអនុវត្តន៍សមស្របក្នុងការទារបំណុល:** ការអនុវត្តន៍ក្នុងការទារបំណុល និងប្រព្រឹត្តទៅដោយសមស្រប និងការសហការណ៍ដោយពុំមានការរំលោភបំពាន ព្រមទាំងការគំរាមកំហែង។

៧. **យន្តការឆ្លើយតបចំពោះមតិយោបល់:** យើងនឹងផ្តល់នូវយន្តការសមស្រប និងងាយស្រួលដល់អតិថិជនដើម្បីផ្តល់មតិយោបល់ និងដំណោះស្រាយ។

៨. **ព័ត៌មានឯកជនរបស់អតិថិជន:** ព័ត៌មានឯកជនរបស់អតិថិជននឹងតែងតែត្រូវបានគោរពជានិច្ចកាលលើកលែងតែមានតម្រូវការផ្នែកច្បាប់។

ក្រមនេះត្រូវបានបញ្ចូលទៅក្នុងគោលនយោបាយរបស់ អេ អឹម ខេ និងត្រូវបានប្រតិបត្តិក្នុងការងារប្រចាំថ្ងៃដោយមានការត្រួតពិនិត្យតាមរយៈមុខងារនៃសវនកម្មផ្ទៃក្នុង និងស្រាវជ្រាវ។

# របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល



២០១១ គឺជាឆ្នាំដែលគួរឲ្យកត់សម្គាល់បំផុត សម្រាប់ អេ អឹម ខេ ដែលក្នុងនោះបានប្តូរទៅជាក្រុមហ៊ុន ដែលផ្តល់សេវាហិរញ្ញវត្ថុឈានមុខគេដល់ប្រជាពលរដ្ឋក្រីក្រនៅក្នុងប្រទេសកម្ពុជា។ អេ អឹម ខេ សម្រេចបានទាំងពីរផ្នែកគឺ ផ្នែកវិសាលភាព និងផលិតផលជាច្រើនដែលផ្តល់ជូនអតិថិជនរបស់ខ្លួន។

ឱកាសដ៏ប្រសើរបំផុតចំពោះ អេ អឹម ខេ គឺការផ្លាស់ប្តូរពីអ្នកផ្តល់ប្រាក់កម្ចីខ្នាតតូច ទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលក្នុងនោះនៅរក្សាបានការផ្តោតទៅលើក្រុមគ្រួសារ ដែលមានប្រាក់ចំណូលទាប រស់នៅតាមទីជនបទដាច់ស្រយាលនៅក្នុងប្រទេសកម្ពុជា។ នេះបានកើតឡើងតាមរយៈយុទ្ធសាស្ត្រជាច្រើននៃការពង្រីកបណ្តាញប្រតិបត្តិការសាខារបស់ខ្លួន និងវិសាលភាពនៃតំបន់ប្រតិបត្តិការ ការដាក់ឲ្យដំណើរការផលិតផលថ្មីៗជាច្រើនមានដូចជា ផលិតផលសន្សំ សេវាផ្ទេរប្រាក់ក្នុងស្រុក ព្រមទាំងដាក់សាកល្បងសេវាសន្សំងាយស្រួល ដែលអនុញ្ញាតិឲ្យ អេ អឹម ខេ បន្តដំណើរការរបស់ខ្លួនក្នុងការផ្តល់ផលិតផលទៅតាមតម្រូវការជាច្រើនទៅកាន់ទីផ្សារគោលដៅរបស់ខ្លួន។ ឆ្នាំ២០១២ រក្សាបាននូវការសន្យាធ្វើឲ្យរីកចម្រើនយ៉ាងឆាប់រហ័ស ផ្នែកសេវាប្រាក់សន្សំ សេវាផ្ទេរប្រាក់ និងការពង្រីកនូវសេវាសន្សំងាយស្រួល ដែលជាហេតុធ្វើឲ្យ អេ អឹម ខេ បន្តដំណើររបស់ខ្លួនក្នុងការផ្តល់ផលិតផលជាច្រើនប្រភេទទៅតាមតម្រូវការនៅក្នុងទីផ្សារគោលដៅរបស់ខ្លួន។

ទោះបីជាកំពុងពិចារណាលើការវិនិយោគផ្នែកបច្ចេកវិទ្យា និងបណ្តាញសាខា អេ អឹម ខេ នៅតែអាចសម្រេចបានប្រាក់ចំណេញរបស់ខ្លួនជិតពីរដងលើកម្រិតប្រាក់ចំណេញក្នុងឆ្នាំ២០១០។ សមិទ្ធផលនេះកើតឡើងដោយសារការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាក្នុងផ្នែកឥណទាន ដែលគ្រប់ផ្នែកទាំងអស់បង្ហាញឃើញនូវការរីកចម្រើនជាវិជ្ជមានរយៈពេលពេញមួយឆ្នាំ។ ផលប័ត្រប្រាក់កម្ចី អេ អឹម ខេ ត្រូវបានផ្លាស់ប្តូរជាច្រើនតាមរយៈផលិតផលថ្មី ចំណែកទីផ្សារថ្មី និងការពង្រីកវិសាលភាពតំបន់ប្រតិបត្តិការបន្ថែមទៀត។ ការឈានទៅដល់សហគមន៍ក្រីក្រ ត្រូវបានកែលម្អនៅក្នុងរយៈពេលមួយឆ្នាំ។ ការពិតដែល អេ អឹម ខេ បានបញ្ចប់ឆ្នាំរបស់ខ្លួនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលធំជាងគេបំផុតនៅក្នុងប្រទេសកម្ពុជាដោយរាប់ពីចំនួនអ្នកខ្ចីប្រាក់ ស្តែងឲ្យឃើញពីការពាក់ព័ន្ធរបស់ខ្លួនមិនត្រឹមតែអតិថិជនរបស់ខ្លួន ថែមទាំងជាហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់ប្រទេស។ ក្រុមគ្រួសារជាង ២៨ ម៉ឺននាក់ ឬប្រហែលជា ប្រជាជនជាង ១,៤ លាននាក់ មានទំនាក់ទំនងហិរញ្ញវត្ថុជាមួយ អេ អឹម ខេ។ ជាងពាក់កណ្តាលនៃអតិថិជនថ្មី ស្ថិតនៅក្នុងបន្ទាត់នៃភាពក្រីក្រផ្លូវការនៅក្នុងប្រទេស។

កំណត់សម្គាល់មួយផ្សេងទៀតគឺការបង្កើតឲ្យមានសមាគមន៍បុគ្គលិក អេ អឹម ខេ ដែលតំណាងក្រុមបុគ្គលិកដ៏រឹងមាំចំនួន ៩៧៣ នាក់របស់គ្រឹះស្ថាន។ សមាគមន៍បុគ្គលិក អេ អឹម ខេ ត្រូវបញ្ចូលជាផ្លូវការ ជាភាគទុនិកនៅក្នុងក្រុមហ៊ុន ជាជំហានដែលទទួលស្គាល់តួនាទីសំខាន់ដែលបានចូលរួមដោយបុគ្គលិក អេ អឹម ខេ ក្នុងការសម្រេចបានគោលដៅរបស់គ្រឹះស្ថាន។ នេះបង្ហាញឲ្យឃើញពីការប្តេជ្ញាចិត្តរបស់ភាគទុនិក និងសមាជិកក្រុមប្រឹក្សាភិបាលក្នុងការស្វែងរកវិធីសាស្ត្រដែលមានប្រសិទ្ធភាព ដើម្បីបង្កើនទុនរបស់បុគ្គលិកនៅក្នុងគ្រឹះស្ថាន។

២០១២ នឹងក្លាយទៅជាឆ្នាំសរុប នៅពេលដែលប្រភេទផលិតផលថ្មីៗជាច្រើននឹងលេចចេញជារូបរាង ព្រមទាំងអាជីវកម្មផ្តល់ប្រាក់កម្ចីបន្តរីកចម្រើនក្នុងទំរង់ស្ថិតស្ថេរដែលការច្នៃប្រឌិតជាច្រើននៅតែបន្តអនុវត្តន៍ជានិច្ច។ ការកែនប្រមូលប្រាក់សន្សំពីសាធារណជននឹងដើរតួនាទីមួយផ្នែកយ៉ាងធំនៅក្នុងតារាងតុល្យការ ហើយសេវាផ្ទេរប្រាក់នឹងធ្វើឲ្យផ្លាស់ប្តូរចរន្តនៃប្រាក់ចំណូល។ ទាំងអស់នេះនឹងត្រូវសម្រេចបានជាមួយនឹងការផ្តោតអារម្មណ៍ ដែលមិនបរាជ័យដើម្បីធ្វើការជាមួយអ្នកដែលទទួលបានផលិតផលតិចនៅក្នុងសង្គម។

គ្មានសមិទ្ធផលណាមួយខាងលើ អាចសម្រេចបានដោយគ្មានការដឹកនាំដ៏រឹងមាំ និងហ៊ានសហួននៅ អេ អឹម ខេ ដោយអគ្គនាយក Pete Power របស់ខ្លួននោះទេ។ លោក Pete ជាមួយគណៈគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថាន បានដឹកនាំ អេ អឹម ខេ នាំមកនូវឆ្នាំមួយដែលគួរឲ្យស្ញប់ស្ញែង ហើយក្រុមប្រឹក្សាភិបាលសូមអរគុណចំពោះរូបគាត់ ព្រមទាំងសមាជិកគណៈគ្រប់គ្រងផ្សេងទៀត ចំពោះការងារដែលប្រកបដោយគុណភាពខ្ពស់ និងការដឹកនាំប្រកបដោយការប្តេជ្ញាចិត្តខ្ពស់របស់ អេ អឹម ខេ។ សំខាន់បំផុតជាងនេះទៅទៀត ក្រុមប្រឹក្សាភិបាលសូមសំដែងនូវការដឹងគុណ និងសូមជូនពរដល់បុគ្គលិក អេ អឹម ខេ ទាំងអស់ ដែលសម្រេចបាននូវយុទ្ធសាស្ត្រដ៏រឹងមាំប្រកបដោយជោគជ័យក្នុងការអនុវត្តន៍ការងាររយៈពេលជាច្រើនឆ្នាំមកហើយ។

ភាពជោគជ័យរបស់ អេ អឹម ខេ អាស្រ័យលើមួយផ្នែកយ៉ាងធំពីទំនុកចិត្តរបស់គ្រួសារអតិថិជនជាង២៨ម៉ឺននាក់របស់យើងមកលើគ្រឹះស្ថាន។ យើងសូមសំដែងនូវការកោតសរសើរអស់ពីដួងចិត្តចំពោះទំនុកចិត្ត និងប្តេជ្ញាចិត្តចំពោះគោលដៅរួមក្នុងការធ្វើឲ្យប្រសើរឡើង ភាពងាយស្រួលក្នុងការប្រើសារាធាតុហិរញ្ញវត្ថុ ក្នុងការជួយធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ពួកគេ ហើយប្រាកដជាមានឥទ្ធិពលល្អប្រសើរលើគុណភាពនៃជីវិតរស់នៅរបស់ពួកគេជាក់ជាពុំខានឡើយ។



**TANMAY CHETAN**
ប្រធានក្រុមប្រឹក្សាភិបាល អេ អឹម ខេ

កំឡុងឆ្នាំ ២០១១ អេ អឹម ខេ បានរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងការផ្លាស់ប្តូរខ្លួនឯងផ្ទាល់ពីគ្រឹះស្ថាន ដែលផ្តល់តែប្រាក់កម្ចីក្លាយទៅជាអ្នកផ្តល់សេវាមីក្រូហិរញ្ញវត្ថុដ៏សម្បូរបែប។

អេ អឹម ខេ បានបន្តពង្រីកយ៉ាងទូលំទូលាយក្នុងការផ្តល់សេវាប្រាក់កម្ចីជាមួយនឹងការពង្រីកអាជីវកម្មថ្មី និងផលិតផលកម្ចីកសិកម្មទូទាំងប្រទេស។ កម្ចីបណ្តាក់កសិកម្មបានចាប់ផ្តើមដាក់ឲ្យសាកល្បងនៅក្នុងខេត្តជាច្រើន។ អេ អឹម ខេ ក៏បានពង្រីកការផ្តល់ផលិតផលកម្ចីងាយស្រួលបន្ថែមទៀតនៅតាម ទីប្រជុំជន ជាយរាជធានី / ខេត្ត។ ក្នុងរយៈពេលពេញមួយឆ្នាំ អេ អឹម ខេ បាននាំមុខធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការផ្តល់ប្រាក់កម្ចីធំជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា ដោយកំពុងបម្រើអតិថិជនកម្ចីចំនួន ២៧៥.២៥១។

ការដាក់ឲ្យដំណើរការសេវាប្រាក់សន្សំនៅគ្រប់សាខាទូទាំងប្រទេស បានបញ្ចប់នៅក្នុងខែមិថុនា ឆ្នាំ២០១១។ សេវាផ្ទេរប្រាក់បានដាក់ឲ្យដំណើរការនៅខែកក្កដា បន្ទាប់មកពង្រីកទៅដល់គ្រប់សាខានៅខែបន្ទាប់។ អេ អឹម ខេ បានចាប់ផ្តើមដំណើរពង្រីកបណ្តាញប្រតិបត្តិការនៅអនុសាខាដល់សាធារណជននៅក្នុងត្រីមាសទី ៤ ឆ្នាំ ២០១១។ គ្រប់អនុសាខាទាំងអស់នឹងធ្វើការកែប្រែឲ្យប្រសើរឡើង ដោយបើកបម្រើសេវាប្រាក់សន្សំ ផ្ទេរប្រាក់ និងការបង់សងត្រឡប់ប្រាក់កម្ចី ដល់សាធារណជនទាំងអស់នៅដើមឆ្នាំ ២០១២។ ដូច្នេះហើយទើបមានអនុសាខាច្រើនរហូតដល់ ៨៥ កន្លែងត្រូវដាក់បន្ថែមទៀតនៅក្នុងបណ្តាញប្រតិបត្តិការដែលមានស្រាប់។

ក្នុងកំឡុងឆ្នាំ ២០១១ អេ អឹម ខេ បានវិនិយោគយ៉ាងច្រើនផ្នែកបច្ចេកវិទ្យាធនាគារចល័ត ដែលជាយន្តការមួយក្នុងការកែនប្រមូលប្រាក់សន្សំនៅតាមភូមិ។ ដំណើរសេវាប្រាក់សន្សំនៅតាមភូមិនេះទាមទារឲ្យមានអាជ្ញាប័ណ្ណរបស់បច្ចេកវិទ្យា និងដំណើរការផ្សេងៗដែលឲ្យយើងអនុវត្តបាន ព្រមទាំងការបង្កើតថ្មីនៃបែបបទប្រតិបត្តិការដែលមានទំនាក់ទំនងជាមួយបណ្តាញភ្នាក់ងារដោយមានការសហការណ៍ជាមួយបុគ្គលិកអេ អឹម ខេ។ សេវាសន្សំងាយស្រួលបានផ្តើមដាក់សាកល្បងនៅក្នុងត្រីមាសទី ៤ ជាមួយនឹងដាក់ឲ្យដំណើរការនៅទូទាំងប្រទេសដូចដែលបានរំពឹងទុកនៅពេលសេវានេះត្រូវបានសាកល្បងហើយ។

អេ អឹម ខេ ទទួលបានប្រាក់ចំណេញចំនួន ១,៧៦ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១១ ដែលស្មើនឹង ១៣,៦៦% នៃចំណូលទទួលបានពីមូលនិធិភាគទុនិក។

## សមិទ្ធផលសំខាន់ៗ មានដូចខាងក្រោម:

- ការដាក់ឲ្យដំណើរការផលិតផលប្រាក់សន្សំនៅគ្រប់សាខា ហើយការកើនឡើងចំនួនគណនីសន្សំពី ២.៧៨១ ទៅដល់ ៨.៩២៤។
- ការកើនឡើងនូវចំនួនទឹកប្រាក់សន្សំពីសាធារណជនពី ១,១ លានដុល្លារអាមេរិករហូតដល់ ៤,១ លានដុល្លារអាមេរិក។
- ការដាក់ឲ្យដំណើរការសេវាផ្ទេរប្រាក់ក្នុងស្រុកនៅខែកក្កដា ដែលមានប្រតិបត្តិការផ្ទេរចំនួន ១.៦៧៦ ដែលក្នុងនោះមានទឹកប្រាក់រហូតដល់ចំនួន ៥២៨.០៩១ ដុល្លារអាមេរិកក្នុងឆ្នាំ ២០១១។
- ការអភិវឌ្ឍន៍បច្ចេកវិទ្យាសន្សំងាយស្រួល និងការសាកល្បងបណ្តាញភ្នាក់ងារនៅតាមភូមិ ក្នុងការកែនប្រមូលប្រាក់សន្សំដោយប្រើទូរស័ព្ទដៃ។
- ការកើនឡើងចំនួនអ្នកខ្ចីប្រាក់ទាំងអស់ជិត ១០% ពីចំនួន ២៥០.៩៣០ រហូតដល់ ២៧៥.២៥៤។
- ផលប័ត្រប្រាក់កម្ចីការកើនឡើង ៥១% ពី ៣១,៣ លានដុល្លារអាមេរិកដល់ ៤៧,២ លានដុល្លារអាមេរិក។
- គុណភាពផលប័ត្រប្រាក់កម្ចីល្អបំផុត ដោយផលប័ត្រដែលមានហានិភ័យ ៣០ ថ្ងៃ នៅត្រឹម ០,១០%។
- ការដាក់ដំណើរការនូវផលិតផលកម្ចីថ្មីជាច្រើននៅទូទាំងប្រទេសរួមមាន កម្ចីពង្រីកអាជីវកម្ម កម្ចីកសិកម្ម និងកម្ចីងាយស្រួល។ ផលិតផលថ្មីទាំងនេះ បង្កើនផលប័ត្រប្រាក់កម្ចីប្រហែល ៤ លានដុល្លារអាមេរិកជាមួយការបង់សងត្រឡប់ជិត ១០០% គិតមកដល់ថ្ងៃនេះ។



- ការសាកល្បងផលិតផលកម្ចីបណ្តាក់កសិកម្មឯកត្តជន ដែលទើបបង្កើតថ្មី។
- ការផ្តល់កម្ចីសង្គ្រោះបន្ទាន់ទឹកជំនន់បណ្តោះអាសន្ន ដល់អតិថិជនចំនួន ១.៦៣១ នាក់ ដែលទទួលរងផលប៉ះពាល់គ្រោះទឹកជំនន់ដ៏ធ្ងន់ធ្ងរនៅក្នុង ខែកញ្ញា-តុលា។
- សមាគមន៍បុគ្គលិក អេ អឹម ខេ (AMK-SA) បានបង្កើតឡើងក្នុងឆ្នាំនេះ ដោយបុគ្គលិកជាម្ចាស់កម្មសិទ្ធិនៃភាគហ៊ុនរបស់ អេ អឹម ខេ តាមរយៈការផ្តល់ជាភាគហ៊ុនអំណោយ និងក្រោមរូបភាពទិញ។

ឆ្នាំ ២០១២ នឹងជួបនូវការប្រកួតប្រជែង និងឱកាសថ្មីៗជាច្រើនសម្រាប់ អេ អឹម ខេ។ អេ អឹម ខេ នឹងបន្តដំណើរការផ្តល់ផលិតផលសន្សំ និងសេវាផ្ទេរប្រាក់នៅតាមបណ្តាញអនុសាខាទាំងអស់។ នៅត្រឹមចុងត្រីមាសទី១ការិយាល័យចំនួន ១០៨ កន្លែងនឹងត្រូវបើកបម្រើសាធារណជននៅទូទាំងប្រទេស។ អេ អឹម ខេ បានចូលរួមក្នុងការិយាល័យឥណទានកម្ពុជា (CBC) ដែលត្រូវត្រួតពិនិត្យមើលគ្រប់ពាក្យស្នើសុំប្រាក់កម្ចីថ្មីៗទាំងអស់នៅដើមឆ្នាំ ២០១២។ នេះនឹងបង្ហាញឲ្យឃើញពីដំណើរការផ្លាស់ប្តូរដ៏សំខាន់ចំពោះ អេ អឹម ខេ ប៉ុន្តែនឹងមានឥទ្ធិពលយ៉ាងខ្លាំងលើតម្លាភាពអតិថិជននិងគុណភាពផលប័ត្រប្រាក់កម្ចី។ អេ អឹម ខេ នឹងត្រួតពិនិត្យយ៉ាងជិតដល់ចំពោះដំណើរការ នៃការសាកល្បងសេវាសន្សំងាយស្រួលក្នុងឆ្នាំ ២០១២ ជាមួយនឹងការចាប់ផ្តើមដាក់ឲ្យដំណើរការនៅទូទាំងប្រទេសនាពេលឆាប់ៗនេះ ប្រសិនបើមានដំណើរការល្អប្រសើរ។ អេ អឹម ខេ រៀបចំផែនការសិក្សាស្រាវជ្រាវ ព្រមទាំងចាប់ផ្តើមសាកល្បងសេវាធានារ៉ាប់រងខ្នាតតូចក្នុងកំឡុងឆ្នាំ ២០១២។

ខ្ញុំសូមសំដែងនូវអំណរអរគុណចំពោះប្រធានក្រុមប្រឹក្សាភិបាល អេ អឹម ខេ លោក Tanmay Chetan ព្រមទាំងសមាជិកគណៈកម្មការទាំងអស់សម្រាប់ការដឹកនាំការគាំទ្រ និងណែនាំបង្ហាញផ្លូវរយៈពេលមួយឆ្នាំពេញ។ ជាពិសេសជាងនេះទៅទៀតខ្ញុំសូមកោតសរសើរបុគ្គលិក អេ អឹម ខេ ទាំងអស់ ចំពោះការខិតខំប្រឹងប្រែងបំពេញការងារ និងការព្យាយាមក្នុងរយៈពេលមួយឆ្នាំ។ ទាំងអស់នេះមានសារៈសំខាន់បំផុតចំពោះជោគជ័យដែលកំពុងមានរបស់ អេ អឹម ខេ។



**PETE POWER**
អគ្គនាយក, អេ អឹម ខេ ខូអិលធីឌី

# សមិទ្ធផលសំខាន់ៗ

| | ធ្នូ~០៨ | ធ្នូ~០៩ | ធ្នូ~១០ | ធ្នូ~១១ |
|---|---|---|---|---|
| **សមិទ្ធផលសំខាន់ៗ ផ្នែកប្រតិបត្តិការ** | | | | |
| ចំនួនសាខា | ២០ | ២២ | ២២ | ២២ |
| ចំនួនអនុសាខា | ២៥ | ៤៣ | ៥៦ | ៧៦ |
| ចំនួនភូមិ | ៤.៧៦២ | ៦.២៥៣ | ៨.០៣២ | ៩.១៥២ |
| ចំនួនភូមិសរុបដែលធ្វើប្រតិបត្តិការ | ៣៦ % | ៤៥ % | ៥៧ % | ៦៥ % |
| ចំនួនបុគ្គលិកសរុប | ៥៦៦ | ៧៦៦ | ៨៤៤ | ៩៧៣ |
| មន្ត្រីអតិថិជនធៀបនឹងបុគ្គលិកសរុប | ៥៧ % | ៥៧ % | ៥៧ % | ៥៤ % |
| ចំនួនអតិថិជនសរុប | ១៨៩.៣៩០ | ២១៨.២៥៦ | ២៥១.៦៣៦ | ២៨០.១៩៥ |
| ចំនួនអ្នកខ្ចីសកម្ម (មិនរាប់បញ្ចូលបុគ្គលិក) | ១៨៨.៦៩៦ | ២១៧.៤៧៧ | ២៥០.៩៣០ | ២៧៥.២៥១ |
| អ្នកកម្ចីជាក្រុម | ៨៥ % | ៨៨ % | ៩៣ % | ៩៣ % |
| អ្នកកម្ចីឯកត្តជន | ១៥ % | ១២ % | ៧ % | ៧ % |
| ផលប័ត្រប្រាក់កម្ចី (ដុល្លារអាមេរិក មិនរាប់បញ្ចូលប្រាក់កម្ចីបុគ្គលិក) | $ ២៣.១៨៧.៩១១ | $ ២៤.៧៩៥.៨៨០ | $ ៣១.៣២៩.៨៥៧ | $ ៤៧.២៤៨.៥៩៩ |
| កម្ចីជាក្រុម | ៦៥ % | ៧៧ % | ៨៦ % | ៨៤ % |
| កម្ចីឯកត្តជន | ៣៥ % | ២៣ % | ១៤ % | ១៦ % |
| ចំនួនអ្នកខ្ចីសកម្ម / ចំនួនជាមធ្យមមន្ត្រីអតិថិជន | ៧៤៦ | ៥៤២ | ៥៤៨ | ៥២៣ |
| សមតុល្យប្រាក់កម្ចី / ចំនួនជាមធ្យមមន្ត្រីអតិថិជន (ដុល្លារអាមេរិក) | $ ៩២.៥៨៣ | $ ៦២.៦៦១ | $ ៦៩.៣២៤ | $ ៩០.៦៤៤ |
| ចំនួនអ្នកដាក់ប្រាក់សន្សំសរុប | ១.៧០២ | ១.៧៧០ | ២.៧៨១ | ៨.៩២៤ |
| សមតុល្យប្រាក់សន្សំសរុប (ដុល្លារអាមេរិក) | $ ១១.៤៩៤ | $ ១៩.៣៤២ | $ ១.១៤២.៤០៩ | $ ៤.១៨២.៣៧០ |
| ចំនួនប្រតិបត្តិការផ្ទេរប្រាក់សរុប | - | - | - | ១.៦៧៦ |
| ចំនួនទឹកប្រាក់ដែលបានផ្ទេរ (ដុល្លារអាមេរិក) | - | - | - | ៤២៨.០៤១ |
| **សមិទ្ធផលសំខាន់ៗ ផ្នែកហិរញ្ញវត្ថុ** | | | | |
| ប្រាក់ចំណេញសុទ្ធ (ក្រោយពេលបង់ពន្ធ គិតជាដុល្លារអាមេរិក) | $ ៩៨៦.១៤៥ | $ ៤៤៨.១៧២ | $ ៩៣៥.២៣៩ | $ ១.៧៦៦.៩៧១ |
| ប្រាក់ចំណេញសុទ្ធ (ក្រោយពេលបង់ពន្ធ គិតជាដុល្លារអាមេរិកOSS) | ១១៨ % | ១០៦ % | ១០៨ % | ១១៤ % |
| ចំណូលទទួលបានពីទ្រព្យសកម្ម (RoA) | ៤,៣០ % | ១,៣០ % | ២,៤៦ % | ៣,១០ % |
| ចំណូលទទួលបានពីទ្រព្យសកម្មដែលបានកែសម្រួល (តិចជាងB២B) | ៥,៤០ % | ១,៣៥ % | ២,៧១ % | ៣,៧៦ % |
| ចំណូលទទួលបានពីមូនិធិភាគទុនិក (RoE) | ១២,៧០ % | ៤,២០ % | ៨,២៦ % | ១៣,៦៦ % |
| ទិន្នផល ផលប័ត្រប្រាក់កម្ចី | ៣៥,៩ % | ៣៤,៥ % | ៣៤,៥ % | ៣៣,៩ % |
| អនុបាតថ្លៃដើមប្រតិបត្តិការ | ២២,៤ % | ២២,០ % | ២២,៣ % | ១៩,៣ % |
| ថ្លៃដើមមូលនិធិគិតជាមធ្យម | ៨,៣០ % | ១០,២០ % | ១០,៨៧ % | ១១,១៤ % |
| អនុបាតបំណុល (បំណុលធៀបនឹងមូលនិធិភាគទុនិក) | ១,៨០ | ២,៥៥ | ២,៥៨ | ៣,៣៥ |
| ផលប័ត្រប្រាក់កម្ចីមានហានិភ័យ ៣០ថ្ងៃ | ០,៣៣ % | ២,៨៥ % | ១,៥៧ % | ០,១០ % |
| អនុបាតបំណុលដែលបានលុបចោល | ០,១៩ % | ០,៣៨ % | ១,១៧ % | ១,១១ % |
| **សមិទ្ធផលសំខាន់ៗ ផ្នែកសង្គម** | | | | |
| អ្នកខ្ចីជាស្ត្រី | ៨៥ % | ៨៥ % | ៨៦ % | ៨៧ % |
| ប្រាក់កម្ចីទាបជាង ៣០០ ដុល្លារអាមេរិក | ៨៩ % | ៩១ % | ៩៤ % | ៩៤ % |
| ចំនួនគណនីទាបជាង ៣០០ ដុល្លារអាមេរិក | ១៦៨.០៤៦ | ១៩៧.៤៧១ | ២៣៦.៧៤៣ | ២៥៨.៨៤១ |
| ចំនួនអ្នកខ្ចីនៅជនបទ | ៩៥ % | ៩៣ % | ៩២ % | ៩៤ % |
| ទំហំកម្ចីជាមធ្យមក្នុងអ្នកខ្ចីម្នាក់ (ដុល្លារអាមេរិក) | $ ១២៤ | $ ១១៦ | $ ១២៦ | $ ១៧២ |
| អ្នកខ្ចីជាក្រុម | $ ៧៧ | $ ៩៩ | $ ១១៥ | $ ១៥៣ |
| អ្នកខ្ចីជាឯកត្តជន | $ ២៨៦ | $ ២២០ | $ ២៤៥ | $ ៤០២ |
| ប្រាក់កម្ចីដែលបានបញ្ចេញជាមធ្យម (ដុល្លារអាមេរិក) | $ ១៤៩ | $ ១៥៥ | $ ១៦៥ | $ ២១៣ |
| អ្នកខ្ចីជាក្រុម | $ ១១៥ | $ ១២៣ | $ ១៤១ | $ ១៨៧ |
| អ្នកខ្ចីជាឯកត្តជន | $ ៣៥៧ | $ ៣៥៩ | $ ៤២៧ | $ ៥៧១ |
| ប្រាក់សន្សំជាមធ្យមក្នុងអ្នកសន្សំម្នាក់ (ដុល្លារអាមេរិក) | $ ៧ | $ ១១ | $ ៤១១ | $ ៤៦៩ |
| អត្រាចាកចេញ* | ២៤ % | ៣៥ % | ៣១ % | ២៦ % |
| អត្រាចាកចេញដែលបានកែសម្រួល (ដកអ្នកនៅ)* | ១៣ % | ១៩ % | ១៥ % | ១៦ % |
| ការពង្រីកវិសាលភាព: អតិថិជនថ្មី (<១ឆ្នាំ) ក្រោមបន្ទាត់នៃភាពក្រីក្រ | | | | |
| ភាគរយចំនួនអតិថិជនថ្មីក្រោមបន្ទាត់កង្វះអាហារថ្នាក់ជាតិ (ការប៉ាន់ស្មាន) | ៦៣ % | ៥៦ % | ៥០ % | ៥០ % |
| ចំនួនអតិថិជនថ្មីក្រោមបន្ទាត់ភាពកង្វះអាហារថ្នាក់ជាតិ (ការប៉ាន់ស្មាន) | ៥៦.៦០៥ | ៤៧.១៥១ | ៥៤.៦៥២ | ៤៥.៣៧៤ |

* % នៃអ្នកនៅ ដោយផ្អែកលើការស្ទង់មតិចាកចេញ (២០០៧. ២០០៩. និង២០១០) និងការស្ទង់មតិសារជាថ្មីម្តងទៀត (២០០៨)។















អតិថិជន អេ អឹមខេ ផលិតស្ករត្នោតក្នុងខេត្តព្រៃវែង: កក្កដា ២០១១

# បណ្ដាញប្រតិបត្តិការ




| ខេត្ត | ស្រុក | ឃុំ | ភូមិ | ចំនួនអ្នកខ្ចីសរុប * |
|---|---|---|---|---|
| បន្ទាយមានជ័យ | ៨ | ៦៤ | ៤៧៨ | ១០.៨០០ |
| បាត់ដំបង/ប៉ៃលិន | ១៦ | ៩៨ | ៦២០ | ១៧.០៥៨ |
| កំពង់ចាម | ១៦ | ១៦៤ | ១.១៤៥ | ៣៤.០៥៥ |
| កំពង់ឆ្នាំង | ៧ | ៥៧ | ៣៩៤ | ១០.៦២៧ |
| កំពង់ស្ពឺ | ៨ | ៧៨ | ៧៨៧ | ២០.៦៤៥ |
| កំពង់ធំ | ៨ | ៨០ | ៥៤១ | ១៦.៩១៧ |
| កំពត/កែប | ១០ | ៩៥ | ៩១៨ | ១៤.០៤៧ |
| កណ្ដាល | ១១ | ១៣០ | ៥៩៤ | ២០.៤៦៧ |
| កោះកុង | ៥ | ១៩ | ៧៧ | ៤.៣៤៣ |
| ក្រចេះ | ៥ | ៣៥ | ១៧៦ | ១១.៣៥១ |
| មណ្ឌលគិរី | ៥ | ១៨ | ៥៩ | ១.៨២៥ |
| ឧត្តមានជ័យ | ៥ | ២៤ | ២០១ | ៨.៧៤៩ |
| ភ្នំពេញ | ៨ | ៦៩ | ១៥៦ | ២.៨០៧ |
| ព្រះសីហនុ | ៤ | ២៥ | ៩៨ | ៤.១៦៩ |
| ព្រះវិហារ | ៨ | ៤៧ | ១៧០ | ៥.៤១៧ |
| ព្រៃវែង | ១២ | ១០៧ | ៦៧៣ | ២២.៧២២ |
| ពោធិ៍សាត់ | ៦ | ៤៩ | ៣៦៦ | ១១.៥៤៨ |
| រតនគិរី | ៨ | ៥០ | ១៥៩ | ៣.២៨០ |
| សៀមរាប | ១២ | ៩៦ | ៦៨២ | ១៧.០៣៦ |
| ស្ទឹងត្រែង | ៤ | ២៦ | ៧៦ | ៣.២៥១ |
| ស្វាយរៀង | ៧ | ៧៨ | ៥៤៨ | ១៦.៦៣៤ |
| តាកែវ | ១០ | ៨៩ | ៦៣៤ | ១៧.៩៩១ |
| សរុប | ១៨៣ | ១.៤៨៨ | ៩.១៥២ | ២៧៥.៧៣៩* |
| % នៃប្រតិបត្តិការ | ៩៥% | ៩២% | ៦៥% | ១០%** |

*រួមបញ្ចូលកម្ចីរបស់បុគ្គលិក
** ភាគរយអតិថិជននៃចំនួនគ្រួសារសរុប

អេ អឹម ខេ មានប្រតិបត្តិការស្ទើរតែគ្រប់ស្រុកទាំងអស់នៅប្រទេសកម្ពុជា និងគ្របដណ្ដប់៩៥%នៃចំនួនឃុំសរុប ដែលមានភូមិចំនួន៩.១៥២។ បច្ចុប្បន្ននេះ អេ អឹម ខេ មានប្រតិបត្តិការក្នុងភូមិចំនួន៦៥% នៃចំនួន ភូមិសរុបចំនួន ១៤.០៧៣ នៅក្នុងប្រទេសកម្ពុជា។ អេ អឹម ខេ គឺជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលនាំមុខគេ នៅក្នុងប្រទេសកម្ពុជាដោយគិតពីចំនួនអ្នកខ្ចីប្រាក់ដែលមានអតិថិជនខ្ចីប្រាក់សរុបចំនួន២៧៥.៧៣៩នាក់។





សិក្ខាសាលាប្រធានសាខាក្នុងខេត្តមណ្ឌលគិរី: ធ្នូ ២០១១

ភាគទុនិករបស់ អេ អឹម ខេ គឺ Concern Worldwide (Ireland). Concern Worldwide UK និងសមាគមន៍បុគ្គលិក អេ អឹម ខេ (AMK-SA)។

ភាគទុនិករបស់ អេ អឹម ខេ តែងតាំងក្រុមប្រឹក្សាភិបាល ដែលទទួលខុសត្រូវអភិបាលកិច្ច និងការណែនាំជាយុទ្ធសាស្រ្តទាំងអស់របស់គ្រឹះស្ថាន។ សមាជិកក្រុមប្រឹក្សាទាំងប្រាំបួននាក់ មានជំនាញទូលំទូលាយនៅក្នុងផ្នែកហិរញ្ញវត្ថុ សវនកម្ម ច្បាប់ និងការអភិវឌ្ឍន៍ ព្រមទាំងបទពិសោធន៍យ៉ាងច្រើនផ្នែកមីក្រូហិរញ្ញវត្ថុ ពាណិជ្ជកម្ម និងការវិនិយោគផ្នែកវិស័យធនាគារ។

ក្រុមប្រឹក្សាភិបាល តែងតាំង អគ្គនាយក ដើម្បីដឹកនាំគណៈគ្រប់គ្រងជាន់ខ្ពស់ ហើយគណៈគ្រប់គ្រងជាន់ខ្ពស់ ត្រួតពិនិត្យគណៈគ្រប់គ្រងបន្ទាប់។ គណៈគ្រប់គ្រងជាន់ខ្ពស់រួមមាន អគ្គនាយក អគ្គនាយករង ប្រធានមន្ត្រីហិរញ្ញវត្ថុ ប្រធានមន្ត្រីប្រតិបត្តិការ និងប្រធានមន្ត្រីអាជីវកម្ម។ ក្រុមគណៈគ្រប់ជាន់ខ្ពស់នេះ ត្រួតពិនិត្យគណៈគ្រប់គ្រងបន្ទាប់។ គណៈគ្រប់គ្រងបន្ទាប់រួមមាន នាយកនាយកដ្ឋានៈ ឥណទានសន្សំ គាំទ្រសាខា Mobile Banking ហិរញ្ញវត្ថុ ហេរញ្ញិក ធនធានមនុស្ស ព័ត៌មានវិទ្យា សវនកម្មផ្ទៃក្នុង ទីផ្សារ បណ្តុះបណ្តាលស្រាវជ្រាវហានិភ័យនឹងស្របតាមនិងអភិវឌ្ឍន៍ផលិតផល។ នាយកដ្ឋានប្រតិបត្តិការ មានប្រធានភូមិភាគចំនួន ៥ ដែលប្រធានភូមិភាគនីមួយៗទទួលខុសត្រូវគ្រប់គ្រងសាខាពីចំនួន ៤ ទៅ ៥។

ក្រុមប្រឹក្សាភិបាលមានគណៈកម្មការអចិន្ត្រៃយ៍ដូចជា: (១) គណៈកម្មាធិការហិរញ្ញវត្ថុ និងសវនកម្ម (២) គណៈកម្មាធិការហានិភ័យ (៣) គណៈកម្មាធិការវាយតម្លៃ តែងតាំង និងអភិបាលកិច្ច (៤) គណៈកម្មាធិការការងារសង្គម។ គណៈកម្មាធិការបីដំបូង មានតួនាទីអភិបាលកិច្ចលើការងាររបស់គ្រឹះស្ថានជាធម្មតា។ គណៈកម្មាធិការការងារសង្គម ផ្តល់ប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សាភិបាល ពីកិច្ចការរបស់គ្រឹះស្ថាន ដោយផ្អែកលើការជ្រៀតចូលទៅកាន់ភាពក្រីក្រ ភាពសមស្របរបស់ផលិតផល ការគាំពារអតិថិជន និងការទទួលខុសត្រូវផ្នែកសង្គមទាំងមូល។



ការទំលាក់ទុនក្នុងខេត្តតាកែវ: កុម្ភៈ ២០១២

# រចនាសម្ព័ន្ធគ្រប់គ្រង



# ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រឹក្សាយោបល់



### លោក TANMAY CHETAN

ក្រុមប្រឹក្សាភិបាល
ប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធានគណៈកម្មាធិការវាយតម្លៃ តែងតាំង និងអភិបាលកិច្ច



លោក Tanmay គឺជាស្ថាបនិករួមគ្នា និងជាដៃគូគ្រប់គ្រងនៅ Agora Microfinance Partner LLP។ គាត់មានបទពិសោធន៍មីក្រូហិរញ្ញវត្ថុរយៈពេល ១២ ឆ្នាំខាងផ្នែកផ្តល់ចំណាត់ថ្នាក់ឥណទាន ការប្រឹក្សាយោបល់ និងការងារអនុវត្តន៍ជាក់ស្តែង។ ពីឆ្នាំ ២០០៣ ដល់ ២០០៧ គាត់ជាអគ្គនាយកដំបូងបង្អស់របស់ អេ អឹម ខេ។ លោក Tanmay ទទួលបានអនុបណ្ឌិតរដ្ឋបាលសាធារណៈ ពីសកលវិទ្យាល័យ Harvard Kennedy និងអនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មពីវិទ្យាស្ថាន Forest Management ប្រទេសឥណ្ឌា។

### លោក HOWARD DALZELL

ក្រុមប្រឹក្សាភិបាល
ប្រធានគណៈកម្មាធិការការងារសង្គម



លោក Howard ថ្មីៗនេះបានចូលនិវត្តន៍ពីគណៈគ្រប់គ្រងជាន់ខ្ពស់របស់អង្គការ Concern Worldwide ដែលគាត់មានតួនាទីជានាយកគោលនយោបាយ និងកិច្ចការបរទេស។ គាត់មានបទពិសោធន៍ការងារអនុវត្តន៍ជាក់ស្តែងជាង ៣០ ឆ្នាំក្នុងការជួយការងារផ្នែកមនុស្សធម៌។ លោក Howard ទទួលបានសញ្ញាប័ត្រវិទ្យាសាស្ត្រកសិកម្ម និងអនុបណ្ឌិតផ្នែកចំណីអាហារសត្វពាហនៈ។

### លោក MARCUS FEDDER

ក្រុមប្រឹក្សាភិបាល
ប្រធានគណៈកម្មាធិការហានិភ័យ និងជាសមាជិកគណៈកម្មាធិការសវនកម្ម និងហិរញ្ញវត្ថុ



លោក Marcus ជាធនាគារិក ជាមួយនឹងបទពិសោធន៍ជាង២ទសវត្សរ៍ជាស្ថាបនិករួមគ្នា និងជាដៃគូគ្រប់គ្រងនៅ Agora Microfinance Partners LLP។ ពីមុនមកគាត់ធ្លាប់កាន់តំណែងជាន់ខ្ពស់នៅស្ថាប័នជាច្រើន រួមមានធនាគារ The Toronto Dominion ធនាគារអឺរ៉ុបផ្នែកការអភិវឌ្ឍន៍ និងស្តារឡើងវិញ ធនាគារពិភពលោក ធនាគារពាណិជ្ជ Canadian Imperial។ លោក Marcus ទទួលបានបណ្ឌិតផ្នែកនយោបាយពីសកលវិទ្យាល័យ Berlin និងសញ្ញាប័ត្រអនុបណ្ឌិតទំនាក់ទំនងអន្តរជាតិ។

### លោក PETE POWER

ក្រុមប្រឹក្សាភិបាល
និងជាអគ្គនាយកបច្ចុប្បន្ន



លោក Pete ជាអគ្គនាយកគ្រឹះស្ថាន អេ អឹម ខេ ចាប់តាំងពីឆ្នាំ២០១១។ លោក Pete ជាគណនេយ្យករអាជីព និងបានចំណាយពេលជាច្រើននៅក្នុងអាជីពរបស់គាត់ជាអ្នកប្រឹក្សាផ្នែកគ្រប់គ្រងនៅក្នុងសហរដ្ឋអាមេរិក អៀកឡង់ និងប្រទេសចិន។ លោក Pete ទទួលបានបរិញ្ញាប័ត្រវិទ្យាសាស្ត្រផ្នែកទស្សនវិជ្ជា និងទំនាក់ទំនងអន្តរជាតិពីសកលវិទ្យាល័យ Scranton និងអនុបណ្ឌិតផ្នែកសមាហរណកម្មអឺរ៉ុបពីសកលវិទ្យាល័យ Limerick ព្រមទាំងអនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មពីសកលវិទ្យាល័យ Tulane ។

### លោកស្រី REBECCA MCKENZIE

ក្រុមប្រឹក្សាភិបាល
សមាជិកគណៈកម្មាធិការវាយតម្លៃ តែងតាំង និងអភិបាលកិច្ច



លោកស្រី Rebecca គឺជាស្ថាបនិករួមគ្នា និងជាដៃគូគ្រប់គ្រងនៅ Agora Microfinance Partners LLP។ លោកស្រីជាអ្នកជំនាញការផ្នែកទីផ្សារមូលធន និងពីមុនមកលោកស្រីធ្លាប់ទទួលខុសត្រូវក្នុងការទំនាក់ទំនងជាមួយអ្នកវិនិយោគទុននៅធនាគារ DEPFA។ មុនចូលបម្រើការនៅធនាគារ DEPFA លោកស្រីបម្រើការងារនៅផ្នែកលក់ទីផ្សារមូលធននៅ UBS Credit Suisse និង Paribas។ លោកស្រី Rebecca ទទួលបានបរិញ្ញាប័ត្រផ្នែកសិល្បៈពីសកលវិទ្យាល័យ Scripps។

### លោកស្រី IRINA IGNATIEVA

ក្រុមប្រឹក្សាភិបាល
សមាជិកគណៈកម្មាធិការការងារសង្គម



លោកស្រី Irina ជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុរបស់អង្គការ Concern Worldwide។ លោកស្រីមានបទពិសោធន៍ជាង១៥ឆ្នាំ ជាអ្នកប្រឹក្សាយោបល់ និងអ្នកបណ្តុះបណ្តាលផ្នែកមីក្រូហិរញ្ញវត្ថុ ហើយលោកស្រីទទួលបានសញ្ញាប័ត្រ EMBA ពីសកលវិទ្យាល័យសេដ្ឋកិច្ច Stockholm និងអនុបណ្ឌិត MA ពីសលកវិទ្យាល័យ St.Petersburg។

# ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រឹក្សាយោបល់



## លោកស្រី FRANCES SINHA

ក្រុមប្រឹក្សាភិបាល
សមាជិកគណៈកម្មាធិការការងារសង្គម

លោកស្រី Frances ជានាយកប្រតិបត្តិនៅប្រព័ន្ធជនបទ EDA ដែលមានមូលដ្ឋាននៅ Gurgaon ប្រទេសឥណ្ឌា។ លោកស្រីមានបទពិសោធន៍ជាង ២៥ ឆ្នាំ ផ្នែកស្រាវជ្រាវ និងការអភិវឌ្ឍន៍សមត្ថភាពមីក្រូហិរញ្ញវត្ថុអាស៊ី។



## លោក ADRIAN GRAHAM

ក្រុមប្រឹក្សាភិបាល
ប្រធានគណៈកម្មាធិការសវនកម្ម និងហិរញ្ញវត្ថុ
និងជាសមាជិកគណៈកម្មាធិការហានិភ័យ

លោក Adrian ជានាយកហិរញ្ញវត្ថុនៅអង្គការ UNICEF ប្រទេសអូស្ត្រាលី។ ពីមុនលោក Adrian ធ្លាប់បម្រើការងារជានាយកហិរញ្ញវត្ថុនៅអង្គការ Concern Worldwide និងជាអ្នកតំណាងរបស់អង្គការ Concern នៅប្រទេសអូស្ត្រាលី។



## លោក ទិព្វ ច័ន្ទវិបុល

ក្រុមប្រឹក្សាភិបាល

លោកបណ្ឌិត ទិព្វ ច័ន្ទវិបុល គឺជាដៃគូគ្រប់គ្រង នៅក្រុមហ៊ុនច្បាប់ Tip & Partners។គាត់ជាសមាជិកសមាគមគណៈមេធាវីនិងបម្រើការងារនៅក្រុមប្រឹក្សាសមាគមគណៈមេធាវីនៅក្នុងប្រទេសកម្ពុជា។ លោកបណ្ឌិត ច័ន្ទវិបុល បានបម្រើការងារជាទីប្រឹក្សាច្បាប់នៅក្នុងគម្រោងនានារបស់អង្គការជាច្រើន រួមមាន អង្គការសហប្រជាជាតិ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី។



## លោកស្រី HELEN IANSON

សមាជិកគណៈកម្មាធិការសវនកម្ម
និងហិរញ្ញវត្ថុ

លោកស្រី Hellen ជានាយកប្រចាំប្រទេស អង្គការ ក្នុងប្រទេសអាល់បានី ដែលបានចំណាយពេលវេលា ១៥ ឆ្នាំ ផ្នែកអភិវឌ្ឍន៍នៅអាស៊ី និងអាហ្វ្រិក។ គាត់បម្រើការនៅអង្គការអន្តរជាតិឈានមុខគេ ដូចជា អង្គការ Concern និងអង្គការ Save the Children ព្រមទាំងបំពេញការងារជិត ៣ ឆ្នាំនៅប្រទេសកម្ពុជា។ លោកស្រី Hellen ជាគណនេយ្យករអាជីពនៅប្រទេសអង់គ្លេស និងបានបម្រើការជាបុគ្គលិកសាធារណៈនៅក្នុងប្រទេសអង់គ្លេសក្នុងតួនាទីជាសវនករ និងនៅផ្នែកពាណិជ្ជកម្មនៅក្នុងអឺរ៉ុប។



## លោក JANARDHAN (JANU) RAO

សមាជិកគណៈកម្មាធិការការងារសង្គម

លោក Janu ជានាយកប្រចាំប្រទេសអង្គការ Concern នៅកម្ពុជា។ គាត់មានបទពិសោធន៍ការងារជាង២៩ឆ្នាំនៅក្នុងអង្គការក្រៅរដ្ឋាភិបាល ផ្នែកអភិវឌ្ឍន៍ជនបទ។ លោក Janu ទទួលបានអនុបណ្ឌិតផ្នែកការងារសង្គមនៅប្រទេសឥណ្ឌាក្នុងឆ្នាំ១៩៨៧។ បន្ទាប់មកបានចំណាយពេលជាច្រើនឆ្នាំធ្វើការនៅអង្គការក្នុងស្រុក នៅតំបន់ជនបទប្រទេសឥណ្ឌា។ លោក Janu បានចាប់ផ្តើមបំពេញការងារនៅអង្គការ Concern ក្នុងឆ្នាំ២000 ជាជំនួយការនាយកប្រចាំប្រទេសនៅប្រទេសស៊ូដង់ខាងត្បូងបន្ទាប់មកជានាយកប្រចាំប្រទេស Eritrea និងស៊ូដង់ខាងជើងមុននឹងបម្រើការងារនាពេលបច្ចុប្បន្ននេះនៅក្នុងប្រទេសកម្ពុជា។



## លោកស្រី OLGA TORRES

សមាជិកគណៈកម្មាធិការការងារសង្គម

លោកស្រី Olga ជានាយិកាស្រាវជ្រាវនៅ Algora Microfinance Partners LLP។ គាត់មានបទពិសោធន៍ជាង១២ឆ្នាំជាអ្នកគ្រប់គ្រង ទីប្រឹក្សាយោបល់ និងជាអ្នកស្រាវជ្រាវ។ ពីឆ្នាំ២00៣ ដល់ឆ្នាំ២00៩ លោកស្រី Olga បានដឹកនាំការងាររបស់ អេ អឹម ខេ ក្នុងការបង្កើត និងអនុវត្តប្រព័ន្ធប្រមូល និងវិភាគទិន្នន័យអតិថិជន (រួមមានកម្រិតនៃភាពក្រីក្រ) និងទិដ្ឋភាពការងារសង្គមផ្សេងៗទៀត។ លោកស្រី Olga ទទួលបានសញ្ញាប័ត្របណ្ឌិតពី Universidad Compluense (ប្រទេសអេស្ប៉ាញ) និងអនុបណ្ឌិតកិច្ចការអន្តរជាតិ ពីសកលវិទ្យាល័យ (សហរដ្ឋអាមេរិក) ។

# គណៈគ្រប់គ្រង


MR. PETE POWER
អគ្គនាយក


លោក តា បូរាណ
អគ្គនាយករង


លោក ម៉ម ជឿន
ប្រធានមន្ត្រីប្រតិបត្តិការ


លោក ឈាង តាំង
ប្រធានមន្ត្រីហិរញ្ញវត្ថុ


អ្នកស្រី លី ធីតា
នាយិការធនធានមនុស្ស


អ្នកស្រី ឡុង ចន្ថា
នាយិកាហេរញ្ញិក


លោក ណាង តីណាល់
នាយកទីផ្សារ


លោក ហៀក ចារុធ
នាយកសវនកម្មផ្ទៃក្នុង


លោក សឿង ភីរី
នាយកហានិភ័យ និងស្រេបតាម


អ្នកស្រី រឿង វីរ៉ានី
នាយិកាហិរញ្ញវត្ថុ


លោក ព្រេម ចន្ទ្រាបុត្រ
នាយកបច្ចេកវិទ្យាព័ត៌មាន


លោក មាស ចាន់រ៉ា
ប្រធានផ្នែកអភិវឌ្ឍន៍បុគ្គលិក


អ្នកស្រី ពុំ សូភី
នាយិកាស្រាវជ្រាវ


លោក ជា រតនា
នាយក Mobile Banking


អ្នកស្រី ពាំង ពិសាធ
នាយិកាបណ្តុះបណ្តាល


លោក សុខ រតនា
នាយកគាំទ្រសាខា


លោក សួន ពិសី
នាយកឥណទាន


អ្នកស្រី រិទ្ធ សុខា
ប្រធានភូមិភាគ


លោក លឹម សៀកស្រ៊ុន
ប្រធានភូមិភាគ


លោក ប៉ុក ធី
ប្រធានភូមិភាគ


លោក ឈាង វុទ្ធី
ប្រធានភូមិភាគ


លោក យីវ ផាន់ណា
ប្រធានភូមិភាគ

# អតិថិជន អេ អឹម ខេ



បុគ្គលិក អេ អឹម ខេ ចូលរួមតាំងពិព័ណការងារនៅវិទ្យាស្ថានជាតិគរុកោសល្យ: ធ្នូ ២០១១

នៅចុងឆ្នាំ ២០១១ អេ អឹម ខេ មានអតិថិជនសកម្មចំនួន ២៨០.១៩៥ នាក់ ប្ញករួមអតិថិជនកម្ចី និងសន្សំនៅទូទាំងប្រទេសកម្ពុជា។ អតិថិជនភាគច្រើន ជាអ្នកក្រីក្រ ឬក្បែរក្រីក្រ។ នាយកដ្ឋានស្រាវជ្រាវ អេ អឹម ខេ ធ្វើការស្ទាបស្ទង់យ៉ាងលម្អិតពីកំរិតជីវភាពរស់នៅជារៀងរាល់ឆ្នាំ។ ២០១១ ការស្រាវជ្រាវបង្ហាញឲ្យឃើញថា:

- ៨៧% នៃអតិថិជន អេ អឹម ខេ ជាស្ត្រី។
- ៦៣% នៃអតិថិជន ចេះអក្សរ។
- អាយុជាមធ្យមរបស់អតិថិជនគឺ ៤២ ឆ្នាំ។
- ក្រុមគ្រួសារជាមធ្យមមានសមាជិក ៥,២ នាក់, ២,៩៩ នាក់ នៃអ្នកទាំងនោះគឺជាអ្នករកប្រាក់ចំណូល។
- ៨៣% នៃអតិថិជនយ៉ាងហោចមានផ្ទៃដីកសិកម្ម ប៉ុន្តែ ៥៥% មានផ្ទៃដីតិចជាង ១,៦ អា។
- ត្រឹម ៤០% ប៉ុណ្ណោះនៃអតិថិជន អេ អឹម ខេ មានទ្រព្យសកម្មដែលមានតម្លៃខ្ពស់ (ជាង ៥០០ ដុល្លារអាមេរិក)។
- ជាងពាក់កណ្ដាលនៃអតិថិជនថ្មី ចាប់តាំងពីចាប់ផ្ដើម អេ អឹម ខេ ស្ថិតនៅក្រោមកំរិតនៃភាពក្រីក្រអាហារជនបទ (ចំណាយលើអាហារប្រចាំថ្ងៃ ២.៥១២ រៀល)។

ក្រុមគ្រួសារជាទូទៅរបស់ អេ អឹម ខេ ផ្អែកទៅលើរបៀបនៃសកម្មភាពរកប្រាក់ចំណូលផ្សេងៗគ្នា។ ដោយក្រុមគ្រួសារភាគច្រើន មានប្រភពចំណូលបី ឬច្រើនជាង។

- ៩៣% នៃគ្រួសារមានសកម្មភាពកសិកម្ម។
- ៩៥% មិនមានសកម្មភាពកសិកម្ម (ជាទូទៅមានបើកហាងលក់ដូរ ឬពាណិជ្ជកម្មតូចតាច។ល។)
- ៩៦% មានប្រាក់ចំណូលផ្សេងៗ រួមមាន ផ្ញើប្រាក់មកពីប្រទេសក្រៅ លក់ ជួល និងចំណូលបានមកពីប្រាក់កម្ចី។

ទោះបីជាអតិថិជនភាគច្រើនរស់នៅតាមជនបទ សកម្មភាពមិនមែនកសិកម្មអាចបន្ថែម ៦៣% ទៅក្នុងប្រាក់ចំណូលសរុប។ សកម្មភាពកសិកម្មរួមបញ្ចូល ៣៥% នៃចំណូលសរុប ចំណែកឯសកម្មភាពពាណិជ្ជកម្មមាន ៣% តែប៉ុណ្ណោះ។ អតិថិជនប្រើពេលវេលាជាច្រើនចំពោះការធ្វើស្រែ ហើយពឹងផ្អែកសកម្មភាពមិនមែនកសិកម្មដើម្បីរកប្រាក់ចំណូល។

ដោយយោងទៅតាមការចាត់ថ្នាក់អតិថិជន ការចំណាយដ៏ច្រើនបំផុត រួមមានលើអាហារ (៥០%) ការវិនិយោគលើសកម្មភាពមិនមែនកសិកម្ម (២៩%) សម្ភារៈគ្រួសារ (៨%) និងការវិនិយោគផ្នែកកសិកម្ម (៨%)។ ពិធីបុណ្យ ទិញទ្រព្យសម្បត្តិ សុខភាព និងការបង់សងត្រឡប់ប្រាក់កម្ចី ជារឿយៗ ក៏ជាបន្ទុករបស់ក្រុមគ្រួសារផងដែរ ប៉ុន្តែវាជាផ្នែកដ៏តូចមួយ នៃការចំណាយប្រចាំឆ្នាំ។




អតិថិជន អេ អឹម ខេ ប្រើប្រាស់ប្រាក់កម្ចី សម្រាប់គោលបំណងផ្សេងៗគ្នា។ ការចង្អុលបង្ហាញខាងក្រោមគឺជាការប្រើប្រាស់ជាបឋម។




អតិថិជនភាគច្រើនបំផុត តាមរបាយការណ៍បានឲ្យដឹងថា មានការប្រសើរឡើង ស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេជាង ១២ ខែចុងក្រោយ (៥៥%) ចំណែកឯ ១៣% មានស្ថានភាពអាក្រក់ជាងមុន និង ៣២% មានស្ថានភាពស្ថិតនៅដដែល។




ក្នុងកំឡុងឆ្នាំ ២០១២ អេ អឹម ខេ នឹងបន្តអនុវត្តន៍ការសិក្សាពីបម្លាស់ប្តូរ និងការជះឥទ្ធិពល ចំពោះជីវភាពរស់នៅក្នុងកំឡុងពេលដែលពួកគេមានទំនាក់ទំនងជាមួយ អេ អឹម ខេ។ ដើម្បីបង្កើតនូវការស្ទាបស្ទង់នេះ អេ អឹម ខេ បានសម្ភាសន៍អតិថិជនគំរូប៉ាន់ចំនួន ៨២៥ នាក់ នៅឆ្នាំ ២០០៦ និង ២០០៧ ហើយបានសម្ភាសន៍គំរូប៉ាន់ម្តងទៀតចំនួន ៦៩១ នាក់នៅឆ្នាំ ២០០៨។ ក្នុងកំឡុងឆ្នាំ ២០១២ ជាថ្មីម្តងទៀត អេ អឹម ខេ សម្ភាសន៍ក្រុមគ្រួសារទាំងនេះ ដោយផ្តោតទៅលើ ចំណូលចំណាយទ្រព្យសម្បត្តិ។ល។ យើងនឹងវាស់ស្ទង់នូវការផ្លាស់ប្តូរតាំងពីការសម្ភាសន៍មុនៗក្នុងគោលបំណងកំណត់ឃើញតើមានការផ្លាស់ប្តូរខ្លាំងបែបណា ដែលអាចចូលរួមចំណែកចំពោះការប្រើសេវាហិរញ្ញវត្ថុ។ ក្នុងពេលដែលរួមចំណែកលើឥទ្ធិពលចំពោះការអន្តរាគមន៍ជាពិសេសណាមួយ គឺជាអំណះអំណាងមួយដែលស្មុគស្មាញបំផុត យើងជឿជាក់ថាវាជាផ្នែកមួយដ៏សំខាន់ នៃការឈានទៅដល់អតិថិជន។ ការស្រាវជ្រាវដ៏សំខាន់ និងការគ្រប់គ្រងពេលវេលានឹងត្រូវប្រឹងប្រែងបំផុតចំពោះការសិក្សានៃការផ្លាស់ប្តូរនេះក្នុងឆ្នាំ ២០១២។



# ដំណើរការគ្រប់គ្រងការងារសង្គម



របាយការណ៍ ២០១១

បុគ្គលិក អេ អឹម ខេ ទំលាក់ទុនកម្ចីជាក្រុមឲ្យអតិថិជននៅខេត្តសៀមរាប: ធ្នូ ២០១១

អេ អឹម ខេ ជាគ្រឹះស្ថានដែលតម្រង់ទិសទៅរកសង្គម និងមានការប្តេជ្ញាចំពោះបេសកកម្មរបស់ខ្លួន ដោយជួយប្រជាពលរដ្ឋក្រីក្រភាគច្រើនធ្វើឲ្យជីវភាពពួកគេមានជីវភាពប្រសើរ តាមរយៈការផ្តល់សេវាមីក្រូហិរញ្ញវត្ថុសមស្រប និងបិតថេរ។ អេ អឹម ខេ ជាគ្រឹះស្ថានដែលឈរលើមូលដ្ឋាននៃការធ្វើឲ្យមានតុល្យភាពរវាងផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ និងសង្គម។ នៅពេលដែលប្រព័ន្ធ និងឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុបានបង្កើតឡើងត្រឹមត្រូវហើយនោះ អេ អឹម ខេ ជាគ្រឹះស្ថានឈានមុខគេក្នុងវិស័យគ្រប់គ្រងការងារសង្គម។ ការប្តេជ្ញាចិត្តរបស់ អេ អឹម ខេ ក្នុងការងារសង្គម ត្រូវបានកត់ត្រាទុកនៅទូទាំងអង្គភាព ទាំងកម្រិតគ្រប់គ្រង / បុគ្គលិក និងកម្រិតក្រុមប្រឹក្សា / ថ្នាក់ដឹកនាំ។ ក្នុងឆ្នាំ ២០១១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាណូ Fondazione Giordano Dell'Amore បានទទួលស្គាល់ អេ អឹម ខេ ចំពោះការច្នៃប្រឌិតរបស់ អេ អឹម ខេ ដោយផ្តល់ជូននូវប័ណ្ណសរសើរចំពោះការអនុវត្តន៍ដ៏វិសេសវិសាលលំដាប់អន្តរជាតិរបស់ខ្លួន។

## កម្រិតគ្រប់គ្រង

នាយកដ្ឋានស្រាវជ្រាវ អេ អឹម ខេ បានដឹកនាំ និងត្រួតពិនិត្យមើលការអនុវត្តន៍ការងារសង្គមក្នុង អេ អឹម ខេ។ នាយកដ្ឋាននេះធ្វើការស្រាវជ្រាវទាំងផ្នែកសង្គម និងទីផ្សារ ដើម្បីស្វែងយល់ពីបញ្ហា ប្រឈមមុខនានារវាងអតិថិជនជាមួយនឹងបុគ្គលិក អេ អឹម ខេ។ នាយកដ្ឋានស្រាវជ្រាវធ្វើការសហការជាមួយនាយកដ្ឋានផ្សេងៗទៀតដូចជានាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានធនធានមនុស្ស នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងនាយកដ្ឋានហិរញ្ញវត្ថុជាដើម ក្នុងការធ្វើឲ្យប្រាកដថា មាត្រដ្ឋាន និងការគ្រប់ការងារសង្គមត្រូវបានប្រតិបត្តិប្រកបដោយប្រសិទ្ធភាព។

## កម្រិតក្រុមប្រឹក្សាភិបាល

លទ្ធផលស្រាវជ្រាវត្រូវបានរាយការណ៍ទៅគណ:គ្រប់គ្រង អេ អឹម ខេ និងគណ:កម្មការការងារសង្គម។ បន្ទាប់មកគណ:កម្មការការងារសង្គម ផ្តល់យោបល់ទៅក្រុមប្រឹក្សាភិបាលពីលទ្ធផល និងពិភាក្សារបកគំហើញដែលទាក់ទងនឹងយុទ្ធសាស្រ្តអាជីវកម្ម។ គោលបំណងដែលធ្វើដូច្នេះគឺផ្តល់ឲ្យក្រុមប្រឹក្សាភិបាលនូវតុល្យភាពក្នុងការប្រមើមើលចំពោះការអនុវត្តន៍ទូទៅក្នុងគ្រឹះស្ថាន ដើម្បីឲ្យការសម្រេចចិត្តក្នុងការគ្រប់គ្រងស៊ីសង្វាក់គ្នាទៅនឹងគោលបំណងទាំងពីររបស់គ្រឹះស្ថាន គឺទាំងផ្នែកសង្គម និងហិរញ្ញវត្ថុ។

## ដំណើរការគ្រប់គ្រងការងារសង្គមក្នុង អេ អឹម ខេ

ដើម្បីឲ្យការគ្រប់គ្រងការងារសង្គមដំណើរការទៅបាន អេ អឹម ខេ បានបង្កើតគម្រោងនៃការគ្រប់គ្រងការងារសង្គម ដែលបានដាក់ទិសបេសកកម្ម អេ អឹម ខេ ទៅក្នុងគោលបំណងយុទ្ធសាស្រ្ត ហើយបានបង្កើតនូវយន្តការអនុវត្តន៍សំខាន់ៗ សម្រាប់គោលបំណងនីមួយៗ។ គំនូសតាងគោលការណ៍គ្រប់គ្រងការងារសង្គមត្រូវបានបង្ហាញនៅទំព័របន្ទាប់។

## គំនូសតាងបង្ហាញពីយុទ្ធសាស្ត្របេសកកម្មរបស់ អេ អឹម ខេ

**ទស្សនវិស័យ:** ទស្សនវិស័យរយៈពេលវែងរបស់ អេ អឹម ខេ គឺដើម្បី សង្គមកម្ពុជា ដែលប្រជាពលរដ្ឋទាំងឡាយមានឱកាសគ្រប់គ្រាន់ និងស្មើភាពគ្នាក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គមដើម្បីធ្វើឲ្យប្រសើរ ឡើងនូវជីវភាពរស់នៅរបស់ពួកគេហើយអាចជួយជាវិភាគទាន យ៉ាងមានប្រយោជន៍ចំពោះការអភិវឌ្ឍន៍ប្រទេសជាតិ។

**បេសកកម្ម:** ជួយដល់ប្រជាពលរដ្ឋក្រីក្រភាគច្រើន ក្នុងគោលបំណងជួយធ្វើឲ្យប្រសើឡើងនូវជីវភាពរស់នៅរបស់ពួកគេ តាមរយៈការផ្តល់សេវាមីក្រូហិរញ្ញវត្ថុ សមស្រប និងបិតថេរ។

**ចំនុចសំខាន់នៃទិសដៅ / គុណតម្លៃ**

- អេ អឹម ខេ ផ្តល់ជូននូវសេវាមីក្រូហិរញ្ញវត្ថុទៅដល់ប្រជាជនក្រីក្រនៅកម្ពុជា ដោយគោរពតាមវិន័យហិរញ្ញវត្ថុនៅ គ្រប់លំដាប់ថ្នាក់។
- អេ អឹម ខេ ប្តេជ្ញាបើកចំហ និងមានតម្លាភាពចំពោះការគ្រប់គ្រង និងប្រតិបត្តិការ។
- អេ អឹម ខេ ប្តេជ្ញាបង្កើតដំណើរការ/សេវាកម្ម ព្រមទាំងទទួលយកអាកប្បកិរិយា និងគំរូមាត្រដ្ឋានដែលធានាការគ្រប់គ្រងសង្គម រួមមានការការពារអតិថិជន។
- អេ អឹម ខេ ជាគ្រឹះស្ថានរៀនសូត្រ ដែលចែករំលែកព័ត៌មានសមស្របដើម្បីរួមចំណែកក្នុងការកសាងសមត្ថភាពបុគ្គលិក បណ្តុះបណ្តាល និងកែលម្អ គោលការណ៍ និងប្រព័ន្ធ។

**ក្រុមអនុវត្តន៍ក្នុងកិច្ចការពារអតិថិជន**

| បេសកកម្ម/សមាសធាតុគុណតម្លៃ | ចំនួនភាគច្រើន | ប្រជាជនក្រីក្រ | ធ្វើឲ្យមានភាពប្រសើរឡើងនូវ ជីវភាពរស់នៅ | សេវាមីក្រូហិរញ្ញវត្ថុ សមស្រប និងបិតថេរ | តម្លាភាព | ទំនួលខុសត្រូវរបស់បុគ្គលិក | ទំនួលខុសត្រូវផ្នែកសង្គមផ្សេងៗទៀត | ការគាំពារអតិថិជន |
|---|---|---|---|---|---|---|---|---|
| គោលបំណងយុទ្ធសាស្ត្រ | អេ អឹម ខេ ជាគ្រឹះស្ថាននាំមុខគេនៅកម្ពុជាផ្នែកចំនួនអតិថិជនពីចំណែកទីផ្សារក្រីក្របំផុត | អតិថិជនថ្មីក្រីក្រជាងអ្នកដែលមិនមែនជាអតិថិជន | ចំណូលនិងទ្រព្យសម្បត្តិអតិថិជន អេ អឹម ខេ កើនហើយភាពងាយរងគ្រោះថយចុះ | ផលិតផលចម្រុះនឹងត្រូវវាយតម្លៃដើម្បីធានាថាវាចូលដល់ជនក្រីក្រជាពិសេសសម្រាប់ចំណែកទីផ្សារក្រីក្របំផុត | អេ អឹម ខេ នឹងព្យាយាមកំណត់តម្លៃប្រកបដោយទទួលខុសត្រូវ និងផ្តល់ព័ត៌មានច្បាស់លាស់គ្រប់គ្រាន់ទាន់ពេលវេលា សម្រាប់ឲ្យអតិថិជនសម្រេចចិត្ត | អេ អឹម ខេនឹងព្យាយាមផ្តល់ឱកាសការងាររយៈពេលវែងដល់បុគ្គលិកទាំងអស់ | អេ អឹម ខេ ព្យាយាមធ្វើជាអ្នកស្ថាបនាក្នុងសង្គមកម្ពុជា | អេ អឹម ខេ នឹងអនុវត្តតាមយ៉ាងខ្ជាប់ខ្ជួនក្រុមអនុវត្តន៍ក្នុងកិច្ចការពារអតិថិជន |
| ប្រភេទវាស់វែងការអនុវត្តន៍ | ទំហំនៃការជ្រៀតចូល | ជម្រៅនៃការជ្រៀតចូល | ប្រសិទ្ធភាពបម្រែបម្រួល | ផលិតផលសមស្រប | តម្លាភាព និងការកំណត់តម្លៃប្រកបដោយទំនួលខុសត្រូវ | ការពេញចិត្តរបស់បុគ្គលិក | ភាពជាអ្នកដឹកនាំនៅក្នុងវិស័យ និងការទទួខុសត្រូវសង្គមរួមផ្សេងៗទៀត | គោលការណ៍ការពារអតិថិជន |
| ចំនុចសំខាន់ៗនៃការអនុវត្តន៍ | • ចំនួនអតិថិជនសរុប<br>• ចំនួនអតិថិជនកម្ចី<br>• ចំនួនអតិថិជនសន្សំ<br>• ចំនួនអតិថិជនផ្ទេរប្រាក់<br>• ចំនួនភូមិ<br>• % ជ្រៀតចូលដល់ភូមិ<br>• %ជ្រៀតចូលដល់លំនៅគ្រួសារ | • %អតិថិជនថ្មីក្រោមបន្ទាត់ភាពក្រីក្រ-ក្រីក្រ បំផុត<br>• %ចំនួនអតិថិជនថ្មីក្រោមបន្ទាត់ក្រីក្រចំណីអាហារ<br>• %អតិថិជនក្រីក្រ ១ & ២ ឯកត្តជន | • ចំនួនផលិតផល/ប្រភេទផលិតផល<br>• អតិថិជនបន្តប្រើផលិតផល (សរុប និងតាមផលិតផល)<br>• %កម្ចី<៣០០ ដុល្លារអាមេរិក<br>• អតិថិជនសកម្ម<br>• %អតិថិជនក្រុមប្តូរទៅឯកត្តជន<br>• %អតិថិជនកម្ចី ដែលមានគណនីសន្សំ | • %អតិថិជនចាស់ដែលមានជីវភាពប្រសើរឡើង<br>• %អតិថិជនក្រីក្រដែលមានជីវភាពកើនឡើង<br>• អត្រាពិន្ទុសុខុមាលភាពប្រសើរឡើង(អតិថិជន និងមិនមែនអតិថិជន) | • ពិន្ទុការពេញចិត្តអតិថិជន<br>• #ការត្អូញត្អែរនៃអតិថិជន<br>• ការបើកចំហលើផលិតផល និងដំណើរការ<br>• មាត្រដ្ឋាននៃតម្លៃ<br>• ការកំណត់តម្លៃប្រកបដោយទទូលខុសត្រូវ និងប្រកួតប្រជែង | • ការពេញចិត្តរបស់បុគ្គលិក<br>• ការពេញចិត្តរបស់បុគ្គលិកភេទស្រី<br>• % បុគ្គលិកភេទស្រី<br>• % បុគ្គលិកភេទស្រីក្នុងគណៈគ្រប់គ្រង<br>• អត្រាលាលែងការងាដែលមានគណនីសន្សំ<br>• រយៈពេលបម្រើការងារជាមធ្យម | • សមាជិកក្រុមប្រឹក្សាភិបាលសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>• កម្រិតនៃការចូលរួមក្នុងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា<br>• ការិយាល័យឥណទាន<br>• ភាពជាអ្នកដឹកនាំផ្តួចផ្តើមផ្នែកមីក្រូហិរញ្ញវត្ថុ<br>• គម្រោងដែលជាប់ពាក់ព័ន្ធក្នុងសមាគម<br>• ការចូលរួមផ្តួចផ្តើមសង្គមផ្សេងៗទៀត | • % អ្នកខ្ចីប្រាក់ពហុកម្ចី<br>• % អ្នកខ្ចីពីប្រភពក្រៅផ្លូវការ<br>• % អតិថិជនដែលមានបញ្ហាក្នុងការបង់សងត្រឡប់ ឬបំណុលវណ្តក (ODI)<br>• ការពេញចិត្តរបស់អតិថិជន |

# ដំណើរការគ្រប់គ្រងការងារសង្គម

ដើម្បីគាំទ្រគម្រោងនេះ ជារៀងរាល់ឆ្នាំនាយកដ្ឋានស្រាវជ្រាវបានប្រមូល និងវិភាគទិន្នន័យពីអតិថិជន អ្នកដែលមិនមែនជាអតិថិជន និងប្រភពព័ត៌មានផ្សេងៗទៀត ដើម្បីសរសេរជារបាយការណ៍ជាបន្តបន្ទាប់ (របាយការណ៍ស្រាវជ្រាវសំខាន់ៗ)។ ខាងក្រោមនេះគឺជាគំរូនៃរបាយការណ៍ ដែលផ្តោតទៅលើផ្នែកសង្គម និងទីផ្សារៈ

### ភាពស៊ីជម្រៅ

- របាយការណ៍កម្រងឯកសារអតិថិជន
- របាយការណ៍ភាពស៊ីជម្រៅ

### ភាពគ្រប់គ្រាន់ផលិតផល

- របាយការណ៍អតិថិជនចាកចេញ
- របាយការណ៍អំពីការពេញចិត្តរបស់អតិថិជន
- របាយការណ៍អំពីមតិកែលម្អចំពោះផលិតផលថ្មី
- របាយការណ៍វាយតម្លៃទៅលើផលិតផលដាក់សាកល្បង

### តម្លាភាព

- របាយការណ៍ការយល់ដឹងរបស់អតិថិជន
- របាយការណ៍គូប្រកួតប្រជែង
- របាយការណ៍ស្តង់ដារការងារសង្គម (The MIX)

### ការការពារអតិថិជន

- របាយការណ៍ពហុកម្ចី
- របាយការណ៍តវ៉ារបស់អតិថិជន

### ការពេញចិត្តរបស់បុគ្គលិក

- របាយការណ៍ការពេញចិត្តរបស់បុគ្គលិក
- របាយការណ៍ការចាកចេញរបស់បុគ្គលិក

### ប្រសិទ្ធភាពនៃបម្រែបម្រួល

- របាយការណ៍ប្រសិទ្ធភាពនៃបម្រែបម្រួល របាយការណ៍ និងការអង្កេតផ្សេងៗ

ការស្រាវជ្រាវ Ad-HOC ផ្សេងៗទៀត ត្រូវបានធ្វើឡើងដោយអាស្រ័យទៅលើការស្នើពីគណៈគ្រប់គ្រង គណៈកម្មាធិការការងារសង្គម និងក្រុមប្រឹក្សាភិបាល។



អតិថិជនគោលដៅ អេ អ៊ឹម ខេ ប្រមូលផលស្រូវក្នុងខេត្តតាកែវៈ កក្កដា ២០១១

## ភាពស៊ីជម្រៅ

នៅក្នុងឆ្នាំ ២០១១ នាយកដ្ឋានស្រាវជ្រាវ អេ អឹម ខេ បានជួបសម្ភាសន៍ជាមួយគ្រួសារចំនួន ១.៦៦៥។ ខាងក្រោមនេះជាចំនុចសំខាន់ៗ ដែលបានរកឃើញពីការសម្ភាសន៍:

ជាមធ្យមអតិថិជនចូលថ្មីរបស់ អេ អឹម ខេ មានលក្ខណៈក្រីក្រជាងអ្នកដែលជាមិនមែនអតិថិជន។ នៅក្នុងឆ្នាំ ២០១១ មានអតិថិជនចំនួន ៥០% ស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្រចំណីអាហារ (ការចំណាយលើម្ហូបប្រចាំថ្ងៃគឺ ២.៥១២ រៀល) ចំណែកឯអ្នកសម្ភាសន៍ដែលមិនមែនជា អតិថិជនមានតែ ៣២% ប៉ុណ្ណោះ។




ក្នុងខណៈពេលដែលកម្រិតភាពក្រីក្រដាច់ខាត បានទទួលការចាប់អារម្មណ៍តាមរយៈការប្រៀបធៀប អេ អឹម ខេ ពឹងផ្អែកជាសំខាន់ទៅលើការវាស់ភាពក្រីក្រតាមការប្រៀបធៀបក្នុងចំណោមអតិថិជនថ្មី ដើម្បីធានាថា អេ អឹម ខេ បន្តទិសដៅបម្រើអ្នកក្រីក្រ។ ក្រុមគ្រួសារនីមួយៗ ត្រូវបានគេកំណត់ពិន្ទុសុខុមាលភាពដែលពិន្ទុខ្ពស់បង្ហាញពីភាពធូធារក្នុងគ្រួសារ។ រាល់អ្នកដែលមិនមែនជាអតិថិជន ត្រូវបានគេបែងចែកជាបួនក្រុមស្មើៗគ្នា ដែលក្រុមទាំងនេះគឺត្រូវគេយកទៅប្រៀបធៀប ជាមួយពិន្ទុសុខុមាលភាពអតិថិជន អេ អឹម ខេ ដែលចូលថ្មី។ គំរូតាងខាងក្រោមបង្ហាញថាក្នុង អេ អឹម ខេ បានបំរើដល់គ្រួសារក្រីក្របំផុតមានចំនួនតិចជាង បើប្រៀបធៀបនឹងអ្នកដែលមិនមែនជាអតិថិជន។ ទោះជាយ៉ាងនេះក្តី អេ អឹម ខេ បានបម្រើដល់អតិថិជនដែលមានជីវភាពក្រីក្រ និងជីវភាពមធ្យមជាងអ្នកដែលមិនមែនជាអតិថិជន ហើយអ្វីដែលគួឲ្យកត់សម្គាល់នោះគឺថា អតិថិជនដែលមានជីវភាពធូរធាមានចំនួនតិចជាងអ្នកដែលមិនមែនជាអតិជន។ កត្តាខាងលើនេះបញ្ជាក់ឲ្យឃើញថា ជាធម្យមអតិថិជនថ្មីរបស់ អេ អឹម ខេ ក្នុងឆ្នាំ ២០១១ មានជីវភាពក្រីក្រជាងអ្នកដែលមិនមែនជាអតិថិជន។




**កំណត់សម្គាល់:** អ្នកដែលមិនមែនជាអតិថិជន (ក្រុមប្រៀបធៀប) ត្រូវបានគេជ្រើសរើស ជាគំរូសំណាកជារៀងរាល់ឆ្នាំពីថ្នាក់ស្រុក និងខេត្ត ដែល អេ អឹម ខេ បានប្រតិបត្តិការ ហេតុដូច្នេះក្នុងកំឡុងពេលប្រតិបត្តិការឆ្នាំដំបូងៗ អត្រាភាពក្រីក្ររបស់អ្នកដែលមិនមែនជាអតិថិជនមានភាគរយខ្ពស់នៅក្នុងតំបន់ទាំងនោះ។ នៅពេលដែល អេ អឹម ខេ គ្របដណ្តប់ ២៤ ខេត្ត/រាជធានីស្ថិតិអ្នកដែលមិនមែនជាអតិថិជនបានចាប់ផ្តើមឆ្លុះបញ្ចាំងយ៉ាងទូលំទូលាយទៅលើកត្តានៃភាពក្រីក្រទាំងមូលក្នុងប្រទេសកម្ពុជា។

## ភាពសមស្របនៃផលិតផល

ផ្អែកលើយុទ្ធសាស្ត្រនៃការពង្រីកខ្លួន ដើម្បីក្លាយជាអ្នកផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុដ៏ធំមួយ អេ អឹម ខេ បានចាប់ផ្តើមពង្រីកការផ្តល់ឲ្យនូវសេវាកម្មរបស់ខ្លួនក្នុងឆ្នាំ ២០១១។ ក្នុងដំណាក់កាលបម្រែបម្រួលនេះគណៈគ្រប់គ្រងធ្វើការសម្រេចចិត្តដោយផ្អែកទៅលើការស្រាវជ្រាវផ្អែកសង្គម និងទីផ្សារដើម្បីបង្កើតនូវផលិតផលថ្មីសមស្របតាមតម្រូវការទីផ្សារ និងជំរុញគោរពតាមបេសកកម្មរបស់ អេ អឹម ខេ។ គំនូសតាងខាងក្រោមបង្ហាញថា អតិថិជនដែលទទួលកម្ចីមានការពេញចិត្តជាមួយសេវាកម្ម អេ អឹម ខេ ដែលការពេញចិត្តរបស់ពួកគាត់មាន កម្រិតកើនឡើងគួរឲ្យកត់សម្គាល់ក្នុងឆ្នាំ ២០១១។




ជាទូទៅទាំងអតិថិជនថ្មី និងចាស់មានការពេញចិត្តជាមួយ អេ អឹម ខេ។ មូលហេតុដែលពួកគាត់មានការពេញចិត្តនេះគឺពួកគាត់បានលើកឡើងជារឿយៗថា "សេវាហិរញ្ញវត្ថុនៅជិតបំផុត" "អត្រាការប្រាក់ទាប" និង"ភាពងាយស្រួលក្នុងការទទួលយកកម្ចី"។ នេះបញ្ជាក់ឲ្យឃើញថាអតិថិជនមានភក្តីភាពជាមួយ អេ អឹម ខេ ដែលយើងអាចឃើញពីភាពប្រសើរឡើងនូវអត្រានៃការរក្សាអតិថិជន ក្នុងចំណោមផលិតផលភាគច្រើន។

## តម្លាភាព និងការយល់ដឹងរបស់អតិថិជន

តាមរយៈការស្រាវជ្រាវបានបង្ហាញឲ្យឃើញថាអតិថិជន អេ អឹម ខេ ភាគច្រើនបានយល់ពីសិទ្ធិ និងទំនួលខុសត្រូវរបស់ពួកគេ។ ឧទាហរណ៍ មានអតិថិជនចំនួន ៦៩% បានដឹងពីចំនួនប្រាក់ពិតប្រាកដ ដែលពួកគេបានបង់ពីខែមុន ប៉ុន្តែមានអតិថិជនចំនួន ១៧% គ្រាន់តែដឹងពីចំនួនប្រហាក់ប្រហែល។ លើសពីនេះទៀត ៧៦% នៃអតិថិជនអាចរកឃើញនូវចំនួនទឹកប្រាក់ ដែលពួកគាត់ជំពាក់នៅក្នុងសៀវភៅកម្ចី។

## ការការពារអតិថិជន - ការតវ៉ារបស់អតិថិជន

អេ អឹម ខេ មានប្រព័ន្ធទូរស័ព្ទចំនួនបីខ្សែសម្រាប់អតិថិជនធ្វើការហៅចូលដើម្បីរៀបរាប់ពីការមិនពេញចិត្តរបស់ពួកគេពាក់ព័ន្ធទៅនឹងសេវាកម្ម ផលិតផល និងបញ្ហាផ្សេងៗទៀតជាមួយ អេ អឹម ខេ។ ក្នុងឆ្នាំ ២០១១ នេះ អេ អឹម ខេ បានទទួលការហៅចូលចំនួន ៥២២ ដង។ គោលបំណងនៃការដាក់ឲ្យមានការហៅចូលនេះ គឺដើម្បីជាដំណោះស្រាយមួយ ដែលធានាឲ្យការតវ៉ាទាំងឡាយរបស់អតិថិជនមានការដោះស្រាយ ហើយភាគច្រើននៃការហៅចូលដើម្បីតវ៉ារបស់អតិថិជនក្នុងឆ្នាំ ២០១១ នេះគឺបញ្ហាទាក់ទងជាមួយការស្នើសុំកម្ចី ពេលនៃការណាត់ជួបអតិថិជន និងបញ្ហារដ្ឋបាលផ្សេងទៀត (៩១%)។ ការតវ៉ាជាទូទៅ គឺពាក់ព័ន្ធជាមួយការខកខានក្នុងការណាត់ជួប និងការពន្យា នៃការដកវិញនូវទ្រព្យធានារបស់អតិថិជន។

## ការការពារអតិថិជន - របាយការណ៍ពហុកម្ចី

តាមរយៈការរកឃើញក្នុងការស្រាវជ្រាវបានបង្ហាញថា អតិថិជនដែលមានពហុកម្ចីជួបប្រទះការលំបាកក្នុងការបង់សងត្រឡប់វិញជាងអតិថិជនដែលមានកម្ចីតែមួយពី អេ អឹម ខេ (៤% ទល់នឹង ១%)។ ដោយផ្អែកលើគោលការណ៍ការពារអតិថិជន អេ អឹម ខេ ពិនិត្យមើលអតិថិជនយ៉ាងល្អិតល្អន់ដើម្បីជៀសវាងការជំពាក់បំណុលច្រើន និងធានាគុណភាពនៃកម្ចី។ ជាលទ្ធផល អេ អឹម ខេ បានឃើញនូវកម្រិតថយចុះ នៃអតិថិជនថ្មី ដែលមានពហុកម្ចីពី ៣១% ក្នុងឆ្នាំ ២០០៩ ទៅ ២១% ក្នុងឆ្នាំ ២០១០ និង ២០១១។

កម្ចីជាក្រុមៈពហុកម្ចីនិងបំណុលលើសលប់
(ពហុកចម្ចី + ការជួបបញ្ហានៃការសង)




ក្នុងចំណោមអតិថិជន អេ អឹម ខេ ទាំងអស់មានអតិថិជនចំនួន ១៦% កំពុងទទួលកម្ចីពីប្រភពផ្លូវការ (មីក្រូហិរញ្ញវត្ថុ ធនាគារពាណិជ្ជ។ល។) រីឯអតិថិជនចំនួន ៥% កំពុងទទួលកម្ចីពីប្រភពក្រៅផ្លូវការរួមមាន ញាតិសន្តាន អ្នកចងការប្រាក់។ល។ ជាទូទៅអតិថិជន អេ អឹម ខេ ទទួលកម្ចីពី អេ អឹម ខេ មុនខ្ចីពីប្រភពដទៃ ហើយបញ្ហាពហុកម្ចីមានភាពស្រដៀងគ្នាដែរក្នុងចំណោមអតិថិជនចាស់ និងអតិថិជនថ្មី និងក្នុងចំណោមផលិតផលផ្សេងៗរបស់ អេ អឹម ខេ។ អេ អឹម ខេ រំពឹងថាការបង្កើតការិយាល័យឥណទាន ក្នុងឆ្នាំ ២០១២ នឹងជួយឲ្យមានភាពប្រសើរឡើងនូវការកំណត់អត្តសញ្ញាណនៃអតិថិជនដែលមានកម្ចីបន្ថែម ដែលការនេះធ្វើឲ្យហានិភ័យជាមួយនឹងពហុកម្ចីនឹងមានការថយចុះ។



របាយការណ៍ ២០១១

ផលិតផលរបស់ អេ អឹម ខេ ត្រូវបានបង្កើតឡើងដើម្បីបំពេញសេចក្តីត្រូវការហិរញ្ញវត្ថុរបស់អតិថិជនខ្លួនទៅតាម ជីវភាពរស់នៅ និងបំលាស់ប្តូរប្រភពចំណូលរបស់ពួកគេអស់រយៈពេលជាយូរមកហើយ។ ជាលទ្ធផល អេ អឹម ខេ ផ្តល់ផលិតផលសន្សំ និងកម្ចីជាច្រើនប្រភេទទៅតាមតម្រូវការជាក់លាក់របស់អតិថិជន។ អតិថិជន អេ អឹម ខេ ជាទូទៅ ចូលរួមជាអតិថិជនធនាគារភូមិដែលអាចទទួលប្រាក់កម្ចីខ្នាតតូចតាមរយៈផលិតផលកម្ចីក្រុមធានា។ ដោយអាស្រ័យ ទៅតាមលំហូរចំណូល អតិថិជនអាចជ្រើសរើសរវាងកម្ចីសងចុងវគ្គ និងបង់រំលស់។ អតថិជិនដែលបង់សងត្រឡប់ បានទាន់ពេលវេលាដល់ អេ អឹម ខេ ទទួលបានទំហំកម្ចីច្រើនជាងមុនចំពោះប្រាក់កម្ចីបន្ទាប់។ អតិថិជនទាំងនេះអាចប្រើប្រាស់ផលិតផលកម្ចីបណ្តាក់ ដែលមានលក្ខណៈងាយស្រួល និងកម្ចីសង្គ្រោះបន្ទាន់ប្រសិនបើត្រូវការ។

អតិថិជន ដែលមានបំណងខ្ចីប្រាក់ដែលមានទំហំធំជាង អាចទទួលបានប្រយោជន៍ពីផលិតផលកម្ចីឯកត្តជនច្រើនប្រភេទ។ ដោយសារទំហំកម្ចី ព្រមទាំងហានិភ័យដែលពាក់ព័ន្ធទាំងឡាយកើតមានឡើងច្រើនជាង កម្ចីទាំងនេះត្រូវមានទ្រព្យបញ្ចាំ និងអ្នកធានា។ សម្រាប់អ្នករស់នៅតាមជាយរាជធានី អេ អឹម ខេ ផ្តល់នូវផលិតផលកម្ចីងាយស្រួលដែលមានលក្ខណៈខុសប្លែកបន្តិចពីប្រភេទឯកត្តជន ប៉ុន្តែបន្ធូរបន្ថយលក្ខខណ្ឌទីលំនៅ ទ្រព្យបញ្ចាំ និងអ្នកធានា។ ទំហំកម្ចីអតិបរមា រយៈពេល និងលក្ខណៈពិសេសរបស់ផលិតផលកម្ចីឯកត្តជនទាំងនេះ ត្រូវបានបង្កើតឡើងដោយឆ្លើយតបទៅតាមសេចក្តីត្រូវការជាក់លាក់សមស្របរបស់អតិថិជន។

អេ អឹម ខេ បង្កើតគ្រួសារផលិតផលសន្សំដែលមានលក្ខណៈងាយស្រួលផងដែរ។ អតិថិជនប្រើប្រាស់គណនីងាយស្រួល គណនីមានកាលកំណត់ ព្រមទាំងផលិតផលសន្សំផែនការ ដែលអនុញ្ញាតឲ្យពួកគេ អាចសន្សំប្រាក់សម្រាប់អនាគត សម្រាប់ទិញរបស់របរជាក់លាក់ ការសិក្សា អាពាហ៍ពិពាហ៍ជម្ងឺ និងករណីបន្ទាន់ផ្សេងៗទៀត។

## នីតិវិធីក្រុមធានា

អេ អឹម ខេ ប្រើប្រាស់វិធីសាស្ត្រកម្ចីក្រុមធានា ដើម្បីគ្រប់គ្រងកម្ចីជាក្រុមរបស់ខ្លួន។ ដំណើរការនេះចាប់ផ្តើមពីការជ្រើសរើសអតិថិជនដែលមានសក្តានុពលដោយខ្លួនឯង ដើម្បីបង្កើតជាក្រុមសាមគ្គីដែលមានសមាជិកពី ៤ ទៅ ៦ នាក់។ បន្ទាប់មកក្រុមធានាទាំងនេះ ត្រូវបង្កើតឲ្យទៅជាធនាគារភូមិដែលរួមមានពី ៤ ទៅ ១២ ក្រុម (ឬពី ២០ ទៅ ៦០ អតថិជិន)។ ជាផ្នែកមួយនៃក្រុមធានាដែលជ្រើសរើសដោយខ្លួនឯង បង្ហាញឲ្យឃើញ អ្នកភូមិចាប់ពី ៣ ទៅ ៥ នាក់ ផ្សេងទៀតមានទំនុកចិត្តចំពោះអ្នកស្នើសុំប្រាក់កម្ចី អនុញ្ញាតិឲ្យចូលរួមក្រុមរបស់ពួកគេ។ គ្រប់ប្រាក់កម្ចីទាំងអស់ត្រូវបានធានាដោយសមាជិកក្រុមនីមួយៗ។ ប្រាក់កម្ចីត្រូវបានវាយតម្លៃ និងអនុម័តដោយមន្ត្រីអតិថិជន អេ អឹម ខេ និង ប្រធានធនាគារភូមិ មុននឹងទម្លាក់ទុន។ នៅពេលទម្លាក់ទុន ត្រូវមានវត្តមានសមាជិកក្រុមទាំងអស់ព្រមទាំងប្រធានតំបន់/ប្រធានសាខា។

ដើម្បីក្លាយជាសមាជិកក្រុម អតិថិជនសក្តានុពល ត្រូវបំពេញនូវលក្ខខណ្ឌទាំងឡាយដូចខាងក្រោម:

- មានឆន្ទៈចង់ក្លាយជាសមាជិកក្រុមធានា និងផ្តល់ការធានាផ្នែកស្មារតីចំពោះសមាជិកផ្សេងទៀត
- មានយ៉ាងហោចណាស់សកម្មភាពសេដ្ឋកិច្ចមួយនៅក្នុងគ្រួសាររបស់ពួកគេ
- មិនមានជាប់ពាក់ព័ន្ធជាមួយប្រាក់កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្មវិធីនានា ធនាគារ ឬ អ្នកផ្តល់ប្រាក់កម្ចីផ្សេងៗទៀតឡើយ
- ក្រុមទាំងអស់មិនអាចមានសមាជិក២ ឬច្រើននាក់មកពីគ្រួសារតែមួយឡើយ។

មិនមានលក្ខខណ្ឌផ្នែក Gender ទេ។ ស្ត្រីត្រូវបានលើកទឹកចិត្តឲ្យចូលរួម។ នាពេលបច្ចុប្បន្នអតិថិជនស្ត្រីមានចំនួន៨៧% នៃអតិថិជន អេ អឹម ខេ ទាំងអស់។ ក្រុមនីមួយៗជ្រើសតាំងប្រធានក្រុមទទួលខុសត្រូវ ធានាឲ្យមានការចូលរួមពីសមាជិកក្រុមទាំងអស់នៅពេលប្រជុំ ដោះស្រាយបញ្ហា ព្រមទាំងទំនាក់ទំនងជាមួយប្រធានធនាគារភូមិ មន្ត្រីអតិថិជន និងសមាជិកផ្សេងៗទៀតនៅក្នុងក្រុម។

ប្រធានធនាគារភូមិ គឺជាអ្នកតំណាងការគ្រប់គ្រងរបស់ធនាគារភូមិ។ គាត់ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយសម្ងាត់ពីសមាជិកធនាគារភូមិទាំងអស់ និងត្រូវបានផ្តល់ប្រាក់លើកទឹកចិត្តអាស្រ័យទៅតាមលទ្ធផលរបស់ធនាគារភូមិ។ ប្រធានធនាគារភូមិ ទទួលខុសត្រូវក្នុងការជួយសម្រួលដល់មន្ត្រីអចិជនក្នុងការរៀបចំការប្រជុំ ប្រមូល និងបង់សងត្រឡប់ ផ្តល់យោបល់ដល់មន្ត្រីអតិថិជនពីស្ថានភាពមិនបង់សងត្រឡប់ តាមដានអតិថិជនដែលមានបញ្ហា ដោះស្រាយបញ្ហាសមាជិកភាព ព្រមទាំងធានាឲ្យបាននូវគ្រប់អតិថិជនទាំងអស់ត្រូវបានចុះឈ្មោះទៅតាមលក្ខណៈវិនិច្ឆ័យក្នុងការបង្កើតជាធនាគារភូមិ។

## ផលិតផលកម្ចីជាក្រុម

អេ អឹម ខេ ផ្តល់នូវផលិតផលកម្ចីធនាគារភូមិចំនួន៣ ដែលប្រើប្រាស់វិធីសាស្ត្រខ្ចីប្រាក់ជាក្រុម។ ផលិតផល សងចុងវគ្គធនាគារភូមិ ត្រូវបានបង្កើតឡើងសម្រាប់អតិថិជនដែលមានលំហូរសាច់ប្រាក់តាមរដូវកាល ដែលអនុញ្ញាតិអោយបង់សងប្រាក់ដើមនៅចុងវគ្គ។ អតិថិជនគោលដៅ ដែលជ្រើសរើសយកបង់រំលស់ដោយមានលំហូរសាច់ប្រាក់ទៀងទាត់ ត្រូវបង់ការប្រាក់ និងប្រាក់ដើមជារៀងរាល់ខែ។ ផលិតផលកម្ចីសងបណ្តាក់ធនាគារភូមិផ្តល់ជូនអតិថិជននូវឱកាសតែមួយគត់ក្នុងការខ្ចីមូលនិធិបន្ថែម និងការបង់សងត្រឡប់សមតុល្យដែលនៅសល់ នៅពេលណាមួយបានច្រើនដងក្នុងវគ្គកម្ចីរបស់ពួកគេ ដោយផ្តល់ភាពបត់បែនជាច្រើនសម្រាប់អតិថិជន។ លើសពីនេះទៀត អេ អឹម ខេ ផ្តល់នូវផលិតផលកម្ចីសង្គ្រោះបន្ទាន់សម្រាប់អតិថិជនជាក្រុម និងឯកត្តជន ក្នុងគោលបំណងជួយដោះស្រាយហេតុការណ៍អកុសលដែលបានកើតឡើងជាយថាហេតុ។

កម្ចីជាក្រុមធានា និងសង្គ្រោះបន្ទាន់ មានបរិយាយលម្អិតនៅក្នុងតារាងខាងក្រោម៖

### ផលិតផលកម្ចីជាក្រុមធានា និងសង្គ្រោះបន្ទាន់

| ការបរិយាយ | កម្ចីសងដើមចុងវគ្គ ~ ធនាគារភូមិ | សងរំលស់ ~ ធនាគារភូមិ | កម្ចីបណ្តាក់ ~ ធនាគារភូមិ | កម្ចីសង្គ្រោះបន្ទាន់ * |
|---|---|---|---|---|
| អតិថិជនគោលដៅ | សមាជិកក្រុមដែលមានលំហូរសាច់ប្រាក់តាមរដូវកាល | សមាជិកក្រុមដែលមានលំហូរសាច់ប្រាក់ទៀងទាត់ | សមាជិកក្រុមដែលបានបញ្ចប់វគ្គទី១ | អតិថិជនជាឯកត្តជន ឬក្រុមដែលបានបំពេញយ៉ាងតិច៦ខែ |
| ទំហំកម្ចីអតិបរមា | វគ្គទី១: ៦០០.០០០ រៀល ឬ ៦.០០០ បាត<br>វគ្គទី២: ៨០០.០០០រៀល ឬ ៨.០០០ បាត<br>វគ្គទី៣:១.០០០.០០០រៀល ឬ១០.០០០បាត | ១.០០០.០០០ រៀល ឬ ១០.០០០ បាត | វគ្គទី២: ៨០០.០០០ រៀល ឬ ៨.០០០ បាត<br>វគ្គទី៣: ១.០០០.០០០ រៀល ឬ ១០.០០០ បាត | ៤០០.០០០ រៀល ឬ ៤.០០០ បាត |
| ការធានាលើកម្ចី | ការធានាលើផ្អែកសង្គម – មិនទាមទារវត្ថុធានារូបវន្ត ឬអ្នកធានាឡើយ | | | អ្នកធានាម្នាក់ |
| ប្រភេទរូបិយប័ណ្ណ | ប្រាក់រៀល និងប្រាក់បាតថៃ (នៅខេត្តបន្ទាយមានជ័យ) | | | |
| កាលកំណត់បញ្ចេញប្រាក់កម្ចី | ១ ទៅ ២ សប្តាហ៍បន្ទាប់ ពីចុះហត្ថលេខា ប្រសិនបើគ្មានការផ្លាស់ប្តូរនៅក្នុងពាក្យដាក់ស្នើសុំ | | | ៤ ម៉ោងធ្វើការបន្ទាប់ពីស្នើសុំ |
| រយៈពេលអតិបរមា | ១២ ខែ | | ២៤ ខែ | ១០ ខែ |
| ចំនួនទឹកប្រាក់ និងរបៀបនៃការទូទាត់សង | បង់ការប្រាក់រៀងរាល់ខែ។ ប្រាក់ដើមបង់នៅចុងវគ្គ។ | បង់ការប្រាក់ និងប្រាក់ដើមរៀងរាល់ខែ។ ការប្រាក់គិតទៅតាមប្រាក់ដើម ដែលនៅសល់។ | បង់ការប្រាក់ប្រចាំខែ ដោយគិតលើប្រាក់ដើមដែលបានខ្ចីនៅសល់។ បង់ប្រាក់ដើមនៅចុងវគ្គ ឬមុន។ | បង់ការប្រាក់រៀងរាល់ខែ ដោយគិត លើប្រាក់ដើមដែលនៅសល់។ បង់ប្រាក់ដើមនៅចុងវគ្គ ឬមុន។ |
| អត្រាការប្រាក់ (ប្រចាំខែ) | ៣% | ២,៨% | ៣% | ២,៥% |
| កម្រៃលើការសងយឺត | បង់បន្ថែម ១% ក្នុង១ខែ លើប្រាក់ដើមដែលសងយឺត (គិតចាប់ពីខែដែលការបង់សងត្រឡប់មានការខកខាន) | | | |
| កម្រៃផ្សេងៗ | កម្រៃជើងសារលើកដំបូងចំនួន ០,៥% នៃប្រាក់កម្ចី | | | គ្មាន |

*ផលិតផលនេះ គឺសម្រាប់អតិថិជនជាក្រុម និង ឯកត្តជន។

## ផលិតផលកម្ចីឯកត្តជន

បន្ថែមពីលើកម្ចីជាក្រុម អេ អឹម ខេ ផ្តល់ជូននូវកម្ចីឯកត្តជន ៤ ប្រភេទដល់អតិថិជនរបស់ខ្លួន។ (ផលិតផលកម្ចីបណ្តាក់កសិកម្ម កំពុងតែដាក់សាកល្បង)។ កម្ចីពង្រីកអាជីវកម្មរបស់ អេ អឹម ខេ ត្រូវបង្កើតឡើងសម្រាប់សហគ្រិននៅតាមទីផ្សារជនបទ ដែលមានបំណងពង្រីកអាជីវកម្មដែលកំពុងមាននាពេលបច្ចុប្បន្ន។ ផលិតផលកម្ចីកសិកម្មរបស់ អេ អឹម ខេ គឺសម្រាប់អតិថិជនដែលមានស្រាប់ ហើយត្រូវការដើមទុនសម្រាប់ដំណាំដាំដុះ ការចិញ្ចឹមសត្វ ឬទិញគ្រឿងយន្ត និងឧបករណ៍កសិកម្ម។ ផលិតផលកម្ចីងាយស្រួល មានគោលដៅសម្រាប់អតិថិជនដែលមានចំណូលទាបរស់នៅតាមជាយរាជធានី/ខេត្ត ដែលលទ្ធភាពនៅមានកម្រិតក្នុងការប្រើប្រាស់ប្រាក់កម្ចីផ្លូវការ។

ការបរិយាយលម្អិតរបស់ផលិតផលកម្ចីឯកត្តជន មានបង្ហាញជូននៅក្នុងតារាងខាងក្រោម៖

### កម្ចីឯកត្តជន

| ការបរិយាយ | កម្ចីអាជីវកម្ម | កម្ចីកសិកម្ម | កម្ចីកសិកម្មកបណ្តាក់ ( សាកល្បង ) * | កម្ចីងាយស្រួល |
|---|---|---|---|---|
| អតិថិជនគោលដៅ | អតិថិជនឯកត្តជនដែលមានអាជីវកម្មខ្នាតតូចចង់ពង្រីកមុខរបរ ដែលមានស្រាប់ ឬបង្កើតមុខរបរថ្មី | អតិថិជនឯកត្តជនដែលមានលំហូរសាច់ប្រាក់ទៀងទាត់ពីកសិកម្ម ដំណាំដាំដុះ និងការចិញ្ចឹមសត្វ | អ្នកដែលត្រូវការប្រាក់សំរាប់ធ្វើកសិកម្ម | អ្នករស់នៅតាមជាយរាជធានីដែលមានប្រាក់ចំណូលទាប ហើយមានទីលំនៅអចិន្ត្រៃយ៍យ៉ាងតិច ៦ខែ |
| ទំហំកម្ចីអតិបរមា | ៨.០០០.០០០ រៀល<br>ឬ ៨០.០០០ បាត<br>ឬ ២.០០០ ដុល្លារអាមេរិក | ៦.០០០.០០០ រៀល<br>ឬ ៦០.០០០ បាត<br>ឬ ១.៥០០ ដុល្លារអាមេរិក | រហូតដល់ ៤.០០០.០០០រៀល<br>ឬ ១.០០០ដុល្លារអាមេរិក<br>ឬ ៤០.០០០បាត | ១.០០០.០០០ រៀល<br>ឬ ១០.០០០ បាត<br>ឬ ២៥០ ដុល្លារអាមេរិក |
| ការធានាលើកម្ចី | វត្ថុធានារូបវន្ត<br>និងអ្នកធានាពីរនាក់ | វត្ថុធានារូបវន្ត<br>និងអ្នកធានាមួយនាក់ | វត្ថុធានារូបវន្ត និងអ្នកធានាម្នាក់ | មិនមានអ្នកធានា ប្រសិនបើអតិថិជនមានផ្ទះផ្ទាល់ខ្លួន និងត្រូវមានអ្នកធានាមួយនាក់ប្រសិនបើអតិថិជនជួលផ្ទះរស់នៅសម្រាប់ប្រាក់កម្ចីដែលមានទំហំរហូតដល់១០០ ដុល្លារអាមេរិក ឬ ៤០០.០០០ រៀល អ្នកធានាម្នាក់សម្រាប់ទំហំកម្ចីរហូតដល់ ២៥០ ដុល្លារអាមេរិក ឬ ១.០០០.០០០ រៀល |
| អត្រាការប្រាក់ (ប្រចាំខែ) | ២,២% - ៣% | ២,៤% - ៣% | ២,៤% - ៣% | ២,៣% - ៣% |
| ប្រភេទរូបិយប័ណ្ណ | ប្រាក់រៀល ប្រាក់បាត (នៅខេត្តបន្ទាយមានជ័យ) និងប្រាក់ដុល្លារអាមេរិក | | | |
| កាលកំណត់បញ្ចេញប្រាក់កម្ចី | រយៈពេល៣ថ្ងៃបន្ទាប់ពីចុះហត្ថលេខា ប្រសិនបើគ្មានការផ្លាស់ប្តូរនៅក្នុងពាក្យស្នើសុំ | រយៈពេល៣ថ្ងៃបន្ទាប់ពីចុះហត្ថលេខា ប្រសិនបើគ្មានការផ្លាស់ប្តូរនៅក្នុងពាក្យស្នើសុំ | រយៈពេល៣ថ្ងៃបន្ទាប់ពីចុះហត្ថលេខា ប្រសិនបើគ្មានការផ្លាស់ប្តូរនៅក្នុងពាក្យស្នើសុំ | ពី១ ទៅ ២ សប្តាហ៍បន្ទាប់ពីចុះហត្ថលេខា ប្រសិនបើគ្មានការផ្លាស់ប្តូរនៅក្នុងពាក្យស្នើសុំ |
| រយៈពេលអតិបរមា | ១៨ ខែ | ១២ ខែ | ១២ ខែ | ១២ ខែ |
| ចំនួនទឹកប្រាក់ និងរបៀបនៃការទូទាត់សង | បង់ការប្រាក់ និងប្រាក់ដើមរៀងរាល់ខែ។ការប្រាក់គិតទៅតាមប្រាក់ដើមដែលនៅសល់។ | បង់ការប្រាក់រៀងរាល់ខែ។ បង់ប្រាក់ដើម១០០%នៅចុងវគ្គ ឬនៅពេលណាមួយនៅក្នុងវគ្គ | បង់ការប្រាក់ប្រចាំខែគិតលើប្រាក់ដើមដែលបានខ្ចីនៅសល់។ បង់ប្រាក់ដើមនៅចុងវគ្គ ឬមុន។ | បង់ប្រាក់ដើម និងការប្រាក់រៀងរាល់ខែ ឬរៀងរាល់ពីរសប្តាហ៍ |
| ការពិន័យលើការទូទាត់មុន | គ្មាន | | | |
| កម្រៃលើការសងយឺត | បង់បន្ថែម ១% ក្នុង១ខែ លើប្រាក់ដើមដែលសងយឺត (គិតចាប់ពីខែដែលការបង់សងត្រឡប់មានការខកខាន) | | | |
| កម្រៃផ្សេងៗ | កម្រៃជើងសារលើកដំបូងចំនួន ០,៥% នៃប្រាក់កម្ចី | | | |

* កម្ចីកសិកម្មបណ្តាក់ ដាក់ឲ្យសាកល្បងនាពេលបច្ចុប្បន្ននេះ។

## ផលិតផលសន្សំ

អេ អឹម ខេ ផ្តល់នូវផលិតផលសន្សំ៤ប្រភេទ។ ផលិតផលសន្សំទាំងនេះរួមមាន គណនីសន្សំទូទៅ គណនីងាយស្រួល គណនីមានកាលកំណត់ និងគណនីអនាគត។ ផលិតផលសន្សំងាយស្រួលកំពុងដាក់ឲ្យសាកល្បងនាពេលបច្ចុប្បន្ននេះ។ គណនីសន្សំទូទៅផ្តល់ជូនអតិថិជននូវភាពងាយស្រួលក្នុងការប្រតិបត្តិការនៅពេលប្រជុំប្រចាំខែ និងពេលចុះទៅប្រមូលប្រាក់។ គណនីងាយស្រួលរបស់ អេ អឹម ខេ ផ្តល់ជូនដល់អ្នកសន្សំប្រាក់នូវលក្ខខណ្ឌងាយស្រួល និងបត់បែន ដើម្បីធានាថាពួកគេអាចដាក់ និងដកប្រាក់ប្រកបដោយសុវត្ថិភាពនៅគ្រប់ពេលដែលពួកគេត្រូវការសាច់ប្រាក់ដោយរីករាយជាមួយនឹងការផ្តល់ជូននូវអត្រាការប្រាក់ទៅតាមទីផ្សារប្រកួតប្រជែង។ គណនីមានកាលកំណត់ផ្តល់ជូននូវអត្រាការប្រាក់ខ្ពស់ សម្រាប់អតិថិជនដែលមានបំណងដាក់មូលនិធិនៅក្នុងរយៈពេលជាក់លាក់ណាមួយ។ គណនីអនាគត សម្រាប់អតិថិជនដែលមានបំណងចង់សន្សំប្រាក់ដើម្បីគោលបំណងជាក់លាក់មួយ ឬ ទិញអ្វីមួយនាពេលអនាគត ដូចជាការចូលនិវត្តន៍ ការសិក្សារបស់កូន ឬ ទិញសម្ភារៈដាក់ផ្ទះ។

លក្ខខណ្ឌជាក់លាក់នៃផលិតផលទាំងនេះមានបរិយាយនៅក្នុងតារាងខាងក្រោម:

### គណនីសន្សំទូទៅ

| រូបិយប័ណ្ណ | រៀល | ដុល្លារអាមេរិក | បាត |
|---|---|---|---|
| អត្រាការប្រាក់ប្រចាំឆ្នាំ | ៣,០ % | ១,៥ % | ១,៥ % |
| សមតុល្យអប្បបរមា | ១.០០០ រៀល | ១ ដុល្លារ | ១០ បាត |
| ទីតាំងប្រតិបត្តិការ | ភូមិ (ពេលប្រជុំប្រចាំខែ ឬ ប្រមូល) | | |
| ការដកប្រាក់ និងគណនាការប្រាក់ | ■ ការប្រាក់គណនាទៅតាមសមតុល្យប្រចាំថ្ងៃ<br>■ គណនីនឹងត្រូវបូកបញ្ចូលរៀងរាល់៦ខែនៅក្នុងប្រព័ន្ធដោយស្វ័យប្រវត្តិ<br>■ មិនគិតថ្លៃសេវាលើរាល់ប្រតិបត្តិការ បើក ឬ បិទគណនី ឬ សៀវភៅសន្សំលើកលែងបាត់សៀវភៅសន្សំ<br>■ ដកប្រាក់មិនចំពេលប្រជុំប្រចាំខែ ត្រូវជូនដំណឹងមកសាខាឲ្យមុន១ថ្ងៃនៃថ្ងៃធ្វើការ | | |

### គណនីងាយស្រួល

| រូបិយប័ណ្ណ | រៀល | ដុល្លារអាមេរិក | បាត |
|---|---|---|---|
| អត្រាការប្រាក់ប្រចាំឆ្នាំ | ៥,០ % | ៣,០ % | ៣,០ % |
| សមតុល្យអប្បបរមា | ១.០០០ រៀល | ១ ដុល្លារ | ១០ បាត |
| ទីតាំងប្រតិបត្តិការ | នៅតាមបញ្ជរសាខា ឬ អនុសាខា | | |
| ការដកប្រាក់ និងគណនាការប្រាក់ | ■ ការប្រាក់គណនាទៅតាមសមតុល្យប្រចាំថ្ងៃ<br>■ គណនីនឹងត្រូវបូកបញ្ចូលរៀងរាល់១ខែនៅក្នុងប្រព័ន្ធដោយស្វ័យប្រវត្តិ<br>■ មិនគិតថ្លៃសេវាលើរាល់ប្រតិបត្តិការ បើក ឬ បិទគណនី ឬ សៀវភៅសន្សំលើកលែងបាត់សៀវភៅសន្សំ | | |

*អេ អឹម ខេ សូមរក្សាសិទ្ធិកែប្រែអត្រាការប្រាក់ដោយមិនបាច់ជូនដំណឹងជាមុន

## គណនីមានកាលកំណត់

| រយៈពេល / រូបិយប័ណ្ណ | រៀល | ដុល្លារអាមេរិក | បាត |
|---|---|---|---|
| ១ ខែ | ៥,៥០ % | ៣,២៥ % | ៣,២៥ % |
| ៣ ខែ | ៦,០០ % | ៣,៥០ % | ៣,៥០ % |
| ៦ ខែ | ៧,០០ % | ៤,០០ % | ៤,០០ % |
| ៩ ខែ | ៨,០០ % | ៥,០០ % | ៥,០០ % |
| ១២ ខែ | ១០,០០ % | ៧,០០ % | ៧,០០ % |
| ១៨ ខែ | ១០,៥០ % | ៧,២៥ % | ៧,២៥ % |
| ២៤ ខែ | ១១,០០ % | ៧,៥០ % | ៧,៥០ % |
| សមតុល្យអប្បបរមា | ១០០.០០០ រៀល | ២៥ ដុល្លារ | ១.០០០ បាត |
| ទីតាំងប្រតិបត្តិការ | នៅតាមបញ្ជរសាខា ឬ អនុសាខា | | |
| ការដកប្រាក់ និងគណនាការប្រាក់ | ■ ការប្រាក់នឹងគណនានៅចុងវគ្គ<br>■ ត្រូវជូនដំណឹងមុន១ថ្ងៃ សម្រាប់ការដកមុនកាលកំណត់។ អតិថិជននឹងទទួលបានអត្រាការប្រាក់ដូចគណនីងាយស្រួល<br>■ មិនមានការពិន័យចំពោះការដកមុនឡើយ | | |

## គណនីអនាគត

| រយៈពេល / រូបិយប័ណ្ណ | រៀល | ដុល្លារអាមេរិក | បាត |
|---|---|---|---|
| ៣ - ១២ ខែ | ៦,០ % | ៣,៥ % | ៣,៥ % |
| ១៣ - ២៤ ខែ | ៨,០ % | ៥,០ % | ៥,០ % |
| ២៥ - ៦០ ខែ | ៩,០ % | ៦,០ % | ៦,០ % |
| សមតុល្យអប្បបរមា | ២០.០០០ រៀល | ៥ ដុល្លារ | ២០០ បាត |
| ទីតាំងប្រតិបត្តិការ | នៅតាមបញ្ជរសាខា ឬ អនុសាខា | | |
| ការដកប្រាក់ និងគណនាការប្រាក់ | ■ ការប្រាក់នឹងគណនានៅចុងវគ្គ<br>■ ត្រូវជូនដំណឹងមុន១ថ្ងៃ សម្រាប់ការដកមុនកាលកំណត់។ អតិថិជននឹងទទួលបានអត្រាការប្រាក់ដូចគណនីងាយស្រួល<br>■ មិនមានការពិន័យចំពោះការដកមុនឡើយ | | |

*អេ អឹម ខេ សូមរក្សាសិទ្ធិកែប្រែអត្រាការប្រាក់ដោយមិនបាច់ជូនដំណឹងជាមុន

## ផលិតផលសន្សំងាយស្រួល

ដើម្បីអនុញ្ញាតិឲ្យប្រជាជនក្រីក្រជាច្រើនអាចទទួលបាននូវដំណោះស្រាយផ្នែកសេវាហិរញ្ញវត្ថុ និងប្រាក់សន្សំ បិតថេរ អេ អឹម ខេ មានគំរោងបង្កើតបណ្តាញទូទាំងប្រទេសក្នុងភូមិតាមរយៈភ្នាក់ងារសន្សំ។ ភ្នាក់ងារប្រើទូរសព្ទ័ដៃ ជាមួយកម្មវិធីក្នុងទូរសព្ទ័ដៃជាភាសាខ្មែរដើម្បីចូលទៅកាន់ ប្រពន្ធ័ធនាគាររបស់ អេ អឹម ខេ។ អេ អឹម ខេ បានធ្វើការសាកល្បងប្រពន្ធ័នេះក្នុងត្រីមាសទី២ឆ្នាំ២០១១ ហើយចាប់ផ្តើមដំណើរការសាកល្បងក្នុងត្រីមាសទី៤ ។

ភ្នាក់ងារអេ អឹម ខេ ផ្តល់នូវសេវា ដាក់ប្រាក់ ដកប្រាក់ និងផ្ទេរប្រាក់ជូនអតិថិជន។ អតិថិជនប្រើប្រាស់គណនីសន្សំងាយស្រួលទទួលបានការប្រាក់ អាចពិនិត្យមើលសមតុល្យសាច់ប្រាក់ ដែលបានដាក់ ដក និងផ្ទេរជាមួយភ្នាក់ងារបានយ៉ាងងាយស្រួលបំផុត។

បណ្តាញភ្នាក់ងារ អេ អឹម ខេ ត្រូវបានគ្រប់គ្រងដោយបុគ្គលិករបស់អេ អឹម ខេ ដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យភាពសមស្របឯកសារអតិថិជន គ្រប់គ្រងការជម្រះបញ្ជីភ្នាក់ងារ និងផ្តល់នូវដំណោះស្រាយផ្សេងៗ។ ដំណើរការសាកល្បងនឹងបន្តរហូតដល់ចុងឆ្នាំ២០១២ បន្ទាប់មកនឹងដាក់ឲ្យដំណើរការទូទាំងប្រទេស។

លក្ខណៈផលិតផលរបស់ អេ អឹម ខេ សន្សំងាយស្រួលមានដូចខាងក្រោម:

### សន្សំងាយស្រួល *

| រូបិយប័ណ្ណ | រៀល | ដុល្លារអាមេរិក |
|---|---|---|
| អត្រាការប្រាក់ប្រចាំឆ្នាំ | ៣,៥ % | ២,៥ % |
| អតិថិជនគោលដៅ | អ្នករស់នៅតាមទីជនបទ – អតិថិជន អេ អឹម ខេ និងមិនមែនអតិថិជន អេ អឹម ខេ | |
| សមតុល្យ អប្បបរមា | មិនមាន | មិនមាន |
| ទីតាំងប្រតិបត្តិការ | ■ ការិយាល័យសាខា<br>■ ការិយាល័យអនុសាខា<br>■ ភ្នាក់ងារនៅតាមភូមិ | |
| កម្រៃសេវានៅពេលដាក់ប្រាក់ | ឥតគិតថ្លៃ | |
| ការដកប្រាក់ និងការគណនា | ■ ការប្រាក់នឹងគណនាដោយផ្អែកទៅតាមសមតុល្យប្រចាំថ្ងៃ<br>■ គណនីត្រូវបានបូកបញ្ចូលជារៀងរាល់ខែនៅក្នុងប្រព័ន្ធដោយស្វ័យប្រវត្តិ<br>■ មិនគិតថ្លៃនៅពេលបើក ឬបិទគណនី ឬសម្រាប់ កាត លើកលែងតែបាត់ | |
| ប្រតិបត្តិការ ដែលមាននាពេលបច្ចុប្បន្ន | ■ ដាក់ប្រាក់នៅតាមភ្នាក់ងារ/ការិយាល័យសាខា<br>■ ដកប្រាក់នៅតាមភ្នាក់ងារ/ការិយាល័យសាខា<br>■ ផ្ទេរប្រាក់ ពីគណនី ទៅ គណនី | |
| ផែនការប្រតិបត្តិការនាពេលអនាគត | ការបង់សងត្រឡប់ប្រាក់កម្ចី | |

* សេវាសន្សំងាយស្រួល កំពុងសាកល្បងនាពេលបច្ចុប្បន្ននេះ។
*អេ អឹម ខេ សូមរក្សាសិទ្ធិក្នុងការកែប្រែអត្រាប្រាក់ដោយមិនបាច់ជូនដំណឹងជាមុន

ការផ្សព្វផ្សាយសេវាសន្សំងាយស្រួលក្នុងខេត្តតាកែវៈ មីនា ២០១២

# សេវាផ្ទេរប្រាក់

អេ អឹម ខេ បានចាប់ផ្តើមសាកល្បងដំណើរការសេវាផ្ទេរប្រាក់ក្នុងខែកក្កដាឆ្នាំ២០១១ សំរាប់ចំនួនសាខាតិចតួច។ យើងទទួលបាននូវការឆ្លើយតបជាវិជ្ជមានពីសំណាក់អតិថិជន ហើយ អេ អឹម ខេ បានចាប់ផ្តើមដំណើរការនៅគ្រប់សាខាទូទាំងប្រទេស។ លក្ខណៈពិសេសផលិតផលផ្ទេរប្រាក់ អេ អឹម ខេ មានបរិយាយនៅក្នុងតារាងខាងក្រោម:

## ការផ្តល់ប្រាក់នៅការិយាល័យសាខា

| រូបិយប័ណ្ណ | ទំហំទឹកប្រាក់ផ្ទេរប្រចាំថ្ងៃ | ថ្លៃសេវា |
|---|---|---|
| ដុល្លារអាមេរិក | រហូតដល់ ១.០០០ | ១ |
| | ១.០០១ - ២.០០០ | ២ |
| | >២.០០០ | 0,10% |
| រៀល | រហូតដល់ ៤.០០០.០០០ | ៤.០០០ |
| | ៤.០០០.០០១ - ៨.០០០.០០០ | ៨.០០០ |
| | >៨.០០០.០០០ | 0,10% |
| បាត | រហូតដល់ ៤០.០០០ | ៤០ |
| | ៤០.០០១ - ៨០.០០០ | ៨០ |
| | >៨០.០០០ | 0,10% |

## ការផ្តល់ប្រាក់ដល់ផ្ទះ

| រូបិយប័ណ្ណ | ទំហំទឹកប្រាក់ផ្ទេរប្រចាំថ្ងៃ | ថ្លៃសេវា |
|---|---|---|
| ដុល្លារអាមេរិក | រហូតដល់ ៥០០ | ២ |
| រៀល | រហូតដល់ ២.០០០.០០០ | ៨.០០០ |
| បាត | រហូតដល់ ២០.០០០ | ៨០ |

ចាប់តាំងពីដំណើរការក្នុងខែកក្កដា អេ អឹម ខេ មានការកើនឡើងទាំងចំនួនប្រតិបត្តិការ និងចំនួនទឹកប្រាក់ផ្ទេរជានិច្ច។



បុគ្គលិក អេ អឹម ខេ ផ្សព្វផ្សាយសេវាផ្ទេរប្រាក់ក្នុងរាជធានីភ្នំពេញ: កក្កដា ២០១១

# ការឆ្លើយតបសង្គ្រោះបន្ទាន់ទឹកជំនន់

នៅចុងខែកញ្ញា រយៈពេលបីសប្តាហ៍នៃទឹកភ្លៀងមូសុងដ៏ធ្ងន់ធ្ងរ បានបណ្តាលឲ្យមានគ្រោះទឹកជំនន់ដ៏អាក្រក់ដែលប្រទេសកម្ពុជាពុំដែលបានជួបប្រទះនៅក្នុងរយៈពេលមួយទស្សវត្តន៍។ ប្រជាជនប្រមាណ ១,៥ លាននាក់ ប្រហែលជា ១០% នៃប្រជាជនសរុប ត្រូវបានទទួលរងឥទ្ធិពលនៃព្យុះនេះ។ អេ អឹម ខេ យល់ឃើញថាការជនលិចមានផលជាអវិជ្ជមានទៅលើការរស់របស់អតិថិជនខ្លួន និងលទ្ធភាពរបស់ពួកគេក្នុងការបង់សងត្រឡប់ប្រាក់បំណុល។

ឆ្លើយតបទៅនឹងបញ្ហានេះ អេ អឹម ខេ បានផ្តល់កម្ចីសង្គ្រោះបន្ទាន់ទឹកជំនន់សម្រាប់ការធ្វើស្រែប្រាំង។ កម្ចីនេះត្រូវបានបង្កើតឡើងដោយយោងទៅតាមការផ្តល់មតិត្រឡប់ពីអតិថិជនដែលទទួលរងពីទឹកជំនន់ មិនមានថ្លៃសេវា អត្រាការប្រាក់ត្រឹមតែ១,៥%ប៉ុណ្ណោះក្នុងមួយខែ និងមានទំហំកម្ចីអតិបរមា ៦០០.០០០រៀល ឬ ៦.០០០បាត។ កម្ចីនេះសម្រាប់តែអតិថិជននៅក្នុងខេត្តចំនួន១២ដែលទទួលរងគ្រោះទឹកជំនន់ធ្ងន់ធ្ងរ ដែលមានរយៈពេលកម្ចីប្រាំមួយខែ។ អតិថិជនសរុប ១.៦៣១នាក់ បានប្រើប្រាស់កម្ចីសង្គ្រោះបន្ទាន់ទឹកជំនន់នេះ។

លក្ខណៈពិសេសនៃផលិតផលកម្ចីសង្គ្រោះបន្ទាន់ អេ អឹម ខេ មានបរិយាយជូននៅក្នុងតារាងខាងក្រោម:

| ការបរិយាយ | កម្ចីសង្គ្រោះបន្ទាន់ទឹកជំនន់ |
|---|---|
| អតិថិជនគោលដៅ | អតិថិជនដែលត្រូវការដើមទុនសម្រាប់យកទៅធ្វើស្រែប្រាំងបន្ទាប់ពីទឹកជំនន់ |
| ទំហំកម្ចីអតិបរមា | រហូតដល់ ៦០០.០០០រៀល ឬ ៦.០០០បាត |
| ការធានាលើកម្ចី | មិនមានអ្នកធានា |
| អត្រាការប្រាក់ (ប្រចាំខែ) | ១,៥% |
| ប្រភេទរូបិយប័ណ្ណកម្ចី | ប្រាក់រៀល និងប្រាក់បាតថៃ (នៅខេត្តបន្ទាយមានជ័យ) |
| កាលកំណត់បញ្ចេញកម្ចី | បីថ្ងៃបន្ទាប់ពីចុះហត្ថលេខា ប្រសិនបើគ្មានការផ្លាស់ប្តូរនៅក្នុងពាក្យស្នើសុំ |
| រយៈពេលអតិបរមា | ៦ ខែ |
| អត្រាការប្រាក់និងរបៀបនៃការទូទាត់សង | អត្រាការប្រាក់ប្រចាំខែ ១.៥% នៅលើសមតុល្យប្រាក់ដើមនៅសល់។ ប្រាក់ដើមអាចសងត្រឡប់ពេលចុងវគ្គ ឬ មុនពេលចុងវគ្គ។ |
| ការពិន័យលើការទូទាត់មុន | គ្មាន |
| កម្រៃលើការសងយឺត | បន្ថែម ១% ក្នុង១ខែទៅលើប្រាក់ដើមដែលនៅសល់ (គិតចាប់ពីខែដែលការទូទាត់សងមានការខកខាន) |
| កម្រៃផ្សេងៗ | គ្មាន |

អេ អឹម ខេ ជួយអង្គការក្រៅរដ្ឋាភិបាលផងដែរ ក្នុងការឆ្លើយតបចំពោះគ្រោះទឹកជំនន់ ជាពិសេសបានសហការជាមួយអង្គការ Save the Children ដើម្បីដំណើរការផ្ទេរប្រាក់ដោយផ្ទាល់ទៅដល់ក្រុមគ្រួសារជាង១០.០០០ នៅខេត្តកំពង់ចាម និងព្រៃវែង។



ទឹកជន់លិចផ្លូវជាតិលេខ៥ ក្នុងខេត្តកណ្តាល: តុលា ២០១១

ឆ្នាំ ២០១១ គឺជាឆ្នាំដែលល្អបំផុតសម្រាប់ផ្នែកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា។ នេះបានបង្ហាញឲ្យឃើញពីការរីកចម្រើននៅគ្រប់ផ្នែកទាំងអស់:

- ចំនួនអ្នកខ្ចីប្រាក់បានកើនឡើង ១៦% ស្មើនឹង ១.១៥១.៣៤០ នាក់
- ផលប័ត្រប្រាក់កម្ចីបានកើនឡើង ៥១% ស្មើនឹង ៦៤៥ លានដុល្លារអាមេរិក
- ចំនួនអ្នកដាក់ប្រាក់សន្សំបានកើនឡើង ៤៨% ស្មើនឹង ២៨០.៥៣៨ នាក់
- សមតុល្យនៃការដាក់ប្រាក់សន្សំបានកើនឡើង ១៧៩% ស្មើនឹង ១១៥ លានដុល្លារអាមេរិក

អេ អ៊ីម ខេ នៅតែប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះចំណែកអ្នកក្រីក្របំផុតនៃសង្គម ដែលមានចំនួនអតិថិជនកម្ចីច្រើនជាង និងមានទំហំកម្ចីជាមធ្យមទាបជាងគេបំផុតក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាតិធំៗទាំងអស់។

## សមិទ្ធផលវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា *

| ឆ្នាំ | ចំនួនអ្នកខ្ចីប្រាក់ | ផលប័ត្រប្រាក់កម្ចី | | ទំហំកម្ចីជាមធ្យម (ដុល្លារអាមេរិក) | ចំនួនអ្នកផ្ញើរប្រាក់ | អ្នកផ្ញើរប្រាក់ | | ទំហំផ្ញើរជាមធ្យម (ដុល្លារអាមេរិក) |
|---|---|---|---|---|---|---|---|---|
| | | ទឹកប្រាក់ (លានរៀល) | ទឹកប្រាក់ (លានដុល្លារអាមេរិក) | | | ទឹកប្រាក់ (លានរៀល) | ទឹកប្រាក់ (លានដុល្លារអាមេរិក) | |
| ២០០៩ | ៨៧៨.៥៥៩ | ១.២៤៧.៧៧៤ | ២៩៩ | ៣៤១ | ១២៦.០៩៩ | ៤០.៤៥៧ | ១០ | ៧៧ |
| ២០១០ | ៩៩២.៤៥២ | ១.៧២៦.២៥៧ | ៤២៦ | ៤២៩ | ១៩០.០២៣ | ១៦៥.៧៣៥ | ៤១ | ២១៥ |
| ២០១១ | ១.១៥១.៣៤០ | ២.៦០៣.៧១២ | ៦៤៥ | ៥៦០ | ២៨០.៥៣៨ | ៤៦២.៨៩៦ | ១១៥ | ៤០៩ |

* ប្រភព: សមាគមន៍គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ. ការផ្លាស់ប្តូរបណ្តាញព័ត៌មាន (NIX) ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

បុគ្គលិកទទួលដកប្រាក់ ជាមួយសៀវភៅសន្សំក្នុងរាជធានីភ្នំពេញ: សីហា ២០១១

# ការគ្រប់គ្រងហានិភ័យ




វប្បធម៌ហានិភ័យដ៏មាំមួន គឺជាកត្តាដ៏សំខាន់មួយក្នុងការបន្តនិរន្តរភាព និងភាពជោគជ័យ របស់ អេ អឹម ខេ។ ដើម្បីឲ្យកិច្ចការនេះប្រព្រឹត្តទៅបាន អេ អឹម ខេ បានប្រកាន់យកនូវការទប់ស្កាត់ជាមុនដោយធ្វើការបង្កើនសមត្ថភាពយល់ដឹងពីការគ្រប់គ្រងហានិភ័យនៅក្នុងគ្រឹះស្ថានទាំងមូល។ អេ អឹម ខេ បានប្រកាន់យកនូវវិធានការទប់ស្កាត់បីកំរិត ដែលរួមមាន ប្រតិបត្តិការ ហានិភ័យ និងសវនកម្មផ្ទៃក្នុង ដើម្បីចូលរួមចំនែកក្នុងការគ្រប់គ្រងហានិភ័យនៅក្នុងគ្រឹះស្ថានទាំងមូល។

អេ អឹម ខេ បានបង្កើនសមត្ថភាព និងភាពដែលអាចយល់ដឹងពីហានិភ័យដល់បុគ្គលិកគ្រប់ជាន់ថ្នាក់។ វគ្គបណ្តុះបណ្តាល ជាច្រើនត្រូវបានរៀបចំឡើងដោយនាយកដ្ឋានហានិភ័យ ធ្វើការបណ្តុះបណ្តាលដល់បុគ្គលិកស្តីពីការកំណត់ហានិភ័យ ជំរុញវិធីសាស្ត្រ ដើម្បីធ្វើឲ្យប្រសើរឡើងការត្រួតពិនិត្យ និងការត្អូញត្អែដែលនៅមានជាមួយនឹងគោលនយោបាយខាងក្នុង និងខាងក្រៅ ព្រមទាំងបទបញ្ជាផ្សេងៗ។ ក្រុមប្រឹក្សាភិបាលក៏បានបង្កើតឡើងនូវគណៈកម្មាធិការហានិភ័យ ដើម្បីផ្តល់ការណែនាំលើបញ្ហា ដែលពាក់ព័ន្ធ ព្រមទាំងធានាឲ្យបាននូវភាពសមស្របក្នុងការទទួលយកហានិភ័យរបស់គ្រឹះស្ថាន ជាមួយនឹងការទទួលបានមកវិញនូវអត្ថប្រយោជន៍ទាំងផ្នែកសង្គម និងផ្នែកហិរញ្ញវត្ថុ។



អេ អឹម ខេ ប្រើប្រាស់ដំណើរការបួនយ៉ាងក្នុងការគ្រប់គ្រងហានិភ័យប្រតិបត្តិការ នៅក្នុងក្រុមហ៊ុនទាំងមូល។ ដំណើរការទាំងនោះរួមមាន ការកំណត់ ការវាយតម្លៃ ការគ្រប់គ្រង និងការត្រួតពិនិត្យហានិភ័យ។ នៅក្នុងដំណាក់កាលកំណត់ហានិភ័យ នាយកដ្ឋានហានិភ័យបានធ្វើការសម្របសម្រួលឲ្យមានកិច្ចពិភាក្សាជាមួយនឹងប្រធានសាខា និងនាយកនាយកដ្ឋាន ដើម្បីធ្វើការកំណត់ហានិភ័យដែលពាក់ព័ន្ធទៅនឹងបុគ្គលិក នីតិវិធីផ្ទៃក្នុង ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ឬកត្តាខាងក្រៅផ្សេងទៀត។ ហានិភ័យត្រូវបានវាយតម្លៃបន្ទាប់ពីហានិភ័យនោះត្រូវបានកំណត់។ មធ្យោបាយនានាត្រូវបានប្រើប្រាស់ដូចជាការចុះបញ្ជីហានិភ័យជាដើម។ បណ្តាហានិភ័យដែលបានកំណត់ត្រូវបានកត់ត្រានៅក្នុងបញ្ជីហានិភ័យជាមួយនឹងចំណាត់ថ្នាក់ហានិភ័យ ដែលផ្អែកទៅលើលទ្ធភាពដែលអាចកើតមាន ព្រមទាំងផលប៉ះពាល់របស់ហានិភ័យទាំងនោះ។ អាទិភាពហានិភ័យត្រូវបានកំណត់ និងផែនការសកម្មភាពត្រូវបានបង្កើតឡើង ដើម្បីកាត់បន្ថយកម្រិតប្រឈមខ្ពស់ចំពោះហានិភ័យ។ អេ អឹម ខេ ក៏បានកំណត់នូវជម្រើសយុទ្ធសាស្ត្រសមស្របក្នុងការគ្រប់គ្រងហានិភ័យប្រតិបត្តិការដែលមានដូចជាការទទួលយក ការដោះស្រាយ ការផ្ទេរ និងការបញ្ចៀស។ អេ អឹម ខេ បន្តធ្វើការត្រួតពិនិត្យលើកត្តានីមួយៗ ដើម្បីធានានូវការអនុវត្តន៍តាមជំហាន ដែលបានកំណត់ ក្នុងការកាត់បន្ថយកម្រិតហានិភ័យនីមួយៗឲ្យបានសមស្រប។ ផ្អែកតាមវិធីសាស្ត្រ ដែលមានលក្ខណៈជាប្រព័ន្ធនេះគណៈគ្រប់គ្រងអាចយល់ដឹងពីហានិភ័យ ដែលកំពុងជួបប្រទះក៏ដូចជាហានិភ័យថ្មីៗ ដែលក្រុមហ៊ុននឹងជួបប្រទះ ដូច្នេះគណៈគ្រប់គ្រងអាចនឹងធ្វើសេចក្តីសម្រេចចិត្តជាយុទ្ធសាស្ត្រទុកជាមុនបាន។

ក្នុងពេល អេ អឹម ខេ កំពុងរីកចម្រើន ការផ្តោតការយកចិត្តទុកដាក់លើការកំណត់ហានិភ័យ និងការដោះស្រាយហានិភ័យតាមវិធីសាស្ត្រសមស្របនឹងជួយជំរុញ អេ អឹម ខេ ឲ្យសម្រេចបាននូវគោលបំណងទាំងផ្នែកសង្គម និងផ្នែកហិរញ្ញវត្ថុ។

## ២០១១

អេ អឹម ខេ ទទួលបានរង្វាន់អន្តរជាតិជាគ្រឹះស្ថានដែលអនុវត្តការការងារបានល្អប្រសើរបំផុតពី Fondazione Giordano Dell'Amore។ រង្វាន់នេះទទួលស្គាល់គម្រោងការងារគ្រប់គ្រងសង្គមដែលបានបង្កើតថ្មី ព្រមទាំងទទួលបានរង្វាន់ទឹកប្រាក់ចំនួន ៥0.000អឺរ៉ូ។




អេ អឹម ខេ ទទួលបានរង្វាន់តម្រិត Platinum ផ្នែកគ្រប់គ្រង និងរាយការណ៍ផ្នែកសង្គមពីបណ្តាញ ផ្លាស់ប្តូរព័ត៌មានមីក្រូហិរញ្ញវត្ថុ (MIX) ដែលជារង្វាន់កម្រិតខ្ពស់បំផុតក្នុងកិច្ចខិតខំប្រឹងប្រែងចំពោះការគ្រប់គ្រង និងការត្រួតពិនិត្យការងារសង្គមប្រកបដោយតម្លាភាព។ រង្វាន់កម្រិត Platinum នេះ ត្រូវបានផ្តល់ជូនចំពោះស្ថាប័នមីក្រូហិរញ្ញវត្ថុចំនួន២២នៅក្នុងលោកក្នុងឆ្នាំ២០១១។

កិច្ចប្រជុំកំពូលមីក្រូហិរញ្ញវត្ថុ C៥ បានទទួលស្គាល់ អេ អឹម ខេ ដោយផ្តល់ជាបណ្ណសរសើរក្នុងការបម្រើអតិថិជនបានច្រើនបំផុតលើលោក សម្រាប់ការទទួលខុសត្រូវចំពោះអតិថិជនក្នុងកម្រិតខ្ពស់បំផុត។

## ២០១០

អេ អឹម ខេ ទទួលបានបណ្ណសរសើរមាសស្តីពីការរាយការណ៍ការងារសង្គមពី Microfinance Information Exchange (MIX) ការផ្តល់បណ្ណសរសើរនេះ ត្រូវបានរៀបចំដោយ MIX ព្រមទាំងចូលរួមឧបត្ថម្ភគាំទ្រពី CGAP. the Michael & Susan Dell Foundation និង the Ford Foundation។ បណ្ណសរសើរនេះទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងលើការរាយការណ៍ព័ត៌មានពីការងារសង្គម។




## ២០០៩

នៅឆ្នាំ ២០០៩ ការចាត់ថ្នាក់របស់ MIX Global 100 Composite អេ អឹម ខេ ត្រូវបានផ្តល់ចំណាត់ថ្នាក់ទី១៦

នៅលើពិភពលោក និងទី១នៅប្រទេសកម្ពុជា រយៈពេលបីឆ្នាំជាប់ៗគ្នា ហើយជាគ្រឹះស្ថានតែមួយគត់ក្នុងចំណោមអង្គភាពទាំង ២០ ដែលឈរនៅលំដាប់កំពូលនៅលើសកលលោករយៈពេលបីឆ្នាំចុងក្រោយនេះ។




ធនាគារជាតិនៃកម្ពុជាផ្តល់ អេ អឹម ខេ នូវបណ្ណសរសើរស្តីពីការទទួលស្គាល់ជាគ្រឹះស្ថានដែលមានតម្លាភាពផ្នែកមីក្រូហិរញ្ញវត្ថុ។

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី (ហៅកាត់ថា "ក្រុមហ៊ុន") មានសេចក្តីសោមនស្ស សូមដាក់ជូនរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ ក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ ជូនប្រជាពលរដ្ឋក្រីក្រកម្ពុជា តាមរយៈការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងតាមរយៈបណ្តាសាខាជាច្រើនទៀត នៅរាជធានីភ្នំពេញ និងបណ្តាខេត្តនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ត្រូវបានបង្ហាញក្នុងរបាយការណ៍ លទ្ធផល នៅលើទំព័រទី ៨ នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ទ្រព្យសកម្ម

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលបណ្តាលឲ្យតម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានកំហុសឆ្គងនោះទេ។

## ទ្រព្យអកម្មយថាភាព និងទ្រព្យអកម្មផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមាន ៖

ក. បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំ សម្រាប់ការធានាបំណុលរបស់បុគ្គលណាមួយ។

ខ. ទ្រព្យអកម្មយថាភាពណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងចាប់ពីដំណាច់ឆ្នាំមក។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល មិនមានទ្រព្យអកម្មយថាភាព ឬទ្រព្យអកម្មផ្សេងៗរបស់ក្រុមហ៊ុន ដែលត្រូវបានទាមទារឲ្យសង ឬអាចនឹងត្រូវទាមទារឲ្យសង ក្នុងរយៈពេល ១២ ខែ គិតចាប់ពីដំណាច់ឆ្នាំ ដែលនឹងឬអាចនឹងមានឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន នៅថ្ងៃកំណត់សងនោះទេ។

## ការផ្លាស់ប្តូរកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបាន វែកញែកនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចបណ្តាលឲ្យចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុមានកំហុសឆ្គងនោះទេ។

## ប្រតិបត្តិការមិនធម្មតា

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ពុំមានរងនូវការប៉ះពាល់ជាសារវន្តពីគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតានោះទេ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល មិនមានគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជា សារវន្ត និងមិនធម្មតា ដែលបានកើតឡើងនៅក្នុងចន្លោះពេលរវាងថ្ងៃបិទបញ្ជី និងកាលបរិច្ឆេទនៃរបាយការណ៍នេះ ដែលអាចនាំឲ្យប៉ះពាល់ជាសារវន្ត លើលទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងឆ្នាំនេះទេ។

## ព្រឹត្តិការណ៍សំខាន់ៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមានព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្តណាមួយ បានកើតឡើងក្រោយកាលបរិច្ឆេទតារាងតុល្យការ ដែលតម្រូវឲ្យមាននិយ័តកម្ម ឬការលាតត្រដាងណាមួយ ក្រៅពីការលាតត្រដាងផ្សេងៗ ក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលក្នុងអំឡុងឆ្នាំ និងគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម:

- **លោក TANMAY CHETAN**
  ប្រធានក្រុមប្រឹក្សាភិបាល
- **លោក PETER POWER**
  សមាជិកក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក
- **លោកស្រី FRANCES SINHA**
  សមាជិកក្រុមប្រឹក្សាភិបាល
- **លោក MARCUS FEDDER**
  សមាជិកក្រុមប្រឹក្សាភិបាល
- **លោកស្រី REBECCA MCKENZIE**
  សមាជិកក្រុមប្រឹក្សាភិបាល
- **លោកស្រី IRINA IGNATIEVA**
  សមាជិកក្រុមប្រឹក្សាភិបាល
- **លោក HOWARD DALZELL**
  សមាជិកក្រុមប្រឹក្សាភិបាល
- **លោក TIP JANVIBOL**
  សមាជិកក្រុមប្រឹក្សាភិបាល
- **លោក ADRIAN GRAHAM**
  សមាជិកក្រុមប្រឹក្សាភិបាល

## ផលកម្រៃរបស់ក្រុមប្រឹក្សាភិបាល

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ កាន់កាប់ផលកម្រៃ ក្នុងមូលធនរបស់ក្រុមហ៊ុននោះទេ។ ក្រុមហ៊ុន មិនបានចូលរួមក្នុងការរៀបចំណាមួយក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដើម្បីឲ្យទទួលបានផលកម្រៃតាមរយៈការទិញភាគហ៊ុន ឬប័ណ្ណបំណុលពីសាម៉ីក្រុមហ៊ុន ឬក្រុមហ៊ុនផ្សេងទៀតឡើយ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុងឆ្នាំ និងគិតត្រឹមដំណាច់ឆ្នាំនេះ ក្រុមហ៊ុនមិនបានចូលរួមក្នុងការរៀបចំណាមួយ ក្នុងគោលបំណងជួយ ដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដើម្បីឲ្យទទួលបានអត្ថប្រយោជន៍ តាមរយៈការទិញភាគហ៊ុន ឬប័ណ្ណបំណុល ពីសាម៉ីក្រុមហ៊ុន ឬក្រុមហ៊ុនផ្សេងទៀតឡើយ។

មិនមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់របស់ក្រុមហ៊ុនទទួលបាន ឬមានសិទ្ធិនឹងទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ផ្សេងៗ ដែលបានរួមបញ្ចូលទៅក្នុងចំនួនអត្ថប្រយោជន៍សរុប ដែលសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗត្រូវទទួលបាន ដូចបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងរវាងក្រុមហ៊ុន ឬរវាងក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិកឬជាមួយក្រុមហ៊ុនដែលសមាជិក ក្រុមប្រឹក្សាភិបាលនោះ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្ត ក្រៅពីអ្វីដែលបានលាតត្រដាងនៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុនេះទេ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល ចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដោយផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងចលនាសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ តម្រូវឲ្យក្រុមប្រឹក្សាភិបាល ៖

(ក) ជ្រើសរើសគោលការណ៍គណនេយ្យដែលសមស្របមកប្រើ ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណ យ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ហើយបន្ទាប់មក ត្រូវអនុវត្តឲ្យមានភាពស៊ីសង្វាក់គ្នា។

(ខ) អនុលោមតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មាន និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដារទាំងនោះ ក្នុងការបង្ហាញឲ្យមានភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះ ត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណ ឲ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(គ) ថែរក្សាកំណត់ត្រាគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានករណីសន្មត ដោយសមរម្យថា ក្រុមហ៊ុននឹងមិនអាចបន្តប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី។

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាព ដោយចូលរួមលើរាល់ការសម្រេចចិត្តសំខាន់ៗទាំងអស់ ដែលមានឥទ្ធិពលលើប្រតិបត្តិការ និងលទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមការតម្រូវខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## របាយការណ៍ក្រុមប្រឹក្សាភិបាល

តាងនាមក្រុមប្រឹក្សាភិបាលក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី យើងខ្ញុំសូមធ្វើការបញ្ជាក់ អះអាងថា របាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងកំណត់សម្គាល់ទាំងឡាយដែលបានភ្ជាប់មកជាមួយនេះ បានបង្ហាញយ៉ាងត្រឹមត្រូវ នូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងចលនាសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជាក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជ. ក្រុមប្រឹក្សាភិបាល

លោក TANMAY CHETAN
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ: ២១ មិនា ២០១២

ជូនភាគទុនិក ក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុន អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី (ហៅកាត់ថា "ក្រុមហ៊ុន") រួមមាន តារាងតុល្យការ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍ចលនាសាច់ប្រាក់សម្រាប់ ដំណាច់ឆ្នាំ ព្រមទាំងសេចក្តីសង្ខេប នៃគោលការណ៍ គណនេយ្យសំខាន់ៗ និងកំណត់សម្គាល់ផ្សេងៗទៀត។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង ទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ ហិរញ្ញវត្ថុទាំងនេះឲ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមគោលការណ៍ ណែនាំផ្សេងៗ របស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ ហិរញ្ញវត្ថុ មិនឲ្យមានការ រាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុស ឆ្គងផ្សេងៗ។

## ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុទាំង នេះ ដោយផ្អែកទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ស្តង់ដារ ទាំងនោះ តម្រូវឲ្យយើងខ្ញុំប្រតិបត្តិតាមក្រមសីលធម៌ ធ្វើផែនការ និងធ្វើ សវនកម្ម ដើម្បីទទួលបាននូវការធានាអះអាង ដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុពុំមានលក្ខណៈខុសឆ្គងជាសារវន្ត។

ការធ្វើសវនកម្ម រួមមានការអនុវត្តនីតិវិធីដើម្បីទទួលបាននូវភស្តុតាង សវនកម្ម អំពីចំនួនទឹកប្រាក់ និងការដាក់ បង្ហាញនៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុ។ ការជ្រើសរើសនីតិវិធីទាំងនេះ គឺអាស្រ័យលើការវិនិច្ឆ័យរបស់ សវនករ ដោយរួមបញ្ចូលទាំងការវាយតម្លៃលើហានិភ័យនៃភាពខុសឆ្គងជា សារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬ កំហុសឆ្គង។ ក្នុងការវាយតម្លៃហានិភ័យទាំងនោះ សវនករបានពិចារណា ទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ ក្រុមហ៊ុនដែលទាក់ទងទៅនឹងការរៀបចំ និងការបង្ហាញយ៉ាងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីរៀបចំនូវនីតិវិធី សវនកម្មដែលមានលក្ខណៈសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ ប៉ុន្តែការពិចារណានេះ ពុំមានគោលបំណងបញ្ចេញ មតិទៅលើប្រសិទ្ធភាព នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។ សវនកម្មក៏រួមបញ្ចូលទាំង ការវាយតម្លៃនូវ ភាពសមស្របនៃគោលការណ៍គណនេយ្យដែលបាន ប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ដែលធ្វើ ឡើងដោយគណៈគ្រប់គ្រង ក៏ដូចជាការវាយតម្លៃលើការបង្ហាញជាទូទៅនៃ របាយការណ៍ហិរញ្ញវត្ថុ។

យើងខ្ញុំ ជឿជាក់ថាភស្តុតាងសវនកម្មដែលយើងទទួលបាន គឺមានលក្ខណៈ គ្រប់គ្រាន់ និងត្រឹមត្រូវ ដែលជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់ របស់យើងខ្ញុំ ។

## មតិយោបល់

តាមទស្សនៈរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញត្រឹមត្រូវនូវ គ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិត ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងចលនាសាច់ ប្រាក់ សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមគោលការណ៍ណែនាំ របស់ធនាគារជាតិ នៃកម្ពុជា និងស្តង់ដាគណនេយ្យកម្ពុជា។

ជ. PricewaterhouseCoopers (Cambodia) Ltd.

គុយ លីម
នាយក

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ: ២១ មិនា ២០១២



បុគ្គលិកទទួលដកប្រាក់ អេ អឹម ខេ ផ្តល់សេវាកម្មជូនអតិថិជននៅអនុសាខាមានជ័យ រាជធានីភ្នំពេញ: មិថុនា ២០១១

# តារាងតុល្យការ
## គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១១

| | | ២០១១ | | ២០១០ | |
|---|---|---|---|---|---|
| | សម្គាល់ | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤ | ១.៥២០.៤០៤ | ៣៧៦.៤៣១ | ៨៣០.៥២៧ | ២០៤.៩១៧ |
| សមតុល្យនៅធនាគារកណ្ដាល | ៥ | ៤.៨៥៥.៣៤៣ | ១.២០២.១១៥ | ៥.២១៥.០៣១ | ១.២៨៦.៧០៩ |
| សមតុល្យនៅធនាគារផ្សេងៗ | ៦ | ៦៦.១២៥.៥៤៥ | ១៦.៣៧១.៧៦២ | ៣៥.៩៦៨.១៩៨ | ៨.៨៧៤.៤៦៣ |
| ឥណទានអតិថិជន | ៧ | ១៩០.០៨៨.៨២២ | ៤៧.០៦៣.៣៣៨ | ១២៥.៥៩៨.៨៣៣ | ៣០.៩៨៩.១០៣ |
| ទ្រព្យសកម្មផ្សេងៗ | ៨ | ៦.៦៦៦.៧៤០ | ១.៦៥០.៥៩២ | ៣.៨៧១.៣៥៨ | ៩៥៥.១៨៣ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៩ | ៤.៣៥០.៩៤៥ | ១.០៧៧.២៣៣ | ៣.៨១៤.១១៨ | ៩៤១.០៦០ |
| ទ្រព្យសកម្មអរូបិយ | ១០ | ១.៨៥៦.៥៧៦ | ៤៥៩.៦៦២ | ២.៣៧៨.០០៤ | ៥៨៦.៧២៧ |
| ពន្ធពន្យារជាទ្រព្យសកម្ម | ១១ | ៧៩៣.៤៦៩ | ១៩៦.៤៥២ | ២៤២.១៨៦ | ៥៩.៧៥៥ |
| **ទ្រព្យសកម្មសរុប** | | **២៧៦.២៥៧.៨៤៤** | **៦៨.៣៩៧.៥៨៥** | **១៧៧.៩១៨.២៥៥** | **៤៣.៨៩៧.៩១៧** |
| **ទ្រព្យអកម្ម** | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | ១២ | ១៨.៥៣៤.១០២ | ៤.៥៨៨.៧៨៥ | ៥.៧៨១.៧៣១ | ១.៤២៦.៥៣១ |
| ប្រាក់ជំពាក់ភាគទុនិក | | - | - | ៧៦.៦៦៤ | ១៨.៩១៧ |
| ពន្ធទ្រព្យអកម្ម | ១៣ | ១.៨៥៦.៤១៧ | ៤៥៩.៦២៣ | ៤៣០.៨៦២ | ១០៦.៣០៧ |
| ទ្រព្យអកម្មផ្សេងៗ | ១៤ | ៨.១១៤.២៤០ | ២.០០៨.៩៧៣ | ៣.៩៧០.១៩៤ | ៩៧៩.៥៦៩ |
| ប្រាក់កម្ចី | ១៥ | ១៨៨.៥១១.៩០៨ | ៤៦.៦៧២.៩១៦ | ១១៧.១៧៩.៤១៧ | ២៨.៩១១.៧៧៣ |
| សំវិធានធនសម្រាប់មូលនិធិសោធននិវត្តន៍របស់បុគ្គលិក | ១៦ | ៣.០១១.២៨១ | ៧៤៥.៥៥១ | ២.០៣៩.៣០៥ | ៥០៣.១៥៩ |
| **ទ្រព្យអកម្មសរុប** | | **២២០.០២៧.៩៤៨** | **៥៤.៤៧៥.៨៤៨** | **១២៩.៤៧៨.១៧៣** | **៣១.៩៤៦.២៥៦** |
| **មូលធន** | | | | | |
| ដើមទុន | ១៧ | ៣៤.៥៧៩.២០០ | ៨.៥៦១.៣២៧ | ៣៤.០៦៩.២៥០ | ៨.៤០៥.៩៣៤ |
| បុព្វលាភភាគហ៊ុន | | ៩៥.៥០៦ | ២៣.៦៤៦ | | |
| ដើមទុនបម្រុង | ១៨ | ៣.៣០៤.៣៣៨ | ៨១៨.១០៨ | ១.៥៥០.៦១៨ | ៣៨២.៥៨៥ |
| ចំណេញរក្សាទុក | | ១៨.២៥០.៨៥២ | ៤.៤៦៧.៣១៩ | ១២.៨២០.២១៤ | ៣.១៣១.៦៩៧ |
| លំអៀងពីការប្តូររូបិយប័ណ្ណ | | - | ៥១.៣៣៧ | - | ៣១.៤៤៥ |
| **មូលធនសរុប** | | **៥៦.២២៩.៨៩៦** | **១៣.៩២១.៧៣៧** | **៤៨.៤៤០.០៨២** | **១១.៩៥១.៦៦១** |
| **ទ្រព្យអកម្ម និងមូលធនសរុប** | | **២៧៦.២៥៧.៨៤៤** | **៦៨.៣៩៧.៥៨៥** | **១៧៧.៩១៨.២៥៥** | **៤៣.៨៩៧.៩១៧** |

# របាយការណ៍លទ្ធផល
## សម្រាប់ដំណាច់ឆ្នាំ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១១

| | | ២០១១ | | ២០១០ | |
|---|---|---|---|---|---|
| | សម្គាល់ | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ចំណូលពីការប្រាក់ | ១៩ | ៥៦.៧៣០.០១០ | ១៣.៩៥២.២៩០ | ៤២.៨១៤.៧៥២ | ១០.២២៣.១៩៨ |
| ចំណាយលើការប្រាក់ | ២០ | (១៦.៣៨៦.៤៣៦) | (៤.០៣០.១១២) | (១២.១១៨.១៩៨) | (២.៨៩៣.៥៥៣) |
| **ចំណូលពីការប្រាក់សុទ្ធ** | | **៤០.៣៤៣.៥៧៤** | **៩.៩២២.១៧៨** | **៣០.៦៩៦.៥៥៤** | **៧.៣២៩.៦៤៥** |
| | | | | | |
| ចំណាយកម្រៃ និងកម្រៃជើងសារ | | (៣.០៦០.៥៦០) | (៧៥២.៧២០) | (២.០៨៩.៣៨១) | (៤៩៨.៨៩៧) |
| | | | | | |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២១ | ១.៤៤០.៦៣៦ | ៣៥៤.៣១៣ | ១.៥១៨.៩៨១ | ៣៦២.៦៩៨ |
| ចំណាយប្រតិបត្តិការផ្សេងៗ | ២២ | (២៨.១៧៦.១១០) | (៦.៩២៩.៦៨៨) | (២៣.៩៦០.៦៩៩) | (៥.៧២១.២៧៤) |
| សំវិធានធនសម្រាប់ការខាតបង់ឥណទានដែលអាចកើតមាន | ៧-a | (១.៨៨៩.០១៣) | (៤៦៤.៥៨៨) | (១.៦០៣.០៩០) | (៣៨២.៧៨២) |
| **ចំណូលប្រតិបត្តិការ** | | **៨.៦៥៨.៥២៧** | **២.១២៩.៤៩៥** | **៤.៥៦២.៣៦៥** | **១.០៨៩.៣៩០** |
| | | | | | |
| ចំណូលជាជំនួយ | ២៣ | ៥១៧.២៩០ | ១២៧.២២៣ | ៦៦៦.៤៣៨ | ១៥៩.១៣០ |
| | | | | | |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ** | | **៩.១៧៥.៨១៧** | **២.២៥៦.៧១៨** | **៥.២២៨.៨០៣** | **១.២៤៨.៥២០** |
| | | | | | |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៤ | (១.៩៩១.៤៥៩) | (៤៨៩.៧៨៣) | (១.៣១២.០២២) | (៣១៣.២៨១) |
| | | | | | |
| **ចំណេញសុទ្ធក្នុងឆ្នាំ** | | **៧.១៨៤.៣៥៨** | **១.៧៦៦.៩៣៥** | **៣.៩១៦.៧៨១** | **៩៣៥.២៣៩** |

បុគ្គលិក អេ អឹម ខេ ផ្តល់ប្រាក់ដែលបានផ្ទេរដល់ផ្ទះអតិថិជនក្នុងខេត្តព្រៃវែង: ធ្នូ ២០១១

# របាយការណ៍បម្រែបម្រួលមូលធន
## សម្រាប់ដំណាច់ឆ្នាំ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១១

| | ដើមទុន | | បុព្វលាភភាគហ៊ុន | | ដើមទុនបម្រុង | | ចំណេញរក្សាទុក | | លំអៀងពីការប្តូររូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | | | | | | | | | | | |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១០ | ៣៤.០៦៩.២៥០ | ៨.១៧២.០៤៤ | - | - | - | - | ១០.៤៥៤.០៥១ | ២.៥៦៦.៧១១ | (៥៩.១៤៣) | ៤៤.៥២៣.៣០១ | ១០.៦៧៩.៦១២ |
| ការផ្ទេរទៅដើមទុនបម្រុងក្នុងឆ្នាំ | - | - | - | - | ១.៥៥០.៦១៨ | ៣៧០.២៥៣ | (១.៥៥០.៦១៨) | (៣៧០.២៥៣) | (១២.៣៣២) | - | (១២.៣៣២) |
| ចំណេញសុទ្ធក្នុងឆ្នាំ | - | - | | | - | - | ៣.៩១៦.៧៨១ | ៩៣៥.២៣៩ | ៣១.១៥១ | ៣.៩១៦.៧៨១ | ៩៦៦.៣៩០ |
| លំអៀងពីការប្តូររូបិយប័ណ្ណ | - | ២៣៣.៤៩០ | - | - | - | ១២.៣៣២ | - | - | ៧១.៧៦៩ | - | ៣១៧.៩៩១ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | ៣៤.០៦៩.២៥០ | ៨.៤០៥.៩៣៤ | - | - | ១.៥៥០.៦១៨ | ៣៨២.៥៨៥ | ១២.៨២០.២១៤ | ៣.១៣១.៦៩៧ | ៣១.៩៤៥ | ៤៨.៤៤០.០៨២ | ១១.៩៥១.៦៦១ |
| **ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១** | | | | | | | | | | | |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១១ | ៣៤.០៦៩.២៥០ | ៨.៤០៥.៩៣៤ | - | - | ១.៥៥០.៦១៨ | ៣៨២.៥៨៥ | ១២.៨២០.២១៤ | ៣.១៣១.៦៩៧ | ៣១.៩៤៥ | ៤៨.៤៤០.០៨២ | ១១.៩៥១.៦៦១ |
| ការបោះផ្សាយភាគហ៊ុនថ្មី | ៥០៩.៩៥០ | ១២៥.៤១៨ | ៩៥.៥០៦ | ២៣.៤៨៩ | - | - | - | - | - | ៦០៥.៤៥៦ | ១៤៨.៩០៧ |
| ការផ្ទេរទៅដើមទុនបម្រុងក្នុងឆ្នាំ | - | - | - | - | ១.៧៥៣.៧២០ | ៤៣១.៣១៣ | (១.៧៥៣.៧២០) | (៤៣១.៣១៣) | - | - | - |
| ចំណេញសុទ្ធក្នុងឆ្នាំ | - | - | - | - | - | - | ៧.១៨៤.៣៥៨ | ១.៧៦៦.៩៣៥ | - | ៧.១៨៤.៣៥៨ | ១.៧៦៦.៩៣៥ |
| លំអៀងពីការប្តូររូបិយប័ណ្ណ | - | ២៩.៩៧៥ | - | ១៥៧ | - | ៤.២១០ | - | - | ១៩.៨៩២ | - | ៥៤.២៣៤ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១** | ៣៤.៥៧៩.២០០ | ៨.៥៦១.៣២៧ | ៩៥.៥០៦ | ២៣.៦៤៦ | ៣.៣០៤.៣៣៨ | ៨១៨.១០៨ | ១៨.២៥០.៨៥២ | ៤.៤៦៧.៣១៩ | ៥១.៣៣៧ | ៥៦.២២៩.៨៩៦ | ១៣.៩២១.៧៣៧ |

# របាយការណ៍ចលនាសាច់ប្រាក់
## សម្រាប់ដំណាច់ឆ្នាំ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១១

| | | ២០១១ | | ២០១០ | |
|---|---|---|---|---|---|
| | សម្គាល់ | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **ចលនាសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់បានប្រើក្នុងប្រតិបត្តិការ | ២៥ | (៦៣.២៦៧.៥៥៤) | (១៥.៥៦០.១២១) | (១៣.១៨៩.៨១១) | (៣.១៩៩.៨៣០) |
| ពន្ធលើប្រាក់ចំណេញបានបង់ | ១៣ | (១.១១៧.១៨៦) | (២៧៤.៧៦៣) | (៩៥១.៥០៨) | (២២៧.១៧៥) |
| មូលនិធិសោធននិវត្តន៍របស់បុគ្គលិកបានបង់ | | (៣០៦.០៣៤) | (៧៥.២៦៧) | (២៤៥.៦៨៦) | (៥៨.៦៦៤) |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពប្រតិបត្តិការ** | | **(៦៤.៦៩០.៦៧៥)** | **(១៥.៩១០.១៥១)** | **(១៤.៣៨៦.៩០៥)** | **(៣.៤៣៥.២៦៩)** |
| **ចលនាសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់បញ្ញើដើមទុនដែលមានការធានានៅធនាគារកណ្តាល | | - | - | (១.៧០៣.៤៦២) | (៤០៦.៧៤៨) |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ៩ | (១.៨៥២.៣២៩) | (៤៥៥.៥៦៥) | (១.១៨១.២៩៦) | (២៨២.០៦៧) |
| ការទិញទ្រព្យសកម្មអរូបិយ | ១០ | (២០.៨៧៩) | (៥.១៣៥) | (២.៣៦៤.៧៦២) | (៥៦៤.៦៥២) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | ៥០.២៧១ | ១២.៣៦៤ | ១០.១២២ | ២.៤១៧ |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ** | | **(១.៨២២.៩៣៧)** | **(៤៤៨.៣៣៦)** | **(៥.២៣៩.៣៩៨)** | **(១.២៥១.០៥០)** |
| **ចលនាសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | ១០១.២៣៩.៣៣៤ | ២៤.៨៩៩.០០០ | ៤៦.៣៣៣.៤៦៩ | ១១.០៦៣.៣៨៨ |
| ការសងប្រាក់កម្ចី | | (៣៣.៩៤៤.០៦១) | (៨.៣៤៨.២៦៩) | (៣៥.៩៧៤.៧៩៧) | (៨.៥៨៩.៩៧១) |
| សាច់ប្រាក់បានពីការបោះផ្សាយភាគហ៊ុន | | ៦០៥.៤៥៦ | ១៤៩.៩០២ | - | - |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន** | | **៦៧.៩០០.៧២៩** | **១៦.៧០០.៦៣៣** | **១០.៣៥៨.៦៧២** | **២.៤៧៣.៤១៧** |
| **កំណើន/( តំហយ )សុទ្ធ នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | **១.៣៨៧.១១៧** | **៣៤២.១៤៥** | **(៩.២៦៧.៦៣១)** | **(២.២១២.៩០២)** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមឆ្នាំ | ៤ | ១៩.១១៧.៧៣១ | ៤.៧១៦.៩៣៣ | ២៨.៣៨៥.៣៦២ | ៦.៨០៨.៦៧៤ |
| លំអៀងពីការប្តូររូបិយប័ណ្ណ | | - | ១៧.៦៣៦ | - | ១២១.១៦១ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងឆ្នាំ** | | **២០.៥០៤.៨៤៨** | **៥.០៧៦.៧១៤** | **១៩.១១៧.៧៣១** | **៤.៧១៦.៩៣៣** |

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជូន ដូចខាងក្រោម។ គោលការណ៍ទាំងនេះត្រូវបានអនុវត្តយ៉ាងស៊ីសង្វាក់គ្នា គ្រប់ឆ្នាំដែលបានបង្ហាញជូនទាំងអស់ លើកលែង តែមានការបញ្ជាក់ផ្សេងពីនេះ។

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានរៀបចំដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") និងស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា "CAS")។ ក្នុងការប្រើប្រាស់ CAS ក្រុមហ៊ុនក៏បានប្រើ ស្តង់ដារទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុកម្ពុជា CFRS ៧ ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ ៖ ការលាតត្រដាងព័ត៌មាន" ផងដែរ។ គោលការណ៍គណនេយ្យដែលបានប្រើប្រាស់ អាចមានភាពខុសគ្នាពីគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ និងប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេស និងយុត្តាធិការផ្សេងៗ។ របាយការណ៍ ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយនេះ មិនមានបំណងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងចលនាសាច់ប្រាក់ ដោយអនុលោមទៅតាមយុត្តាធិការណាផ្សេងក្រៅពីព្រះរាជាណាចក្រកម្ពុជានោះទេ។ ដូចនេះរបាយការណ៍ ហិរញ្ញវត្ថុទាំងនេះសម្រាប់បង្ហាញចំពោះតែអ្នកដែលបានជ្រាបអំពីគោលការណ៍គណនេយ្យ នីតិវិធី និងការអនុវត្តនៅក្នុង ព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងជាប្រាក់រៀលខ្មែរ("រៀល")ដោយប្រើប្រាស់វិធីសាស្ត្រថ្លៃដើម។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលស្របទៅតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាល និង CAS តម្រូវឲ្យប្រើប្រាស់ការប៉ាន់ស្មាន និងការសន្មត ដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងទ្រព្យអកម្ម និងការលាតត្រដាងទ្រព្យសកម្ម និងទ្រព្យអកម្មយថាភាព ដែលបានរាយការណ៍គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ ហិរញ្ញវត្ថុ និងប៉ះពាល់ដល់ចំនួននៃចំណូល និងចំណាយ ដែលបានរាយការណ៍នៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ។ ទោះបីជាការប៉ាន់ស្មានទាំងនេះ ផ្អែកទៅលើការយល់ដឹងខ្ពស់របស់គណៈគ្រប់គ្រងទៅលើព្រឹត្តិការណ៍ និងសកម្មភាពផ្សេងៗនាពេលបច្ចុប្បន្នក៏ដោយ ក៏លទ្ធផលជាក់លាក់ចុងក្រោយអាចខុសពីការប៉ាន់ស្មានទាំងនេះ។ ផ្នែកដែលទាក់ទងនឹងកម្រិតខ្ពស់នៃការវិនិច្ឆ័យ ឬភាពស្មុគស្មាញ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្ត ចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៣។

តួលេខប្រៀបធៀបត្រូវបានកែតម្រូវដើម្បីឲ្យស្របទៅនឹងបម្រែបម្រួលនៃការបង្ហាញក្នុងឆ្នាំបច្ចុប្បន្ន នៅពេលដែលមានភាពចាំបាច់។

### ២.២ រូបិយប័ណ្ណបរទេស

#### (ក) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានវាស់តម្លៃដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បងដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល")។ របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់រៀលខ្មែរ ("រៀល") ដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ក្រុមហ៊ុន។ រូបិយប័ណ្ណគោលរបស់ក្រុមហ៊ុនគឺជាប្រាក់រៀល ដោយសារវាមានឥទ្ធិពលជាសារវន្តដល់ប្រតិបត្តិការរបស់ ក្រុមហ៊ុន។

#### (ខ) ការបង្ហាញជាប្រាក់ដុល្លារអាមេរិក

ក្រុមហ៊ុនបានបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក ("US$") ដោយកត់ត្រាពីប្រាក់រៀល ទៅប្រាក់ដុល្លារអាមេរិក មានដូចខាងក្រោម ៖

- ទ្រព្យសកម្មនិងទ្រព្យអកម្មដែលបានបង្ហាញនៅក្នុងតារាងតុល្យការនីមួយៗ និងមូលធនភាគទុនិកត្រូវបានកត់ត្រា តាមអត្រាចុងគ្រា នាកាលបរិច្ឆេទតារាងតុល្យការ។
- របាយការណ៍លទ្ធផល និងរបាយការណ៍ចលនាសាច់ប្រាក់ ត្រូវបានកត់ត្រាជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់ អត្រាមធ្យមក្នុងឆ្នាំ។
- រាល់លទ្ធផលនៃលំអៀងពីការប្តូររូបិយប័ណ្ណដែលបានកើតឡើង ត្រូវបានកត់ត្រាដោយឡែកពីគ្នានៅក្នុងមូលធន។

#### (គ) ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល ត្រូវបានកត់ត្រាទៅជាប្រាក់រៀល តាមអត្រាប្តូរប្រាក់ ជាសកល នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណបរទេស ដោយសារការទូទាត់ប្រតិបត្តិការនិងពីការកត់ត្រាទ្រព្យសកម្ម និងទ្រព្យអកម្មរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល តាមអត្រាប្តូរប្រាក់នាដំណាច់ឆ្នាំត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

### ២.៣ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

នៅក្នុងរបាយការណ៍ចលនាសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើដែលអាចដកមកវិញបាននៅធនាគារផ្សេងៗ ការវិនិយោគដែលមានលទ្ធភាពអាចបង្វិលជាសាច់ប្រាក់បានលឿនក្នុងរយៈពេលខ្លី ដែលមានកាលកំណត់បីខែ ឬតិចជាងនេះ និងឥណទានវិបារូបន៍។ នៅក្នុងតារាងតុល្យការ ឥណទាន វិបារូបន៍ ត្រូវបានបង្ហាញនៅក្នុងប្រាក់កម្ចី។

### ២.៤ ឥណទានអតិថិជន

ឥណទានអតិថិជន ត្រូវបានរាយការណ៍ក្នុងតារាងតុល្យការ តាមចំនួនទឹកប្រាក់ដើម ដកចំនួនដែលបានជម្រះចេញពីបញ្ជី សំវិធានធនទូទៅ និងសំវិធានធនជាក់លាក់។ ឥណទានរយៈពេលខ្លី គឺជាឥណទានដែលមានកាលបរិច្ឆេទបង់សង ក្នុងរយៈពេល១ឆ្នាំនៃកាលបរិច្ឆេទដែលឥណទានត្រូវបានធ្វើបុរេប្រទាន។ ឥណទានរយៈពេលវែង គឺជាឥណទានដែលមានកាលបរិច្ឆេទបង់សងចុងក្រោយ មានរយៈពេលលើសពី១ឆ្នាំ នៃកាលបរិច្ឆេទដែលឥណទានត្រូវបានធ្វើបុរេប្រទាន។

សំវិធានធនសម្រាប់ឥណទានអាក្រក់ និងសង្ស័យ ត្រូវបានវាយតម្លៃជារៀងរាល់ខែដោយគណៈគ្រប់គ្រង។ ផ្អែក ដែលត្រូវគេវាយតម្លៃ រួមបញ្ចូលទំហំនៃប្រភេទឥណទាន ការខាតបង់ពីគ្រាមុន លក្ខខណ្ឌសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងផលប៉ះពាល់លើអតិថិជន ស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន និងប្រតិបត្តិការឥណទានដែលទាក់ទងនឹងលក្ខខណ្ឌក្នុងកិច្ចសន្យា។

ឥណទានត្រូវបានជម្រះចេញពីបញ្ជីនៅក្នុងរបាយការណ៍លទ្ធផល នៅពេលដែលឥណទានដែលនៅសល់មិនទាន់បានបង់រយៈពេល១ឆ្នាំ ក្រោយកាលបរិច្ឆេទអាយុកាល ឬនៅពេលដែលអតិថិជនទទួលមរណៈភាព។ ឥណទានដែលបានជម្រះចេញពីបញ្ជី ត្រូវបានយកចេញពីប្រភេទឥណទានដែលនៅសល់ និងដកចេញពីសំវិធានធនសម្រាប់ការខាតបង់ឥណទាន។ ឥណទានអតិថិជនដែលប្រមូលបានមកវិញ បន្ទាប់ពីត្រូវបានជម្រះចេញពីបញ្ជីរួចហើយ ត្រូវបានកត់ត្រានៅក្នុង របាយការណ៍លទ្ធផល។

## ២.៥ សំវិធានធនសម្រាប់ឥណទានអាក្រក់ និងសង្ស័យ

ក្រុមហ៊ុនបានអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន តាមតម្រូវការរបស់ប្រកាសលេខ ធ៧-០២-១៨៦ ប្រ.ក. ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២។ ប្រកាសនេះ តម្រូវឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងឡាយ ធ្វើចំណាត់ថ្នាក់ ប្រភេទឥណទានរបស់ខ្លួនជា៤ថ្នាក់ ហើយត្រូវប្រាកដថាគ្រឹះស្ថានរបស់ខ្លួន បានបំពេញកាតព្វកិច្ច សំវិធានធនជាក់លាក់ អប្បបរមា ដូចខាងក្រោម ៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលផុតកំណត់ | សំវិធានធន |
|---|---|---|
| **ឥណទានរយៈពេលខ្លី (តិចជាង១ឆ្នាំ)** | | |
| ក្រោមស្តង់ដា | ពី ៣១ថ្ងៃ ទៅ ៦០ថ្ងៃ | ១០% |
| សង្ស័យ | ពី ៦១ថ្ងៃ ទៅ ៩០ថ្ងៃ | ៣០% |
| បាត់បង់ | លើសពី ៩០ថ្ងៃ | ១០០% |
| **ឥណទានរយៈពេលវែង (លើសពី១ឆ្នាំ)** | | |
| ក្រោមស្តង់ដា | ពី ៣១ថ្ងៃ ទៅ ១៨០ថ្ងៃ | ១០% |
| សង្ស័យ | ពី ១៨១ថ្ងៃ ទៅ ៣៦០ថ្ងៃ | ៣០% |
| បាត់បង់ | លើសពី ៣៦០ថ្ងៃ | ១០០% |

សំវិធានធនជាក់លាក់ដែលត្រូវបានគណនា ជាចំនួនភាគរយនៃឥណទានដែលនៅសល់ នៅពេលដែលឥណទាន ត្រូវបានធ្វើចំណាត់ថ្នាក់ ដោយមិនរាប់បញ្ចូលការប្រាក់បង្គរ ហើយត្រូវបានចាត់ជាបន្ទុកចំណាយ។

ក្រៅពីសំវិធានធនខាងលើ សំវិធានធនបន្ថែមលើឥណទានបាត់បង់សម្រាប់ឥណទានអាក្រក់ និងសង្ស័យ ត្រូវបានធ្វើ ឡើងតាមអត្រា១% លើឥណទានដំណើរការល្អ ដែលនៅមិនទាន់ទូទាត់ទាំងអស់ ដោយមិនរាប់បញ្ចូល ឥណទានផ្តល់ដល់បុគ្គលិក។

## ២.៦ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការចុះថយតម្លៃបង្គរ។ ថ្លៃដើមរួមមាន ចំណាយផ្ទាល់ផ្សេងៗ ក្នុងការទិញទ្រព្យសកម្មទាំងនោះ។

រំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋាន រំលស់ថេរ លើអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃទ្រព្យសកម្មនីមួយៗនោះ តាមអត្រាដូចខាងក្រោម ៖

- យានយន្ត ៨ ឆ្នាំ
- ម៉ូតូ ៥ ឆ្នាំ
- កុំព្យូទ័រ និងបរិក្ខារការិយាល័យ ៣ ឆ្នាំ ទៅ ៤ ឆ្នាំ

តម្លៃនៅសល់ និងការប៉ាន់ស្មានអាយុកាលប្រើប្រាស់របស់ទ្រព្យសម្បត្តិ ត្រូវបានត្រួតពិនិត្យ ឬធ្វើវិសោធនកម្ម នៅពេលដែលមានភាពចាំបាច់ នូវរាល់កាលបរិច្ឆេទតារាងតុល្យការ។

ចំណាយបន្តបន្ទាប់ផ្សេងៗ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃនៅសល់នៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជា ទ្រព្យដាច់ដោយឡែកតាមការជាក់ស្តែង នៅពេលដែលមានភាពប្រាកដថា ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃ ទ្រព្យនោះនឹងហូរចូលមកក្នុងក្រុមហ៊ុន ហើយថ្លៃដើមនៃទ្រព្យនោះ អាចត្រូវបានវាស់វែងគួរឲ្យជឿជាក់បានតែ ប៉ុណ្ណោះ។ ចំណាយបន្តបន្ទាប់ផ្សេងទៀត ត្រូវបានកត់ត្រាជាបន្ទុកចំណាយក្នុងឆ្នាំដែលប្រតិបត្តិការនោះកើតឡើង។

នៅពេលដែលតម្លៃនៅសល់របស់ទ្រព្យសម្បត្តិ ច្រើនជាងតម្លៃប៉ាន់ស្មានដែលអាចយកមកវិញបាន វាត្រូវបានកត់ត្រាភ្លាមៗក្នុងតម្លៃដែលអាចយកមកវិញបាន។ តម្លៃប៉ាន់ស្មានដែលអាចយកមកវិញបាន គឺជាចំនួនច្រើនជាងនៃលំហូរ សាច់ប្រាក់ដែលបានធ្វើអប្បហារពីការបន្តប្រើប្រាស់ទ្រព្យសម្បត្តិ និងចំនួនដែលអាចទទួលបានពីការលក់ទ្រព្យសម្បត្តិ ដកថ្លៃដើមនៃការជម្រះចេញរបស់ទ្រព្យសម្បត្តិនោះ។

ចំណេញ ឬខាតដែលកើតឡើងពីទ្រព្យសម្បត្តិ និងបរិក្ខារដែលបានជម្រះចេញ ឬលែងប្រើប្រាស់ត្រូវបានកំណត់ថា ជាលំអៀងរវាងការប៉ាន់ស្មាននៃការលក់ចេញសុទ្ធ ទៅនឹងតម្លៃនៅសល់របស់ទ្រព្យនោះ ហើយត្រូវបាន កត់ត្រាក្នុង របាយការណ៍លទ្ធផល នាកាលបរិច្ឆេទជម្រះចេញ ឬលែងប្រើប្រាស់របស់ទ្រព្យនោះ។

## ២.៧ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ និងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានរាយការណ៍ តាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានគេធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើងក្នុងការទិញកម្មវិធីនោះមកប្រើប្រាស់។ ថ្លៃដើមនេះ ត្រូវបានគេធ្វើរំលស់រយៈពេល ៥ឆ្នាំ ដោយប្រើវិធីសាស្ត្ររំលស់ថេរ។

ថ្លៃដើមទាក់ទងនឹងការថែទាំកម្មវិធីកុំព្យូទ័រ ត្រូវបានកត់ត្រាជាបន្ទុកចំណាយ នៅពេលដែលប្រតិបត្តិការនោះ បានកើតឡើង។

## ២.៨ បម្រែបម្រួលក្នុងការប៉ាន់ស្មានគណនេយ្យ

ក្នុងអំឡុងឆ្នាំ ក្រុមហ៊ុនបានធ្វើការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យនៃអាយុកាលប្រើប្រាស់ និងវិធីសាស្ត្រសម្រាប់ ទ្រព្យសកម្មរូបី និងអរូបី។ អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មមួយចំនួន ត្រូវបានផ្លាស់ប្តូរ និងវិធីសាស្ត្រក្នុងការ ធ្វើរំលស់ក៏បានផ្លាស់ប្តូរពីវិធីសាស្ត្ររំលស់ថយទៅវិធីសាស្ត្ររំលស់ថេរវិញ។ គណៈគ្រប់គ្រងយល់ឃើញថា ការប្រើប្រាស់ វិធីសាស្ត្ររំលស់ថ្មីលើអាយុកាលប្រើប្រាស់នេះ ផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធច្រើន ហើយដែលអាចជឿជាក់បាន ព្រោះវាធ្វើ ឲ្យមានភាពច្បាស់លាស់ទៅលើអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម និងមានលក្ខណៈ សមស្របទៅនឹងប្រតិបត្តិការ របស់ក្រុមហ៊ុន។ ប្រសិទ្ធភាពនៃការផ្លាស់ប្តូរនេះ ត្រូវបានចាប់អនុវត្ត ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១។ ប្រសិនបើការ ប៉ាន់ស្មានគណនេយ្យ មិនត្រូវបានផ្លាស់ប្តូរ នោះចំណាយលើរំលស់រូបីដែលបានរាយការណ៍ សម្រាប់ឆ្នាំ២០១១ មានចំនួន ខ្ពស់ជាង ២៣លានរៀល និងចំណាយលើរំលស់អរូបី មានចំនួនខ្ពស់ជាង ១៦លានរៀល។

| បម្រែបម្រួលក្នុងវិធីសាស្ត្ររំលស់ និងអត្រាប្រចាំឆ្នាំ | វិធីសាស្ត្ររំលស់ថយ | វិធីសាស្ត្ររំលស់ថេរ |
|---|---|---|
| **ទ្រព្យសម្បត្តិ និងបរិក្ខារ ៖** | | |
| យានយន្ត | ២៥% | ១២,៥០% |
| ម៉ូតូ | ២៥% | ២០,០០% |
| កុំព្យូទ័រ និងបរិក្ខារការិយាល័យ | ៥០% | ២៥,០០% - ៣៣,៣៣% |
| **ទ្រព្យសកម្មអរូបី** | | |
| កម្មវិធីកុំព្យូទ័រផ្សេងៗ | ៥០% | ២០% |

## ២.៩ ការថយចុះតម្លៃ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មទាំងឡាយណាដែលមានអាយុកាលប្រើប្រាស់មិនកំណត់ មិនត្រូវបានធ្វើរំលស់ទេ ហើយវាត្រូវបាន គេត្រួតពិនិត្យប្រចាំឆ្នាំ ដើម្បីរកការថយចុះតម្លៃរបស់វា។ ទ្រព្យសកម្មទាំងឡាយណា ដែលត្រូវគេធ្វើរំលស់ ត្រូវបានត្រួតពិនិត្យរកការថយចុះតម្លៃរបស់វា នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយ ចង្អុលបង្ហាញថា តម្លៃនៅសល់របស់វា នឹងមិនអាចស្រង់មកវិញបាន។ ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាតាម ចំនួនលំអៀងរវាងតម្លៃនៅសល់នៃទ្រព្យនោះ ធៀបជាមួយតម្លៃដែលអាចស្រង់មកវិញបាន។ តម្លៃដែលអាចស្រង់មក វិញបាន គឺជាតម្លៃមួយណាដែលខ្ពស់ជាង រវាងតម្លៃទីផ្សារនៃទ្រព្យនោះ ដកចំណាយក្នុងការលក់ និងតម្លៃនៅប្រើប្រាស់បាន។ ក្នុងការវាយតម្លៃដើម្បីរកការថយចុះ ទ្រព្យសម្បត្តិទាំងឡាយ ត្រូវបានចាត់ជាក្រុមតូចៗបំផុត ដើម្បីកំណត់ពីលំហូរ សាច់ប្រាក់នីមួយៗ (ឯកត្តាបង្កើតសាច់ប្រាក់ “cash-generating units”)។

ខាតបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាប្រសិនបើតម្លៃនៅសល់នៃទ្រព្យ ឬឯកត្តាបង្កើតសាច់ប្រាក់ របស់វាលើសពីតម្លៃប៉ាន់ស្មានដែលអាចស្រង់មកវិញបាន។ ខាតបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាក្នុង របាយការណ៍លទ្ធផល។

## ២.១០ ប្រាក់បញ្ញើ

ប្រាក់បញ្ញើរបស់អតិថិជនត្រូវបានកត់ត្រាទុកតាមតម្លៃនៃប្រាក់តម្កល់។

## ២.១១ ប្រាក់កម្ចី

ប្រាក់កម្ចី ត្រូវបានកត់ត្រាតាមចំនួនប្រាក់ដើម ដែលមិនទាន់ទូទាត់។ កម្រៃផ្សេងៗ ដែលបានចំណាយដើម្បីទទួល បានប្រាក់កម្ចី ត្រូវបានធ្វើមូលធនកម្ម និងធ្វើរំលស់លើរយៈពេលនៃប្រាក់កម្ចីនោះដោយប្រើវិធីសាស្ត្ររំលស់ថេរ។

## ២.១២ សំវិធានធន

សំវិធានធន ត្រូវបានកត់ត្រានៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ចដែលក្រុមហ៊ុនបាន បង្កើតឡើងនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល វាទំនងជាអាចតម្រូវឲ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់ត្រូវបានប៉ាន់ស្មានគួរឲ្យជឿជាក់បាន។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន កម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ ដោយគិតទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចនោះទាំងមូល។ សំវិធានធនត្រូវបានកត់ត្រា ទោះបីជាកម្រិតលំហូរចេញនៃខ្ទង់ណាមួយ នៅក្នុងចំណាត់ថ្នាក់កាតព្វកិច្ចដូចគ្នានោះមានចំនួនតូចក៏ដោយ។

សំវិធានធនត្រូវបានវាស់វែងឡើងវិញតាមតម្លៃបច្ចុប្បន្ន នៃចំណាយដែលរំពឹងថាត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ន នៃតម្លៃសាច់ប្រាក់គិតតាមពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធន ដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានកត់ត្រាជាចំណាយលើការប្រាក់។

## ២.១៣ សំវិធានធនសម្រាប់មូលនិធិសោធនិវត្តន៍របស់បុគ្គលិក

ក្រុមហ៊ុនផ្តល់អត្ថប្រយោជន៍ដល់បុគ្គលិករបស់ខ្លួន ក្រោមគោលការណ៍មូលនិធិសោធននិវត្តន៍។ បុគ្គលិកដែលបំពេញសេវាកម្មឲ្យក្រុមហ៊ុនលើសពីរយៈពេល ៣ខែទៅ មានសិទ្ធិចូលរួមក្នុងមូលនិធិសោធននិវត្តន៍នេះ។ មូលនិធិនេះ មានប្រភពមកពីកត្តាដូចខាងក្រោម ៖

- បុគ្គលិកចូលរួមចំណែក ៣% នៃប្រាក់បៀវត្សប្រចាំខែរបស់ខ្លួន ហើយក្រុមហ៊ុនចូលរួមចំណែក ៦%។ ការរួមចំណែករបស់ក្រុមហ៊ុន ត្រូវបានកត់ត្រាជាបន្ទុកចំណាយនៅក្នុងរបាយការណ៍លទ្ធផល។
- ក្រុមហ៊ុនផ្តល់ការប្រាក់លើសមតុល្យបង្គរនៃមូលនិធិសោធននិវត្តន៍ដែលត្រូវបានគណនាតាមអត្រា ៧% ក្នុងមួយឆ្នាំ។ ការប្រាក់នេះត្រូវបានកត់ត្រាជាបន្ទុកចំណាយនៅក្នុងរបាយការណ៍លទ្ធផល។

មូលនិធិសោធនិវត្តន៍នឹងត្រូវទូទាត់ជូនបុគ្គលិក (បុគ្គលិកដែលបានចូលរួមចំណែកក្នុងមូលនិធិ) នៅពេលដែល បុគ្គលិកចូលនិវត្ត លាឈប់ពីការងារ ឬត្រូវបញ្ឈប់ពីការងារ។ ការរួមចំណែករបស់បុគ្គលិក ព្រមទាំងការប្រាក់ត្រូវបាន ក្រុមហ៊ុនទូទាត់ជូនយ៉ាងពេញលេញ។

បុគ្គលិកទាំងឡាយណា ដែលត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងារ ដោយសារការប្រព្រឹត្តខុសឆ្គងធ្ងន់ធ្ងរ ត្រូវទទួលបានមូលនិធិនេះត្រឹមតែចំណែកដែលបុគ្គលិករូបនោះបានបង់រួមទាំងការប្រាក់ប៉ុណ្ណោះ ដោយមិនគិតលើអតីតភាពការងាររបស់បុគ្គលិករូបនោះឡើយ។

## ២.១៤ ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ និងពន្ធលើប្រាក់ចំណេញពន្យារ

បន្ទុកពន្ធលើប្រាក់ចំណេញ ត្រូវបានគណនាតាមមូលដ្ឋានច្បាប់សារពើពន្ធដែលបានអនុម័តរួច ឬអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នៅក្នុងប្រទេសកម្ពុជា ដែលជាប្រទេសដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ និងបង្កើត ប្រាក់ចំណេញជាប់ពន្ធ។

ពន្ធពន្យារ ត្រូវបានកត់ត្រាតាមវិធីសាស្ត្រទ្រព្យអកម្មក្នុងតារាងតុល្យការលើលំអៀងបណ្តោះអាសន្ននៃតម្លៃ នៅសល់របស់ទ្រព្យសកម្ម និងទ្រព្យអកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ធៀបនឹងចំនួនដែលបានប្រើប្រាស់សម្រាប់ការគណនាពន្ធ។ ពន្ធពន្យារ ត្រូវបានវាស់វែងតាមអត្រាពន្ធដែលបានអនុម័តរួច ឬអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ ដែលរំពឹងថានឹងត្រូវអនុវត្តចំពោះលំអៀងបណ្តោះអាសន្ន នៅពេលដែលវាត្រូវកត់ត្រាបញ្ច្រាសមកវិញ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទូទាត់ជាមួយនឹងពន្ធពន្យារទ្រព្យអកម្ម ប្រសិនបើក្រុមហ៊ុនមានសិទ្ធិ តាមផ្លូវច្បាប់ ដើម្បីទូទាត់បំណុលពន្ធក្នុងឆ្នាំ ហើយវាទាក់ទងនឹងពន្ធលើប្រាក់ចំណេញ ដែលកំណត់ដោយអាជ្ញាធរពន្ធដារតែមួយ ទៅលើក្រុមហ៊ុនជាប់ពន្ធតែមួយ។

ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានកត់ត្រា លុះត្រាតែមានភាពប្រាកដថាក្រុមហ៊ុននឹងមានប្រាក់ចំណេញជាប់ពន្ធនា ពេលអនាគត សម្រាប់យកលំអៀងបណ្តោះអាសន្នមកប្រើប្រាស់។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានត្រួតពិនិត្យ នៅរៀងរាល់កាលបរិច្ឆេទរបាយការណ៍នីមួយៗ ហើយត្រូវបានកត់ត្រាបន្ថយ ប្រសិនបើមិនមានភាពប្រាកដថានឹងមាន អត្ថប្រយោជន៍ពន្ធពាក់ព័ន្ធ ត្រូវបានទទួលស្គាល់។

## ២.១៥ ការកត់ត្រាចំណូល និងចំណាយ

ចំណូលពីការប្រាក់បានមកពីឥណទានផ្សេងៗ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ។ នៅពេលដែលឥណទានក្លាយជា ឥណទានមិនដំណើរការ ការកត់ត្រាចំណូលពីការប្រាក់ត្រូវបានព្យួរទុកមួយរយៈ រហូតដល់ពេលដែលគេទទួលបាន សាច់ប្រាក់ជាក់ស្តែង។

